ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-May-2012, 14:10
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:០៦ នាទី**

**សវនាការលើកទី៦៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដារ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉េង ហ៊ាត់

លោក វាំងសង់ វ៉ាយដ៍ ដេស្តាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក ឡោ ជុនធី

លោក គីម ម៉េងឃី

លោក វ៉ែន ពៅ

លោក បាណាបេ ណេគ្វី*(Mr. Barnabé NEKUIE)*

លោកស្រី ឡូរ៍ ដេសហ្វកស៍

*(Ms. Laure DESFORGES)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក នី កន (TCW-487) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ÷ លោក នី កន** (TCW-487)

សួរដោយ លោក ប្រធានអង្គជំនុំ ផ្តើមពី៖ ....................ទំព័រ ៣
សួរដោយ លោក ច័ន្ទ តារាវស្មី ផ្តើមពី៖ ....................ទំព័រ ៥
សួរដោយ លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី៖....................ទំព័រ ៤១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៥៤]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងសប្តាហ៍នេះ តាមកាលវិភាគដែលបានកំណត់សម្រាប់ធ្វើសវនាការ អង្គជំនុំជម្រះសាលាដំបូងកំណត់កាលបរិច្ឆេទសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 487 និងក្នុងករណីមិនអាចធ្វើបាន អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដែលមានរហស្សនាម 488 ហើយនិងអាចបន្តនៅចុងសប្តាហ៍នេះនូវសាក្សីបន្តបន្ទាប់ទៀត ដូចជា 321 ជាដើម។

[០៩:០៨:៥៣]

មុននឹងចាប់ផ្តើម សូមក្រឡាបញ្ជីរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវបានអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។

ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មថ្ងៃនេះ គឺសាក្សី TCW-487។ សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:១០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទនៅក្នុងថ្ងៃនេះ ដោយលោក អៀង សារី បានលះបង់សិទ្ធិលាយលក្ខណ៍អក្សរមកអង្គជំនុំ

ជម្រះ ដោយគាត់មិន-- សម្រេចចិត្តមិនចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ ប៉ុន្តែគាត់បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោមមួយ នៃបន្ទប់សវនាការនេះ ដោយមានឧបករណ៍សោតទស្សន៍សម្រាប់រូបគាត់។ ហើយមុននឹងកោះអញ្ជើញសាក្សីចូលមកកាន់សវនាការ អង្គជំនុំជម្រះសូមសម្រេចលើបញ្ហាឯកសារដែលមានអត្តសញ្ញាណ D366/7.1.188។

**អ្នកបកប្រែ៖**

លោកប្រធានសូមអធ្យាស្រ័យ សូមលោកអានឯកសារហ្នឹងឡើងវិញទាន។

[០៩:១១:០០]

**ប្រធានអង្គជំនុំ៖**

ឯកសារ D366/7.1.188។ នៅក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានស្នើសុំឱ្យតំណាងសហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ទៅលើឯកសារ D366/7.1.188 ដែលមានចំណងជើងថា "លក្ខន្តិកៈសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា"។ ព្រោះតំណាងសហព្រះរាជអាជ្ញាមានបំណងយោងទៅលើឯកសារនេះ នៅពេលតាំងសំណួរដេញដោលចំពោះសាក្សី TCW-487។ តាមការពិនិត្យមើលសំណុំរឿងដំបូង វាបង្ហាញថា ឯកសារនេះមិនមាននៅក្នុងបញ្ជីឯកសារដំបូងដែលសហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះនៅក្នុងខែមេសា ឆ្នាំ២០១១ ឯកសារ E9/31 និងនៅខែកក្កដា ឆ្នាំ២០១១ ឯកសារ E109/4 នោះទេ។ បន្ថែមលើការបញ្ជាក់របស់តំណាងសហព្រះរាជអាជ្ញាដែលបានធ្វើក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ នោះ ឥឡូវនេះអង្គជំនុំជម្រះសូមបញ្ជាក់ថា ឯកសារនេះមាននៅក្នុងបញ្ជីឯកសារដំបូងទាំងពីររបស់សហព្រះរាជអាជ្ញា។

ដោយឯកសារនេះមាននៅក្នុងឧបសម្ព័ន្ធទីពីរនៃឯកសារ E109/4 ដូច្នេះឯកសារនេះក៏ចាត់ទុកថាត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះផងដែរ ចំពោះភាពអាចទទួលយកបាននៃឯកសារដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា។

[០៩:១៣:០៤]

ដូចមានបញ្ជាក់នៅក្នុងសេចក្តីសម្រេចឯកសារ E185។ ផ្អែកលើគោលការណ៍ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចឯកសារ E185 អង្គជំនុំជម្រះបានពិនិត្យឡើងវិញនូវឯកសារ D366/7.1.188 នេះ។ ដូច្នេះ អង្គជំនុំជម្រះចាត់ទុកថា ឯកសារនេះត្រូវបានដាក់នៅចំពោះអង្គជំនុំជម្រះ។ ហេតុដូច្នេះ

ឯកសារនេះនឹងត្រូវចាត់ថ្នាក់ទៅជាប្រភេទឯកសារ E3 នៅពេលឆាប់ៗខាងមុននេះតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ន ឯកសារនេះនឹងរក្សានូវលេខឯកសារ D366/7.1.188 ដដែល។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី TCW-487 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[០៩:១៤:០៩]

*(សាក្សីចូលមកក្នុងបន្ទប់សវនាការ)*

[០៩:១៥:៤១]

**ប្រធានអង្គជំនុំ៖**

អរុណសួស្ដីលោកសាក្សី។ លោកសាក្សីមុននឹងដំណើរការសួរដេញដោលចំពោះលោក ទីមួយ អង្គជំនុំជម្រះសូមណែនាំលោកក្នុងការប្រើប្រាស់ក្បាលមីក្រូ ដើម្បីឆ្លើយតបទៅនឹងសំណួរផ្សេងៗ គឺលោកនឹងអាចឆ្លើយតបនៅពេលណានៅក្បាលមីក្រូហ្នឹងមានសញ្ញាភ្លើងក្រហមដូចនេះ លោកចាប់ផ្ដើមនិយាយ ពីព្រោះបើសិន បើលោកនិយាយមុននេះ គឺមិនអាចមានការបកប្រែទេ ពោះវាអត់មានសំឡេងចេញទៅអ្នកបកប្រែខាងក្រោយ ហើយមានការបង្អង់បន្តិចទៅ គឺលោកអាចនឹងឃើញភ្លើងក្រហមហើយលោកចាប់ផ្ដើមឆ្លើយ។ ទីពីរ អង្គជំនុំជម្រះសូមសួរអំពីសាវតាររបស់លោកជាមុនសិន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកឈ្មោះអ្វីទៅសាក្សី?

**លោក នី កន៖**

**ឆ៖** សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ នី កន ហៅកន។

**ស៖** បាទអរគុណ។ រហូតដល់ឆ្នាំនេះ តើលោកមានអាយុប៉ុន្មានហើយ។

**ឆ៖** ខ្ញុំអាយុ៦៩។

**ស៖** បាទអរគុណ។ តើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណាដែរ?

**ឆ៖** ទីលំនៅសព្វថ្ងៃ ខ្ញុំនៅស្រុកសំពៅលូន។

**ស៖** បាទ អរគុណ។ តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំជាទីប្រឹក្សាក្រសួងការពារជាតិ ហើយបច្ចុប្បន្នចុះជួយការងារបក្សស្រុកសំពៅលូន។

**ស៖** បាទ អរគុណ។ តើឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪឈ្មោះខ្ញុំឈ្មោះ សឹង នី ស្លាប់។

**ស៖** ចុះម្តាយរបស់លោក-- ម្តាយបង្កើតរបស់លោកឈ្មោះអីដែរ?

[០៩:១៨:០៥]

**ឆ៖** ម្តាយខ្ញុំឈ្មោះ សឹង សឿង។

**ស៖** ចុះប្រព័ន្ធរបស់លោកឈ្មោះអី?

**ឆ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ លឹម គឹមសាត។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានកូនបីនាក់?

**ស៖** អរគុណ។ លោក នី កន តាមរបាយការណ៍របស់ក្រឡាបញ្ជីថា លោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយភាគីនៃរឿងក្តីនេះទេ តាំងដើមបណ្តឹងរដ្ឋប្បវេណី ក៏ជនជាប់ចោទទាំងបីរូបនាក់ដែរ តើមិន-- ជនជាប់ចោទទាំងបីរូបដែរ តើពិតមែនដែរឬទេ?

[០៩:១៩:០៧]

**ឆ៖** ជាការពិតលោកប្រធាន។

**ស៖** ហើយមុននឹងចូលមកកាន់បន្ទប់សវនាការដើម្បីផ្តល់សក្ខីកម្មនេះ តើលោកបានស្បថហើយឬនៅ?

**ឆ៖** សូមជម្រាបថា ខ្ញុំបានស្បថហើយ ស្បថប្រហែលជាបួនថ្ងៃហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក នី កន នៅក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ លោកមានសិទ្ធិបដិសេធក្នុងការឆ្លើយទៅសំណួរ ឬសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលោកខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវរងការចោទប្រកាន់។ ទន្ទឹមនឹងនេះ លោកក៏មានករណីកិច្ចនិយាយតែការ-- អ្នកណាដែលពិត ដែលលោកបានដឹងបានឮ បានឃើញ បានចាំ ឬក៏ឆ្លងកាត់នូវបទពិសោធន៍របស់លោកដែលលោកបានជួបប្រទះ លើកលែងតែសំណួរឯណាដែលប្រឆាំងទៅលើខ្លួនឯង។ គឺឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធ

ទៅនឹងព្រឹត្តិហេតុ ឬអង្គហេតុទាំងឡាយដែលលោកបានដឹង។ តើលោកយល់ទេ?

**លោក នី កន៖**

ជម្រាបលោកប្រធាន ខ្ញុំយល់បាទ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះក៏បានផ្តល់មេធាវីប្រឹក្សាលោកផងដែរ។ អ៊ីចឹងគឺលោកមេធាវីលោកមានបទពិសោធន៍នៅក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ ក្នុងការផ្តល់ប្រឹក្សាយោបល់ចំពោះសាក្សី ដើម្បីបញ្ចៀសក្នុងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងហើយ។ ហើយនេះជាសិទ្ធិបាទ។

[០៩:២១:២៥]

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីផ្តើមការតាំងសំណួរដេញដោលចំពោះសាក្សីនេះមុនភាគីឯទៀត។

សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពលោកលោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងសវនាការនៅពេលនេះ ហើយក៏សូមគោរពបងប្អូនជនរួមជាតិទាំងអស់ដែលមាន ដែលកំពុងតាមដានកម្មវិធីសវនាការនៅខាងក្រៅបន្ទប់សវនាការនៅពេលនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

សួស្តីលោក នី កន! បាទ ក្នុងនាមខ្ញុំតំណាងសហព្រះរាជអាជ្ញា ខ្ញុំអនុញ្ញាតជម្រាបសួរសំណួរមួយចំនួនទាក់ទិននឹងអ្វីដែលលោកបានដឹង បានឮនៅក្នុងអតីតកាល។ នៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យបាទ។ សំណួរជាបន្តនេះ គឺខ្ញុំសូមសួរពាក់ព័ន្ធទៅនឹងប្រវត្តិគ្រួសាររបស់លោក។

**ស៖** សំណួរទីមួយ គឺតើលោកមានបងប្អូនប្រុសប៉ុន្មាននាក់?

[០៩:២២:៣៥]

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន ខ្ញុំមានបងប្អូនប្រុសពីរនាក់បាទ។

**ស៖** តើគាត់ឈ្មោះអ្វីដែរបាទ?

**ឆ៖** ទីមួយឈ្មោះ សុន សេន។

**ស៖** ទីពីរ?

**ឆ៖** ទីពីរឈ្មោះ សុន ឈុំ។

**ស៖** សូមអរគុណបាទ។ តើលោកអាចរៀបរាប់បានដោយសង្ខេបអំពីតួនាទី និងមុខងាររបស់បងប្អូនរបស់លោកទាំងពីរនាក់បានដែរឬទេ នៅក្នុងចលនាបដិវត្តន៍ក្នុងបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** សូមជម្រាបជូន តួនាទីខ្ញុំមិនច្បាស់ទេ។ បងទីមួយ បងឈ្មោះ សុន សេន ខ្ញុំមិនច្បាស់ជាតួនាទីស្អីច្បាស់ តែបងទីពីរច្បាស់ថា បានធ្វើទូតនៅកូរ៉េមួយរយៈខ្លីបាទ។

[០៩:២៣:៣៨]

**ស៖** ធ្វើទូតនៅកូរ៉េហ្នឹង គឺគាត់ធ្វើទូតនៅក្នុងឆ្នាំណា? ពីឆ្នាំណាដល់ឆ្នាំណាដែរបាទ?

**ឆ៖** ខ្ញុំមិនបានចាំទេបាទ។ គ្រាន់តែដឹងថា ចុងក្រោយបាទ។

**ឆ៖** បាទសូមអរគុណ។ ចំពោះលោក សុន សេន ដែលលោកបានបញ្ជាក់ថា មិនចាំច្បាស់ថា តើអាចបញ្ជាក់បានខ្លះៗទេ អំពីតួនាទីរបស់គាត់នៅក្នុងសម័យកាលនៃចលនាបដិវត្តន៍កុម្មុយនីស្តកម្ពុជាក្នុងសម័យកាលនោះបាទ?

**ឆ៖** សូមជម្រាបជូន ខ្ញុំដឹងជារួមថា គាត់ធ្លាប់ដឹកនាំទ័ពសម័យនុំងបាទ។

**ស៖** ដឹកនាំទ័ពនៅក្នុងតំបន់ណាដែរបាទ? ក្នុងរយៈពេលប៉ុន្មានដែរ ដែលគាត់ដឹងនាំទ័ពនុំងបាទ? ហើយនៅក្នុងតំបន់ណាដែរបាទ?

**ឆ៖** ដឹកនាំទ័ពនៅសម័យវ៉ៃចក្រពត្តិអាមេរិកបាទ ដែលច្បាស់។

**ស៖** តើគាត់ដឹកនាំនៅក្នុងតំបន់ណា? ភូមិភាគណាដែរ?

[០៩:២៥:០៩]

**ឆ៖** ឃើញដឹកនាំរួម ឃើញតែចាប់ចុះពីម្តុំយើងស្ទឹងត្រែងអីចុះមកក្រោមអ៊ីចឹងមក។ បាទដឹកនាំចុះមកក្រោមអ៊ីចឹងមក ហើយចប់បណ្តោយទៅ ចប់៧៥ បណ្តោយទៅ។

**ស៖** លោកអាចចាំបានទេថា គាត់-- លោកអាចមានចាំ-- ចងចាំអំពីឈ្មោះកងពលទេបាទ? អាចបញ្ជាក់បានអំពីកងពលលេខប៉ុន្មាន ឬក៏យ៉ាងម៉េច?

**ឆ៖** សូមជម្រាបជូនថា រឿងនេះខ្ញុំចាំមិនបានទេ។ មិនដឹងមិនចាំទេ។

**ស៖** សូមអរគុណ។ បន្ទាប់មកក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ តើលោកមាន តើលោកចាំទេថា បងប្រុសទាំងពីររបស់លោក គាត់មានតួនាទីអ្វីដែរ?

**ផ៖** ដូចខ្ញុំជម្រាបអម្បាញ់មិញគឺ ខ្ញុំដឹងជារួម ថាចូលរួមដឹកនាំទ័ពតែកម្រិតណាអីកម្រិតណាមិនដឹងទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តទៅសំណួរទាក់ទងនឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកផ្ទាល់ពីមុនឆ្នាំ៧៥ រហូតដល់ឆ្នាំ១៩៧៥។ ចំណុចដែលខ្ញុំចង់ដឹងគឺទាក់ទងនឹងការសិក្សា ហើយនិងការងាររបស់លោក។ សំណួរដែលខ្ញុំចង់សួរបន្តគឺថា តើការរៀនសូត្ររបស់លោកដល់កម្រិតណាដែរ?

[០៩:២៦:៤៣]

**ផ៖** សូមជម្រាបជូន ខ្ញុំរៀនបានត្រឹមថ្នាក់ឌីប្លូម ១៩៦៥។

**ស៖** នៅសាលាណាដែរបាទ?

**ផ៖** នៅវិទ្យាល័យស៊ីសុវត្ថិភ្នំពេញ។

**ស៖** បន្ទាប់មកតើលោកបានចាប់ផ្ដើមបន្តការសិក្សាអ្វីផ្សេងទៀតក្រៅពីនេះដែរឬទេ?

**ផ៖** ខ្ញុំអត់បានរៀនអីទៀតទេ។ ខ្ញុំចេញធ្វើគ្រូ។

**ស៖** លោកធ្វើគ្រូនៅសាលាណាដែរ?

**ផ៖** ខ្ញុំធ្វើគ្រូនៅខេត្តសៀមរាប នៅសាលាបឋមសិក្សា។

**ស៖** សូមអរគុណ។ តើលោកធ្វើគ្រូហ្នឹងពីឆ្នាំណាដល់ឆ្នាំណា?

**ផ៖** ខ្ញុំធ្វើគ្រូបានរយៈខ្លីទេ ពីព្រោះចេញពីកន្លែង*ស្លាស់*ទៅវាអស់មួយឆ្នាំហើយ។ រួចចេញពី*ស្លាស់*ទៅទៀត ទៅបានប្រហែលពីរឆ្នាំ ក៏ឈប់ទៅ។ ពីរឆ្នាំ ឬបីឆ្នាំ មិនច្បាស់ ក៏ឈប់។

[០៩:២៨:១១]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកពាក់ព័ន្ធនឹងបងប្រុសរបស់លោក គឺឈ្មោះលោក សុន សេន។ តើបងប្រុសរបស់លោកឈ្មោះ សុន សេន ហ្នឹងបានលើកទឹកចិត្តឲ្យលោក-- ឲ្យលោកចូលរួមក្នុងចលនាបដិវត្តន៍ដែរឬទេ នៅពេលចប់ការសិក្សារបស់លោក?

**ផ៖** សូមជម្រាបជូន គឺធម្មតាគ្រួសារជាបងជាប្អូន ហើយយល់ថា អ្វីដែលល្អក៏ចេះតែណែនាំតែណែនាំជារួមទេ មិនបានថា ណែនាំឲ្យទៅទិសនេះ ទិសនោះអីទេ។ ប៉ុន្តែអ្វីដែលល្អ ឲ្យធ្វើទៅ។

**ស៖** តើគាត់មានបានណែនាំលោកឲ្យចូលទៅក្នុងចលនាបដិវត្តន៍ដែរឬទេ នៅពេលនោះ?

**ឆ៖** ជំនាន់នុ៎ងគឺជាចលនារួមក្នុងប្រទេសយើង ហៅថាចលនាប្រជាជនទូទៅ ចូលរួម ចូលព្រៃម៉ាគី។ ដូច្នេះក៏ទៅតាមគេតាមឯងអ៊ីចឹងទៅ បាទ ហើយគិតថាល្អ ក៏ទៅតាមហ្នឹង។

**ស៖** គោលបំណងសំខាន់នៃការបង្ហាញផ្លូវឲ្យលោកចូលនៅក្នុងចលនាបដិវត្តន៍ ឬក៏ចូលព្រៃម៉ាគីហ្នឹង គាត់មានបញ្ជាក់ថា ហេតុផលអ្វីដែរ?

[០៩:២៩:៥២]

**ឆ៖** ជំនាន់នុ៎ងគេបញ្ជាក់ថា ចូលព្រៃម៉ាគីដើម្បីរំដោះសត្រូវឈ្លានពាន ទីមួយ។ ទីពីរ ការពារបូរណភាពដែនដី។ ទីបី លើកស្ទួយជីវភាពប្រជាជន។ បាទ មានតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់អំមិញថា ដើម្បីរំដោះសត្រូវពានឈ្លាន តើសត្រូវឈ្លានពាននៅសម័យកាលនោះ ជាអ្នកណា? សូមលោកបញ្ជាក់ចំណុចនេះបន្តិចបាទ។

**ឆ៖** កាលនុ៎ង គេបញ្ជាក់ថា ជាអាមេរិក ហើយនិងរួមជាមួយ លន់ នល់ បាទ។ ប៉ុណ្ណឹងបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ហេតុអីបានចាត់ទុកថា លន់ នល់ ហើយនិងអាមេរិក ជាសត្រូវ? តើលោក សុន សេន បានបញ្ជាក់អំពីមូលហេតុនេះដែរឬទេ? ជម្រាបលោកដែរឬទេ ក្នុងករណីនេះ?

**ឆ៖** សូមជម្រាបជូន គឺបងៗរបស់ខ្ញុំមិនបានបញ្ជាក់អីទេ។ អានេះ ជាទូទៅក្នុងប្រទេសតែម្ដង ធ្វើគ្រូនៅកន្លែងណា គ្រូផ្សេងៗទេ រួមគ្នា យល់អ៊ីចឹងទៅ បាទ។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងទេថា លោក សុន សេន បានចូលព្រៃម៉ាគីមុនលោក ឬក៏នៅពេលណា បាទ?

[០៩:៣១:៣៧]

**ឆ៖** ខ្ញុំ និងបងខ្ញុំបែកគ្នា។ ខ្ញុំនៅជនបទ សៀមរាប ហើយតាមស្រុកទៀត។ បងខ្ញុំនៅភ្នំពេញ។ ដូច្នេះ គាត់ទៅធ្វើរណា អីធ្វើរណា។ អង្គាល់ណោះ ការសម្ងាត់ខ្ពស់ណាស់ ខ្ញុំមិនអាចដឹងទេបាទ។

**ស៖** លោកមានបានដឹងទេ ថាគាត់នៅភ្នំពេញ នៅក្នុងការិយាល័យណា? នៅក្នុងក្រសួងណា? ឬក៏នៅទីតាំងណា នៅពេលនោះ?

**ឆ៖** សូមជម្រាបជូន ខ្ញុំដឹងត្រួសៗ ថាគាត់នៅ គេហៅ-- សព្វថ្ងៃមិនដឹងគេហៅស្អីពីមុន ថានៅកន្លែងសាលានេះ នៅជិតវិមានឯករាជ្យបាទ។ វិមានឯករាជ្យ ដូចជាសាលាបណ្ដុះបណ្ដាលសាស្ត្រាចារ្យក៏មិនដឹង។ បាទ ខ្ញុំចាំមិនអស់ដែរ នៅម្ដុំហ្នឹង។

**សៈ** បាទ សូមអរគុណ។ តើលោកបានចូលរួមជាមួយនឹងបដិវត្តន៍នៅពេលណាពិតប្រាកដដែរ?

**ឆៈ** ខ្ញុំពេលក្រោយរដ្ឋប្រហារ៧០។

**សៈ** លោកអាចបញ្ជាក់ឆ្នាំច្បាស់ទេ បាទ ពីឆ្នាំណា ដល់ឆ្នាំណា?

**ឆៈ** ខ្ញុំចាំមិនច្បាស់ទេ គឺគ្រាន់តែថា ដឹងថាក្រោយរដ្ឋប្រហារ៧០ហ្នឹងមក។ ចុងឆ្នាំហ្នឹង ក៏ចូលរួមមក ហើយបន្តមករហូតមក ដល់ចប់សង្គ្រាម។

[០៩:៣៣:២៣]

**សៈ** បាទ សូមអរគុណ។ បន្ទាប់ពីបានចូលរួមជាមួយនឹងបដិវត្តន៍ តើលោកជាផ្នែកមួយនៃរណសិរ្សមែនឬទេ?

**ឆៈ** ជម្រាបជូន គឺត្រឹមត្រូវហើយ។ ព្រោះខ្ញុំ ក្នុងឋានៈជាគ្រូបង្រៀន ពេលនោះ គេត្រូវការកម្លាំងរណសិរ្ស ដើម្បីឃោសនា។ ព្រោះមានលទ្ធភាព ចេះនិយាយ ចេះឃោសនា ចេះកត់ត្រា។ តែប៉ុណ្ណឹងបាទ។

**សៈ** តើការឃោសនានៅពេលនោះ ផ្តោតទៅលើគោលដៅ និងគោលបំណងអ្វីខ្លះ? ខ្លឹមសារសំខាន់នៃការឃោសនាមានអត្ថន័យយ៉ាងដូចម្តេចដែរបាទ?

**ឆៈ** ខ្លឹមសារសំខាន់ ពេលនោះ គឺទីមួយ ចលនាប្រជាជនទូទៅ ដែលនៅក្នុងតំបន់ខ្លួននៅ ឲ្យបង្កបង្កើនផល ឧបត្ថម្ភខ្លួន ដោយអនុវត្តហៅថា "នយោបាយឯករាជ្យម្ចាស់ការ" គឺឧបត្ថម្ភខ្លួនជាសំខាន់។ ហើយទីពីរ រួមគ្នាទៅសមរភូមិមុខ។ តែប៉ុណ្ណឹងសំខាន់។

[០៩:៣៤:៥៦]

**សៈ** សូមអរគុណ។ តើរណសិរ្ស-- អ្វីដែលលោកបានបញ្ជាក់អំមិញ មានន័យថា លោកចូលរួមជាផ្នែកមួយនៃរណសិរ្ស តើរណសិរ្សហ្នឹង មានន័យដូចម្តេច?

**ឆៈ** ខ្ញុំមិនសូវយល់សារៈសំខាន់ហ្នឹងជ្រៅដែរទេ តែយល់ថារួមគ្នាទាំងប្រជាជនទូទាំងប្រទេស ហើយនិងអ្នកមុខអ្នកការនៅក្នុងប្រទេសតាមឋានៈទៅរួមគ្នា ចូលរួមការតស៊ូបាទ តែប៉ុណ្ណឹងបាទ។

**សៈ** បាទ អរគុណ។ តើលោកអាចបញ្ជាក់បន្ថែមទេ ទាក់ទិនទៅនឹងរចនាសម្ព័ន្ធនៃការបង្កើតរណសិរ្សនោះ។ តើរណសិរ្សហ្នឹងបង្កើតឡើងក្នុងទម្រង់នៃរចនាសម្ព័ន្ធបែបណាដែរ?

**ឆៈ** សូមជម្រាបជូន គឺសំណួររបស់លោកនេះ វាលើសសមត្ថភាពខ្ញុំ។ ខ្ញុំយល់មិនដល់ទេ ពី

ព្រោះកិច្ចការអស់ហ្នឹង អត់ដល់ទេ យល់មិនដល់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបន្តទៅសំណួរផ្សេងមួយទៀត តើលោកបានក្លាយជាសមាជិកសម្ព័ន្ធយុវជនបដិវត្តន៍ដែរឬទេ?

[០៩:៣៦:១៩]

**ឆ៖** ជម្រាបជូន ខ្ញុំបានក្លាយត្រង់គេហៅ "មហាជនចម្រើន"។ មហាជនចម្រើនហ្នឹង ដូចថាក្នុងចំណោមហ្នឹងវាគ្រាន់បើជាងគេបាទ ក្នុងការឃោសនា ក្នុងការអីចឹងបាទ។

**ស៖** បាទ តើមហាជនចម្រើនហ្នឹងមានន័យដូចម្តេចដែរបាទ?

**ឆ៖** មានន័យដូចបានជម្រាបអំមិញគឺថា សកម្មខាងឃោសនាអីចឹងទៅ ដាក់ឲ្យធ្វើអីធ្វើហ្នឹងទៅ។ ប៉ុណ្ណឹងបាទ។

**ស៖** បាទអរគុណ។ តើមហាជនចម្រើនហើយនិងសម្ព័ន្ធយុវជនបដិវត្តន៍ ខុសគ្នាយ៉ាងដូចម្តេច?

**ឆ៖** មហាជនចម្រើននេះគឺថ្នាក់ក្រោមបាទ។ ទាប ថ្នាក់ទាបលើប្រជាជនបន្តិច បាទ។

**ស៖** ចុះសម្ព័ន្ធយុវជនបដិវត្តន៍វិញបាទ?

**ឆ៖** សម្ព័ន្ធហ្នឹងតាមខ្ញុំយល់អាចថ្នាក់លើ ៗរបស់មហាជនចម្រើន។

**ស៖** ថ្នាក់លើបន្ទាប់ ឬក៏ថ្នាក់លើកម្រិតណាដែរបាទ?

**ឆ៖** សូមជម្រាបគឺមិនសូវច្បាស់ទេ។

[០៩:៣៨:០៥]

**ស៖** សូមអរគុណ។ អីចឹងមានន័យថា លោកអត់បានក្លាយជាសមាជិកសម្ព័ន្ធយុវជនបដិវត្តន៍ទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ក្នុងពេលនោះអត់បានក្លាយទៅទេបាទ។

**ស៖** អរគុណ។ តើលោកបាន-- ធ្លាប់បានក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** សូមជម្រាបជូន តាមខ្ញុំចាំ ខ្ញុំបានប្រកាសៗទទួលស្គាល់ថា ជាសមាជិកបក្សនុំងប្រហែលចុង៧៤ មិនចាំថ្ងៃ មិនចាំខែទេបាទ។

**ស៖** ហេតុអ្វីបានជាលោកចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** អាហ្នឹងមិនមែនខ្ញុំចង់ចូលទេ។ គឺស្រេចតែអង្គការនៅកន្លែងនុំងគេឃើញថា យើងមានលក្ខណៈសម្បត្តិ គេប្រកាសឲ្យអីចឹងទៅ យើងមិនអាចទៅសុំចូលអីបានទេបាទ។

[០៩:៣៩:៣៤]

**ស៖** អរគុណបាទ។ តើលក្ខណៈសម្បត្តិដែលត្រូវបំពេញដើម្បីឲ្យក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាក្នុងសម័យកាលនោះមានលក្ខណៈសម្បត្តិយ៉ាងដូចម្តេចខ្លះបាទ?

**ឆ៖** ជម្រាបជូនគឺ សូមជម្រាបជាបឋមថា ខ្ញុំក៏ចាំមិនអស់ដែរ តែខ្ញុំចាំគោលៗ គឺដូចខ្ញុំជម្រាបអំមិញ ការងារល្អ សីលធម៌ល្អដោយប្រៀបធៀប ហ្នឹងជាសំខាន់ ហើយស្មោះត្រង់នឹងការងារ ឲ្យធ្វើការងារអីធ្វើការងារហ្នឹងបាទ ក្រៅពីហ្នឹងមិនចាំ។

[០៩:៤០:២៣]

**ស៖** បាទអរគុណ។ លោកបានបញ្ជាក់អម្បាញ់មិញថា លោកមិនមែនចូលដោយស្ម័គ្រចិត្តខ្លួនឯងទេ គឺថ្នាក់លើ ឬក៏អង្គការជាអ្នកចាត់តាំងឲ្យលោកចូល។ សូមលោកមេត្តាបញ្ជាក់បន្តិច ថាតើអង្គការ ឬក៏ថ្នាក់លើដែលចាត់តាំងឲ្យលោកចូលហ្នឹង អស់លោកទាំងនោះគឺជាអ្នកណាខ្លះ? ខ្ញុំចង់បញ្ជាក់ ឲ្យលោកជួយបញ្ជាក់អំពីឈ្មោះ ថាតើអ្នកណាខ្លះដែលចាត់តាំង ឬក៏ណែនាំ ឬក៏តម្រូវឲ្យលោកចូលក្នុងសមាជិកបក្សកុម្មុយនីស្តកម្ពុជានាសម័យកាលនោះបាទ?

**ឆ៖** សូមជម្រាបជូនគឺ កន្លែងមួយៗគេមានសាខាគេ មិនមែនអង្គការលើអីទេ។ សាខាគេហ្នឹងគឺគេអ្នកទទួលខុសត្រូវផ្ទាល់ចំពោះកន្លែងនុំង ហើយគេមានប៉ុន្មាននាក់ ខ្ញុំក៏មិនដឹង ហៅ "សាខា១" ហើយសាខានុំង គេមានម្នាក់គេមកប្រាប់ថា យើងមានលក្ខណៈសម្បត្តិអាចធ្វើជាសមាជិកបាន តែប៉ុណ្ណឹង ឯថ្នាក់លើថ្នាក់អីគ្មានទេបាទ។

**ស៖** បាទអរគុណ។ មនុស្សម្នាក់ដែលមកជម្រាបលោកថា លោកអាចក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាបាន តើអ្នកនោះគឺជានរណា? ឈ្មោះអ្វីដែរបាទ? ហើយតើបច្ចុប្បន្ននេះគាត់នៅឯណាដែរ?

[០៩:៤១:៤៨]

**ឆ៖** អ្នកដែលមកនាំខ្ញុំហ្នឹង គ្រូបង្រៀនដែរ ហើយអ្នកឃោសនាដូចគ្នាដែរ។ គាត់ឈ្មោះ សេង តែគាត់ស្លាប់បាត់ហើយ បាទ។ គាត់អ្នកស្រុកធ្វើគ្រូបង្រៀន នៅសៀមរាប ដូចខ្ញុំដែរបាទ។

**ស៖** បាទ អរគុណ។ សាខា១ ដែលលោកបានបញ្ជាក់អំមិញ តើសាខានោះឈ្មោះអ្វីដែរ? ហើយស្ថិតនៅទីតាំងណាដែរបាទ?

**ឆ៖** សាខាគេចាត់តាំងតាមស្រុក ឬក៏តាមអង្គភាពឃោសនា។ ដូច្នេះ បើនៅអង្គភាពឃោសនា

ខាងទូទៅដូចខ្ញុំអ៊ីចឹង មកនៅម៉ុំ ឧបមាថាខ្ញុំនៅចល័តម៉ុំសៀមរាបអ៊ីចឹង សាខាគេនៅម៉ុំជីក្រែង សៀមរាបអីអ៊ីចឹងទៅ ហើយគេនៅត្រង់ហ្នឹង ហើយគេក៏ចល័តដែរ មិនមែននៅដដែលទេបាទ ពេលនុ៎ង។

[០៩:៤២:៥៥]

**ស៖** បាទ អរគុណ។ ខ្ញុំសូមសួរបន្តទៅទៀត មុនពេលគេទទួលយករូបលោក ចូលទៅក្នុងចលនាបដិវត្តន៍ តើលោកត្រូវចូលរួមរៀនសូត្រវគ្គនយោបាយ ឬក៏វគ្គបំពាក់បំប៉នគោលនយោបាយដែរឬទេ?

**ឆ៖** បាន រៀនសូត្រដែរបាទ រៀនតាមសាខាហ្នឹងបាទ។

**ស៖** តើគេបង្រៀនវគ្គនយោបាយនោះ កម្មវត្ថុនៃការបង្រៀនហ្នឹងផ្តោតទៅលើចំណុចណាខ្លះ? ហើយអ្វីទៅជាចំណុចសំខាន់ នៃការអប់រំវគ្គនយោបាយនោះ?

**ឆ៖** ចំណុចសំខាន់ ដូចខ្ញុំជម្រាបដដែល គេមិនអាចយកឯកសារទាំងដុលមកអប់រំខ្ញុំទេ។ គេដកស្រង់ឲ្យសមស្របនឹងសមត្ថភាពខ្ញុំ ហើយនិងការងាររបស់ខ្ញុំ ដូចជម្រាបអំមិញគឺ ចលនាប្រជាជនទូទៅបង្កើនផល ឧបត្ថម្ភខ្លួន។ ទីពីរ ឃោសនាប្រមូលកម្លាំងទៅសមរភូមិ នេះសំខាន់ ហើយក្រៅពីហ្នឹងវាជាត្រដំត្រសងទេ។ ខ្លឹមសារសំខាន់មានពីរដែលសំខាន់។

[០៩:៤៤:១៥]

**ស៖** បាទ អរគុណ។ តើគេបង្រៀនលោក នៅកន្លែងណាដែរ? ហើយគេបង្រៀនលោកប៉ុន្មានដង? ហើយការបង្រៀនហ្នឹង អ្នកណាជាអ្នកបង្រៀនលោកបាទ?

**ឆ៖** ចំនួនដងចាំអត់បាន។ អ្នកបង្រៀនគឺឈ្មោះ សេង អំមិញហ្នឹងហើយបាទ។ សេង គ្រូបង្រៀនអំមិញហ្នឹងបាទ។

**ស៖** បាទ គេបង្រៀនលោកនៅកន្លែងណាដែរបាទ?

**ឆ៖** សូមជម្រាបជូនថា ក្នុងសង្គ្រាមគេចល័តលោក ម្តងត្រង់នេះ ម្តងត្រង់នោះ ធ្វើម៉េចឲ្យតែមានសន្តិសុខ ព្រោះសង្គ្រាមបាទ។

[០៩:៤៥:១៣]

**ស៖** អរគុណ។ តើលោក សេង-- បើប្រៀបធៀបតួនាទីលោក សេង នៅក្នុងចលនាបដិវត្តន៍ ឬក៏ក្នុងបក្សកុម្មុយនីស្តកម្ពុជា តើលោក សេង មានតួនាទីត្រឹមណាដែរបាទ?

**ធ៖** ខ្ញុំមិនច្បាស់ដែរ។ តាមមើលដឹងតែថា ប្រធានសាខាៗ ប្រចាំកន្លែងនុ៎ងបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ហេតុអីបានគេចាត់តាំងលោក សេង ឲ្យមកបង្រៀនលោក ទាក់ទងនឹងវគ្គបំពាក់បំប៉នគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា?

[០៩:៤៦:០០]

**ធ៖** លោក សេង ហ្នឹង ខ្ញុំមិនយល់ជ្រៅទេ ប៉ុន្តែតាមខ្ញុំយល់ដោយត្រួសៗ គឺថាជាកម្មាភិបាលរបស់ខាងលើ។ ខាងលើកម្រិតណាក៏មិនដឹងទៀត ព្រោះវាច្រើនជាន់ច្រើនថ្នាក់ ហើយឲ្យទទួលខុសត្រូវកន្លែងនុ៎ង បាទ។

**ស៖** បាទ អរគុណ។ តើនៅពេលបើកវគ្គបណ្តុះបណ្តាល ឬក៏អប់រំរៀនសូត្រវគ្គនយោបាយក្នុងសម័យកាលនោះ គេបើវគ្គបណ្តុះបណ្តាលក្នុងមួយវគ្គ មនុស្សប៉ុន្មាននាក់ដែលចូលរួមរៀនវគ្គនយោបាយនោះ?

**ធ៖** កាលនោះគេរៀនចង្អៀតណាស់ គេមិនអាចរៀនច្រើនទេ យ៉ាងច្រើនបីនាក់ទៅប្រាំនាក់ ហើយគេមិនប៊ានចំហ មិនប៊ានយូរទេ ព្រោះខ្លាចរឿងសន្តិសុខ បាទ។

**ស៖** លោកអាចបញ្ជាក់បន្ថែមទេ គេរៀនចំនួនតិច បីទៅប្រាំនាក់ ចង្អៀត ពាក់ព័ន្ធនឹងបញ្ហាបារម្ភរឿងសន្តិសុខ។ តើរឿងបារម្ភរឿងសន្តិសុខហ្នឹងក្នុងន័យអ្វី? សន្តិសុខយ៉ាងដូចម៉េច? ពាក់ព័ន្ធនឹងសន្តិសុខហ្នឹង បារម្ភរឿងអី ចំណុចសំខាន់បាទ?

[០៩:៤៧:២៨]

**ធ៖** សន្តិសុខហ្នឹងវាទាក់ទងរឿងកប៉ាល់ហោះទម្លាក់ វាទាក់ទងរឿងបាញ់គ្នា សមរភូមិវាចាក់ស្រេះ វាគ្មានមុខគ្មានក្រោយ វាដូចធ្មេញរណារហ្នឹង ចាក់ទៅចាក់មក។ ហើយសន្តិសុខមួយទៀត មិនស្គាល់អ្នកណាជាអ្នកណា ព្រោះចលនាទូទាំងប្រទេសហើយ វណ្ណសិរ្សហើយ មិនដឹងជាអ្នកណាអ្នកណី។ អ៊ីចឹងគេប្រយ័ត្នខ្លួនអ៊ីចឹង បាទ។

**ស៖** បាទ សូមអរគុណ។ តើនៅពេលរៀនវគ្គនយោបាយនោះ អ្នកគ្រប់គ្រងវគ្គនយោបាយនុ៎ងមានបានចែកឯកសារអ្វីខ្លះជូនលោក? ឯកសារដែលទាក់ទងនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដូចជាលក្ខន្តិកៈបក្ស ឬក៏បទបញ្ជាផ្ទៃក្នុងរបស់បក្ស ឬក៏ឯកសារផ្សេងទៀតដែលមាន តើលោកមានបានទទួលឯកសារណាខ្លះដែរឬទេបាទ នៅក្នុងពេលទទួលការវគ្គបណ្តុះបណ្តាលរៀនសូត្រវគ្គនយោបាយនោះបាទ?

[០៩:៤៨:២៩]

**ឆ៖** កាលនោះគ្មានទេ មានតែកត់ត្រួសៗ ហើយឯកសារបើតាមខ្ញុំដឹងដូចគ្មានបោះពុម្ព បោះអីផង។ ដូច្នេះនិយាយតែមាត់ហ្នឹង។ កត់ អ្នកណាកត់បានកត់ អ្នកណាកត់មិនបានក៏ចងចាំទៅបាទ។

**សៈ** បាទ អរគុណ។ លោកមានធ្លាប់ឮគេនិយាយពាក្យថា “ទង់បដិវត្ត” ដែរឬទេបាទ?

**ឆ៖** រឿងទង់បដិវត្តហ្នឹងក្រោយទេលោក។ ជិតដល់ពេលសង្គ្រាម កងទ័ពវៀតណាមវ៉ៃចូលមកទេ។ ដូច្នេះខ្ញុំមិនច្បាស់លាស់ទេ គ្រាន់តែឮៗ តែមិនច្បាស់លាស់ក្រោយមក កាលនោះគ្មានទេ។

**សៈ** បាទ លោកឮពាក្យថា “ទង់បដិវត្ត” នៅគ្រាជិតរំដោះដោយកងទ័ពវៀតណាម តើលោកឮដោយមធ្យោបាយណា? ឬក៏លោកបានឃើញឯកសារហ្នឹងដោយផ្ទាល់ភ្នែក ឬក៏ឮគេថា? ហើយឮនៅពេលណា ឮនៅកន្លែងណាដែរបាទ?

[០៩:៤៩:៤៧]

**ឆ៖** អ្នកដែលមកបង្រៀន ឬអប់រំយើងតហ្នឹង គេដកស្រង់យកខ្លឹមសារហ្នឹងមក។ ដូច្នេះយើងមិនអាចដឹងថា តើឯកសាររូបរាងយ៉ាងម៉េចទេ គេដកស្រង់ឲ្យស្របនឹងសមត្ថភាពរបស់យើង និងការងាររបស់យើងបាទ។ ហ្នឹងដែលដឹងបានប៉ុណ្ណឹងបាទ។

**សៈ** ដូច្នេះមានន័យថាលោក សេង ឬក៏អ្នកបង្រៀនលោកវគ្គនយោបាយហ្នឹង គឺគាត់បង្ហាញថាឯកសារខ្លះ ឬក៏ខ្លឹមសារដកស្រង់ចេញពីខ្លឹមសារនៃទង់បដិវត្ត។ តើមែនឬទេបាទ?

**ឆ៖** អត់បានបង្ហាញទេ គេកត់ត្រា យកមកដូចសៀវភៅអីចឹង។

**សៈ** បាទ តើលោក សេង មានបានពន្យល់ពាក់ព័ន្ធនឹងទង់-- ឯកសារទង់បដិវត្តដែរឬទេ?

**ឆ៖** គេជម្រាបយើងថា ជាខ្លឹមសារនេះដកស្រង់ តែប៉ុណ្ណឹង។ ឯឯកសារនុ៎ងមិនមាន។

**សៈ** បាទ ខ្ញុំសូមអរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចអំពីមុខងារជាក់លាក់របស់លោកនៅក្នុងពេលលោកចូលរួមក្នុងចលនាបដិវត្តន៍។ បាទ គឺនៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ទៅ ចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ៧៥ ទៅ តើលោកមានមុខងារជាក់លាក់អ្វីនៅក្នុងចលនាបដិវត្តន៍ បាទ?

[០៩:៥១:៤៧]

**ឆ៖** សូមជម្រាបជូន មុខងារមូលដ្ឋានរបស់ខ្ញុំដដែល គឺនៅតែខាងឃោសនា អប់រំ ដោយផ្អែកលើមូលដ្ឋានខ្ញុំចេះអក្សរ ចេះលេខ ចេះនិយាយអី អីចឹងដដែល។ រួចហើយតួនាទីនេះចេះតែមករហូតមកដល់៧៥មក។ បាទ ទើបចុងក្រោយបានខ្ញុំត្រូវដកចេញពីមូលដ្ឋានមកនៅក្រសួងការបរទេស។ ដកមក

នេះយកមកដាក់ក្នុងប្រអប់មួយហៅថា ពិធីការ។ តែក្រុមពួកអី ខ្ញុំមិនច្បាស់លាស់ទេ។ ដាក់ហើយឱ្យខ្ញុំជូនភ្ញៀវកម្រិតទាប កម្រិតបុគ្គល មិនមែនគណៈប្រតិភូទេ។ រួចហើយខ្ញុំជូនពីភ្នំពេញទៅសៀមរាបនេះតួនាទី។ ទៅម្តង ប្រហែលប្រាំពីរថ្ងៃ ឬលើស ព្រោះផ្លូវក្រោយសង្គ្រាមពិបាក។ ប៉ុណ្ណឹងទេ បាទៗ។

**ស៖** ខ្ញុំសូមសួរបន្តទៀត ហេតុអ្វីបានជាគេដកលោកពីក្នុងនាមជាអ្នកឃោសនានៅតាមតំបន់តាមខេត្ត មកធ្វើជាអ្នកធ្វើការងារនៅក្នុងក្រសួងការពារជាតិ។ តើមានគោលបំណងអ្វីសំខាន់បាទ?

**ឆ៖** សូមបញ្ជាក់ជូនថាមិនមែនការពារជាតិទេ ការបរទេស បាទ។ ហើយហេតុផលដដែល គឺថាខ្ញុំចេះអក្សរ ចេះអីអឺចឹង យកមកខាងណេះស្រួលជាងនៅខាងណោះ ហើយស្របជាង។ តែទីពីរជ្រៅជ្រះជាងហ្នឹងទៀត ខ្ញុំមិនអាចដឹង ពីព្រោះវាវិន័យវាខ្ពស់ លាក់ការណ៍សម្ងាត់វាខ្ពស់ រួចម្នាក់ៗមិនអាចសួរនាំទេ ឱ្យតែខាងលើថាទៅណាទៅហ្នឹងហើយ បាទ។

[០៩:៥៤:១៣]

**ស៖** អរគុណបាទ។ តើលោកបានធ្វើជាអ្នកឃោសនាជាមួយនឹងប្រជាជននៅតាមភូមិ នៅតំបន់ណាខ្លះដែរ? ហើយនៅខេត្តសៀមរាប តើលោកមានធ្លាប់ធ្វើទេកាលសម័យនោះ?

**ឆ៖** ធ្វើនៅសៀមរាប ធ្វើលួចលាក់ទេ មិនចំហទេបាទ។ បើធ្វើនៅ ដល់ក្រោយដែលសង្គ្រាមកាន់តែធំឡើងៗ អាហ្នឹងជាមួយប្រជាជនតាមមូលដ្ឋាន។ កន្លែងដែលមានការប្រយុទ្ធគ្នា ក្រោយប្រយុទ្ធគ្នាអីហ្នឹង។ ឃោសនាទៅភូមិ ដែលមិនទាន់បានរំដោះ បាទ ប៉ុណ្ណឹង។

[០៩:៥៥:០០]

**ស៖** បាទនៅខេត្តសៀមរាប តើលោកប្រើពេលអស់ប៉ុន្មានថ្ងៃខែឆ្នាំ ក្នុងនាមជាអ្នកឃោសនាជាមួយប្រជាជនបាទ?

**ឆ៖** ខ្ញុំចាំមិនអស់ទេ តែតាមខ្ញុំមើលដល់៧៤ សង្គ្រាមផ្ទុះខ្លាំង បានខ្ញុំចុះមកខាងនេះវិញ។ មកខាងជិតភ្នំពេញវិញបាទ។ ឯថ្ងៃខែពិតប្រាកដមិនច្បាស់ទេបាទ។

**ស៖** ខ្ញុំសូមសួរទៀតថា នៅក្នុងខេត្តសៀមរាបហ្នឹង តើលោកបានឃោសនាហ្នឹង ភាគច្រើននៅស្រុកណា? នៅតាមតំបន់ណា? នៅក្នុងខេត្តសៀមរាប វាមានស្រុក ហើយនិងតំបន់?

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធាន ដោយសារតែអ្នកបកប្រែខាងភាសាបារាំងអត់ឮបាទ។ ដូច្នេះ សូមជួយជម្រាបខាងអ្នកបកប្រែ។ សូមអរគុណបាទ។

[០៩:៥៦:០៦]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងអង្គភាពខាងបកប្រែ មានបញ្ហាការបកប្រែភាសា។

**លោក ច័ន្ទ តារាស្មី៖**

អង់គ្លេសក៏អត់ដែរបាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អាចចាប់ផ្តើមបន្តតំណាងសហព្រះរាជអាជ្ញាជាតិ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតសួរសំណួរទៅលោកសាក្សីជាបន្តទៀតបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សីសូមមេត្តាឆ្លើយសំណួររបស់ខ្ញុំអម្បាញ់មិញ ថាតើលោកបានធ្វើជាអ្នកឃោសនាជាមួយប្រជាជននៅខេត្តសៀមរាប។ ខ្ញុំចង់ដឹងច្បាស់ថា ភាគច្រើននៅក្នុងស្រុកណា ភូមិឃុំស្រុកណាភាគច្រើនដែលលោកបានចុះទៅឃោសនាជាញឹកញាប់។ ហើយនៅពេលនោះ លោកប្រើពេលប្រហែលជាប៉ុន្មាន? បាទ សូមអរគុណ។

**ឆ៖** ភាគច្រើនស្រុកជីក្រែក បាទ។ ហើយគេហៅឃុំកំពង់ក្ដី។ ដឹងប៉ុណ្ណឹងបាទ។

**ស៖** លោកប្រើពេលប៉ុន្មានដែរនៅស្រុកជីក្រែកហ្នឹងបាទ?

**ឆ៖** ប្រហែលជាជាងមួយឆ្នាំដែរបាទ។

**ស៖** បាទ អរគុណ។ ហេតុអីបានជាលោកជ្រើសរើសគោលដៅស្រុកជីក្រែង ធ្វើមូលដ្ឋានញឹកញាប់នៅក្នុងការឃោសនាជាមួយប្រជាពលរដ្ឋ?

**ឆ៖** សូមជម្រាបជូនថា ខ្ញុំមិនមែនជាអ្នកជ្រើសរើសទេ គឺនៅកន្លែងណា កន្លែងហ្នឹង។ ខ្ញុំធ្វើគ្រូបង្រៀននៅកន្លែងហ្នឹង ធ្វើកន្លែងហ្នឹង។

[០៩:៥៨:០៧]

**ប្រធានអង្គជំនុំ៖**

លោកតំណាងអយ្យការសូមកំណត់នូវកាលវេលាឲ្យបានច្បាស់ក្នុងការតាំងសំណួរ ពីព្រោះមាន

កាលវេលាប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា ហើយនិងកាលវេលាដែលពាក់ព័ន្ធនឹងការចោទប្រកាន់ ១៧ មេសា ៧៥ រហូតដល់១៦ មករា ៧៩។ អ៊ីចឹងកាលណាសួរទៅ មិនបញ្ជាក់ពេលវេលាច្បាស់លាស់ហ្នឹង គឺអាចមានការភ័ន្តច្រឡំគ្នារវាងទីតាំងដែលគាត់ទៅធ្វើសកម្មភាព។

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** នៅក្នុងរយៈពេលដែលខ្ញុំបានសួរលោក គឺ១៧ មេសា ឆ្នាំ៧៥-- ចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ៧៥មក តើក្នុងនាមលោកជាអ្នកឃោសនានាសម័យកាលនោះ អ្នកណាជាអ្នកណាជាអ្នកគ្រប់គ្រងលោកពីលើផ្ទាល់តែម្តង?

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន អ្ហឺ!ខ្ញុំឃោសនាពេលនោះ គឺដូចបានជម្រាបថា ប្រធានសាខាហ្នឹងឈ្មោះសេង។ បាទ អ្នកហ្នឹងហើយ អ្នកគ្រប់គ្រង។

**ស៖** បាទ អរគុណបាទ។ តើអ្នកណាជាមេដឹកនាំសំខាន់បំផុតនៅភូមិភាគសៀមរាបបាទ?

**ឆ៖** អត់ស្គាល់ទេបាទ។

[០៩:៥៩:៥២]

**ស៖** បាទ សូមអរគុណ។ តើពេលណាទៅទើបកងកម្លាំងបដិវត្តន៍រំដោះបានតំបន់ជុំវិញទីប្រជុំជនខេត្តសៀមរាប?

**ឆ៖** រយៈពេលវាយូរពេកហើយជាង៣០ឆ្នាំហើយ ហើយខ្ញុំក៏មិនមែននៅខាងក្នុងឋានៈជាមេទ័ព ខ្ញុំមិនចាំទេ។ ខ្ញុំជាឃោសនិក។

**ស៖** បាទ សូមអរគុណ។ នៅក្នុងអត្ថន័យនៃការឃោសនាជាមួយប្រជាពលរដ្ឋហ្នឹង តើលោកមានបានបញ្ចូលមនោគមន៍វិជ្ជាបក្សកុម្មុយនីស្តកម្ពុជាទៅក្នុងការឃោសនា ឬក៏លោកគ្រាន់តែពន្យល់អំពីការងារផ្សេងៗក្រៅពីការងារបក្ស? សូមលោកបញ្ជាក់បន្តិចបាទអំពីចំណុចនេះ? ឬក៏លោកអូសទាញឲ្យប្រជាពលរដ្ឋចូលទៅក្នុងកងកម្លាំងបដិវត្តន៍ ឬក៏យ៉ាងម៉េចបាទ?

[១០:០១:០២]

**ឆ៖** ពេលនុ៎ងគេអត់បានយកឈ្មោះបក្សអីទេ។ គេយកតែឈ្មោះអង្គការទេ ដូច្នេះគេភ្ជាប់

ខ្លឹមសារទៅតាមឈ្មោះ តាមភាគថា អង្គការបាទ។ អត់មានឈ្មោះបក្សទេ។ អង្គការនុ៎ងវាមានន័យប៉ុណ្ណឹង។ ន័យបដិវត្តន៍ ឬន័យយ៉ាងម៉េចមិនដឹងក្រៅតែពីអង្គការៗ អង្គការទូទៅតែម្តងបាទ។

**សៈ** តើអង្គការមានសន្យាអ្វីខ្លះជាមួយនឹងប្រជាជនទេ នៅពេលដែលឃោសនាអ៊ីចឹង តើសន្យាថា នៅពេលដែលអង្គការបានសម្រេចគោលដៅរបស់អង្គការ តើមានសន្យាជាមួយប្រជាជនថានឹងធ្វើអ្វីខ្លះ ឬក៏ជួយប្រជាពលរដ្ឋតាមរូបភាពអ្វីខ្លះនៅពេលដែលអង្គការបានសម្រេចគោលដៅរបស់ខ្លួន នៅពេលអនាគតនោះ នៅពេលដែលលោកឃោសនាជាក់ស្តែងនោះបាទ?

**ឆៈ** សំណួររបស់លោកនេះវាជាន់នឹងការតបឆ្លើយរបស់ខ្ញុំដដែលទេ។ ដូចថាខ្លឹមសារវ៉ៃចក្រពត្តិអាមេរិក ហើយទីពីរ លើកស្ទួយជីវភាពប្រជាជន ផ្សារភ្ជាប់ប្រជាជនទៅសមរភូមិបាទ។ ហើយខ្លឹមសារសំខាន់ប៉ុណ្ណឹងបាទ។

[១០:០២:២៩]

**សៈ** បាទសូមអរគុណ។ ខ្ញុំសូមបន្តសំណួរទាក់ទិនទៅនឹងតំបន់១៥ ដែលជាភូមិភាគពិសេសហើយក្រោយមកបានក្លាយជាតំបន់៣២ នៅភូមិភាគបស្ចិមវិញបាទ។ សំណួរខ្ញុំគឺផ្តោតទៅលើចំណុចនេះបាទ។ សូមលោកបញ្ជាក់បន្តិច តើគេបញ្ជូនលោកទៅណាទៀតបន្ទាប់ពីខេត្តសៀមរាប? អំមិញលោកបញ្ជាក់ថា គេយកលោកមកក្រសួងការបរទេស ហើយចេញពីក្រសួងការបរទេស តើគេមានបញ្ជូនលោកទៅណាទៀតដែរឬទេបាទ?

**ឆៈ** សូមជម្រាបជូន គឺចេញពីក្រសួងការបរទេសនេះ គ្មាននរណាបញ្ជូននរណាទៅណាទៀតទេ។ វាចូលដល់ “ខ” នាំគ្នារៀសសឹកហើយ។ នរណារៀសទៅមុនបានទៅច្រកណាទៅតាមលទ្ធភាព។ ហើយរៀសសឹកហ្នឹងទៅលិច ទៅព្រំដែនថៃបាទ។ អស់ហើយបាទ។

[១០:០៣:៣៧]

**សៈ** បាទ សូមអរគុណលោក នី កន។ សូមឲ្យលោកមេត្តាបញ្ជាក់បន្ថែមបន្តិច ងាកទៅក្រោយបន្តិច ទាក់ទិនទៅនឹងបញ្ហានៃការដែលលោកធ្វើការនៅខេត្តសៀមរាប បន្ទាប់មកគេបញ្ជូនទៅណាផ្សេងក្រៅពីធ្វើការនៅសៀមរាបហ្នឹង មុននឹងទៅក្រសួងការបរទេសដែរឬទេ? តើមានបញ្ជូនលោកទៅធ្វើការនៅកន្លែងណាផ្សេងមុននឹងបញ្ជូនទៅការបរទេសដែរឬទេបាទ?

**ឆៈ** ជម្រាបជូន គឺពេលដែលខ្ញុំចប់ត្រូវដកពីសៀមរាបមក ខ្ញុំចុះមកតំបន់១៥។ តំបន់១៥ហ្នឹងក៏នៅតែឃោសនាអប់រំដដែល។ ឃោសនាអប់រំប្រជាជននៅជាប់នឹងសមរភូមិ ខ្លឹមសារដដែល

បង្កើនផល វ៉ៃចក្រពត្តិបាទ។

**ស៖** បាទសូមអរគុណ។ តំបន់១៥ហ្នឹងមានន័យដូចម្ដេចបាទ?

**ឆ៖** លេខហ្នឹងជាលេខអង្គការដាក់តែ អង្គការថ្នាក់ណា អីថ្នាក់ណាមិនដឹង។ ជាលេខសម្ងាត់ គេអីចឹងតែម្ដង ហៅថា ១៥ បាទ។ ន័យម៉េចទៀតអត់យល់។

[១០:០៥:០៣]

**ស៖** សូមអរគុណ។ តំបន់១៥ហ្នឹង ស្ថិតនៅទីតាំងណាដែរ? បាទ ហើយតំបន់១៥ហ្នឹងនៅក្នុងនោះគេធ្វើសកម្មភាពអ្វីខ្លះ?

**ឆ៖** តំបន់១៥ តាមខ្ញុំចាំ គឺតំបន់សមរភូមិពាយព្យ ភ្នំពេញ ប៉ែកម្ដុំយើងឧដុង្គនេះ។ សកម្មភាពគេមានតែវ៉ៃប៉ុណ្ណឹង។ ហើយខ្ញុំចាំតែអប់រំពីក្រោយហ្នឹងទៅ។ ជាបុគ្គលមួយណា មិនមែនជាទូទៅទេ។ បុគ្គលមួយបាទ។

**ស៖** តើលោកមកដល់ភូមិភាគពិសេសនៅពេលណាដែរ? ភូមិភាគពិសេសដែលលោកបានបញ្ជាក់អម្បាញ់មិញហ្នឹង តើលោកមកដល់នៅពេលណាដែរបាទ?

**ឆ៖** តាមខ្ញុំចាំ មិនសូវជាច្បាស់ទេ ប្រហែលចុង៧៤។

**ស៖** អរគុណ។ តើលោកនៅកន្លែងណានៅពេលនោះ?

**ឆ៖** ខ្ញុំចល័ត។ ចល័តចន្លោះហ្នឹង។ ចន្លោះម្ដុំដែលហៅឧដុង្គហ្នឹង ម្ដងអានេះ ម្ដងអានោះទៅ។ តាមដំបូក។

[១០:០៦:៣៥]

**ស៖** ហេតុអ្វីបានជាលោកចល័តម្ដងទៅកន្លែងនេះ ម្ដងទៅកន្លែងនោះ? តើមានហេតុផលអ្វីខ្លះទៅបាទ?

**ឆ៖** ហេតុផលវាតែមួយម៉ាត់គត់ គឺសង្គ្រាម។ អីចឹងប្រជាជនផ្ដុំត្រង់ណា ទៅត្រង់ហ្នឹងបាទ។ ព្រោះប្រជាជនក៏ភៀសសឹកដែរណ៎ាបាទ។ ភៀសពីនេះ ពីភូមិនេះទៅភូមិនេះៗ។

**ស៖** បាទ អរគុណ។ តើលោកបានរស់នៅជិតមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាដែរឬទេ?

**ឆ៖** ដូចបានជម្រាបដដែលដែរ គឺលាក់ការណ៍សម្ងាត់នុំងវាខ្ពស់ណាស់។ វិន័យនោះ វាវិន័យដែកថែប។ ហើយខ្ញុំបានជម្រាបអម្បាញ់មិញ ខ្ញុំទទួលបន្ត។ ដូច្នេះ មិនអាចបានទៅជិតអីទេ បាទ។

**សៈ** បើសិនជាប្រៀបធៀបអំពីកម្រិតថ្នាក់ តើលោកស្ថិតនៅក្នុងកម្រិតថ្នាក់ទីប៉ុន្មាន? ឧបមាថា លោករាប់ពីមួយដល់ដប់ តើលោកអាចស្ថិតក្នុងកម្រិតថ្នាក់ទីប៉ុន្មាន? ធ្លាប់ធ្វើកិច្ចការ ឬក៏ទំនាក់ទំនងជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាហ្នឹង លោកអាចបញ្ជាក់អំពីកម្រិតថ្នាក់ពីមួយដល់ដប់ តើនៅក្នុងកម្រិតថ្នាក់ទីប៉ុន្មាន? ជាឧទាហរណ៍បាទ។

**ធៈ** ដូចកំណត់កម្រិតមិនបានទេ។ ពីព្រោះគេហៅថ្នាក់វណសិរ្ស។ ថ្នាក់វណសិរ្សហ្នឹងវាមានន័យទូលំទូលាយបាទ។ ទូលាយ វាជាកម្លាំងទូលាយ។ ដែលពេលដែលឃោសនាហ្នឹង ហើយដល់ក្រោយមក វាកម្រិតហ្នឹងខ្ញុំមិនអាចកំណត់បានដែរ មិនដឹងជាកម្រិតប៉ុន្មាន។ ពីព្រោះទីមួយប៉ុន្មាន ទីពីរប៉ុន្មានវាមិនច្បាស់។

[១០:០៨:៥០]

**សៈ** បាទសូមអរគុណ។ ខ្ញុំសូមបន្តសំណួរទៀត។ មុនពេលរំដោះភ្នំពេញ មានការច្របូកច្របល់ចលនាតាមសមរភូមិ តាមតំបន់ផ្សេងៗ តើលោក-- នៅពេលដែលលោកស្ថិតនៅក្នុងតំបន់នីមួយៗហ្នឹង លោកឃើញសកម្មភាព មានសកម្មភាពជ្រួលច្របល់អ្វីខ្លះ? ជាពិសេសតំបន់ភូមិភាគ១៥ ដែលបានក្លាយជាតំបន់ ដែលបានក្លាយជាតំបន់៣២នុ៎ង តើលោកឃើញសកម្មភាពការរស់នៅរបស់ប្រជាពលរដ្ឋហ្នឹង ស្ថិតក្នុងស្ថានភាពបែបណា?

**ធៈ** សូមជម្រាបជូន សកម្មភាពដែលខ្ញុំឃើញ ខ្ញុំឃើញតែប្រជាជនដែលទទួលបន្ទុកក្រោយពីសង្គ្រាមចប់ភ្លាមៗនោះ ត្រូវទទួលបន្ទុកចិញ្ចឹមប្រជាជនភៀសសឹក ឬចេញពីក្រុង។ អាហ្នឹងឃើញប៉ុណ្ណឹង។ គឺថា បន្ទុកនេះត្រូវចែកគ្នារស់ ចិញ្ចឹមគ្នាទៅវិញទៅមក។ អ្នកដែលគ្មានអី ដល់អ៊ីចឹងទៅឃើញអាហ្នឹងដែលច្បាស់។

[១០:១០:០៩]

**សៈ** បាទ ខ្ញុំសូមចូលសំណួរដែលទាក់ទិនតំបន់១៥ មុនខែមីនា ឆ្នាំ១៩៧៤។ លោកបានបញ្ជាក់អំមិញថា លោកបានចូលរួមក្នុងភូមិភាគពិសេសតំបន់១៥ មុនខែមីនា ឆ្នាំ១៩៧៤។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់សំណួរដូចតទៅនេះ សូមលោកមេត្តាឆ្លើយ តើលោកដឹងទេថា ពេលណាទៅទីប្រជុំជនឧដុង្គត្រូវបានដណ្តើមពីកងកម្លាំងលន់ នល់?

**ធៈ** ជម្រាបជូន អត់ចាំទេបាទ។

**សៈ** អរគុណ។ តើលោកនៅតំបន់នោះដែរឬទេ? ឬក៏ទីនោះ មានការរំដោះនៅពេលណាដែរ?

**ឆ៖** ខ្ញុំចល័តទៅ ចល័តមក នៅម្តុំហ្នឹងបាទ។ នៅចន្លោះខដុង្គ ហើយនិងមានស្រុកមួយទៀត ដូចជាពញាឮ បាទ។

**ស៖** បាទសូមអរគុណ។ តើកងកម្លាំងបដិវត្តន៍ធ្វើអ្វីខ្លះ ក្រោយពេលរំដោះទីក្រុងភ្នាម? តើលោកមានចាំទេ បាទ?

[១០:១១:៣៧]

**ឆ៖** ខ្ញុំចាំ បានច្បាស់ត្រង់ កងទ័ពមករួមជាមួយប្រជាជនធ្វើស្រែ ចម្ការ លើកទំនប់ ច្បាស់។

**ស៖** សូមលោកបញ្ជាក់កន្លែងហ្នឹងបន្តិច តើថ្នាក់ណាសម្រេចឲ្យកងទ័ពចូលរួមជាមួយប្រជាជនដើម្បីលើកទំនប់? តើមានបញ្ជាពី-- ឬក៏ការណែនាំពីថ្នាក់ណាដែរ? ហេតុផលអីបានគេឲ្យធ្វើដូច្នេះ បាទ?

**ឆ៖** ជម្រាបជូន ថ្នាក់ហ្នឹង គឺមានតែថ្នាក់លើហ្នឹងហើយ។ បាទ គេបញ្ជាក់ថា អង្គការលើ ហើយហេតុផលដដែល។ អនុវត្តនយោបាយឯករាជ្យ ខ្លួនឧបត្ថម្ភខ្លួន មិនពឹងពាក់ដទៃ បាទ។

**ស៖** បាទ អរគុណ។ តើប្រជាជនខដុង្គត្រូវបានគេជម្លៀសចេញដែរឬទេបាទ?

**ឆ៖** តាមចាំ ដូចអត់ទេ បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរក្នុងរយៈកាលអំឡុងពេលមុនខែមីនា ឆ្នាំ១៩៧៤ ដដែល។ សំណួរខ្ញុំគឺក្នុងបរិបទហ្នឹងដដែល សូមលោកមេត្តាជួយឆ្លើយបន្ត។ តើគេបញ្ជូនប្រជាជនទាំងនោះ ទៅកន្លែងណាដែរ? គឺប្រសិនបើមានការជម្លៀស ឬក៏មានការផ្លាស់ទីប្រជាជនមួយចំនួនតូច ពីកន្លែងមួយទៅកន្លែងមួយ តើលោកអាចបញ្ជាក់បានទេ តើគេបញ្ជូនប្រជាជនទៅកន្លែងណា?

**ឆ៖** ខ្ញុំចាំត្រួសៗ គឺគេបញ្ជូនទៅតាមស្រុកទេសរបស់ប្រជាជន។ ទៅតាមស្រុកភូមិរបស់ប្រជាជន តែប៉ុណ្ណឹងបាទ។ ហើយមួយខទៀត ទៅតាមការជ្រើសរើសរបស់ប្រជាជន មានសាច់ មានឈាម នៅឯណា គេទៅហ្នឹង។

[១០:១៣:៤៧]

**ស៖** បាទ សូមអរគុណ។ តើមានមូលហេតុអ្វីសម្រាប់ជាភស្តុតាងពន្យល់ប្រជាជនឲ្យយល់អំពីការជម្លៀសនេះ? ឲ្យប្រជាជនយល់ថា ការជម្លៀសគាត់ គឺមូលហេតុអី? តើលោកអាចបញ្ជាក់បានទេ បាទ?

**ឆ៖** បញ្ហានេះខ្ញុំយល់មិនដល់ទេ សូមជម្រាបលោក តែខ្ញុំដឹងតែត្រួសៗ ថាដើម្បីការពារសន្តិសុខ ខ្លាចកប៉ាល់ហោះអីហ្នឹងមកទម្លាក់ទៀត។ តែជ្រៅជ្រះអត់យល់ទេ។

**សៈ** បាទ សូមអរគុណ។ តើប្រជាជនមានការភ័យខ្លាចអំពីការខ្វះខាតស្បៀងអាហារដែរឬទេ?

**ឆ៖** ធម្មតា ភ័យហើយ ព្រោះបញ្ហាក្រពះ តែអ្នកដែលហៅថា នៅកន្លែងចាស់នុំង ខ្ញុំឃើញខិតខំដែរ ខិតខំយកមកចែករំលែកគ្នាដែរ។ តែតាមមើលមិនគ្រប់ទេ ព្រោះវាជុក ដែលហៅថា វាជុញមក ហើយបាទ។

[១០:១៥:២១]

**សៈ** បាទ អរគុណ។ ការចែករំលែកស្បៀងអាហាររវាងប្រជាជនទៅប្រជាជនហ្នឹង តើមានការណែនាំ ឬមានការបង្ខិតបង្ខំ ឬក៏ដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋដោយផ្ទាល់បាទ?

**ឆ៖** នេះជាក្រឹត្យក្រមធម្មតា គឺត្រូវមានណែនាំហើយ។ គេហៅ អង្គការណែនាំបាទ។

**សៈ** សូមអរគុណ។ ប្រជាជនមានការភ័យខ្លាច ទាក់ទិននឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក លោកបានបញ្ជាក់អម្បាញ់មិញ ដែលជាហេតុធ្វើឲ្យមានការជម្លៀសប្រជាជនចេញពីតំបន់មួយទៅតំបន់មួយ។ ខ្ញុំចង់ដឹងថា តើការភ័យខ្លាចនេះ តាមលោកចងចាំមានការភ័យខ្លាចរហូតដល់ពេលណាដែរបាទ ទើបការភ័យខ្លាចហ្នឹងចប់?

[១០:១៦:២២]

**ឆ៖** ការភ័យខ្លាចហ្នឹង តាមខ្ញុំមើលចប់នៅពេលសង្គ្រាមចប់ហ្នឹងហើយ។ ពេលដែលសង្គ្រាមនៅសល់កន្ទុយហ្នឹង ភ័យរហូតហើយ ផ្ទះណាក៏មានត្រង់សេដែរបាទ។

**សៈ** បាទ សូមអរគុណ។ តើលោកមានបានដឹង ឬក៏ចងចាំទេថា នៅក្នុងអំឡុងមុនខែមីនា ឆ្នាំ៧៤ នៅតំបន់ឧដុង្គហ្នឹង តើមានការបែងចែកវណ្ណៈ ឋានៈប្រជាជនដែរឬទេ? ឬក៏មានការរើសអើងកើតឡើងដែរឬទេ ដែលជំរុញឲ្យមានការកំណត់មុខសញ្ញាជាខ្មាំង ខ្មាំងធម្មតា ឬក៏ខ្មាំងមានសក្តានុពល? បាទ សូមលោកបញ្ជាក់ចំណុចនេះបាទ។

**ឆ៖** ខ្ញុំអ្នកទទួលឃោសនាអប់រំ ដូចមិនបានទទួលការលម្អិតអ៊ីចឹងទេ។ បានទទួលដូចខ្ញុំបានជម្រាបដដែលបាទ។ ព្រោះខ្ញុំស្ថិតនៅក្នុងអ្នកឃោសនាអប់រំ។ ហើយក៏មាន “ខ” ដែលធ្វើម៉េចឲ្យចងក្រុងសាមគ្គីគ្នាដែរ។ គ្រប់ពេលវេលាហ្នឹងដែលខ្ញុំនិយាយថា ផ្នែករួមផ្សំហ្នឹង ខ្ញុំមិនបានជម្រាបអស់ហ្នឹង ក៏បាននិយាយថា រួបរួមគ្នាចងក្រុងសាមគ្គីគ្នា បានអីចែកគ្នាហូប។ ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណលោក នី កន។ ខ្ញុំសូមបន្តសំណួរទាក់ទងទៅនឹងចំណុចមួយទៀត។ ខ្ញុំចង់ដឹងថា តើលោកបានចូលរួមក្នុងភូមិភាគពិសេស១៥ ដែលគេហៅថា ភូមិភាគពិសេស១៥ ហ្នឹងនៅចន្លោះខែមីនា ឆ្នាំ១៩៧៤ និងខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

[១០:១៨:៣១]

**ឆ៖** ខ្ញុំបានទៅហ្នឹងក្រោយទេ ពីព្រោះទម្រាំគេរៀបចំតំបន់១៥ហ្នឹងចប់ បាន១ទៅ។ តំបន់១៥ហ្នឹងវាជាតំបន់ក្ដៅណាស់ សមរភូមិក្ដៅ។ ដូច្នេះ ត្រូវរៀបចំឡើងវិញទាំងអស់ តាំងពីប្រជាជន តាំងពីទាហានអីចុះឡើង។ ដូច្នេះទម្រាំចប់ហ្នឹងបានគេគួបផ្សំ ទៅខាងនុ៎ងបាទ ដូច្នេះខ្ញុំមិនចាំថ្ងៃមិនចាំខែដែរ។

**ស៖** អ៊ីចឹងមានន័យថា មិនដឹងថាលោកចូលក្នុងចន្លោះឆ្នាំ៧៤ ដល់ ៧៥ ហ្នឹង ឬក៏យ៉ាងម៉េច? ឬក៏អត់ទេ ឬក៏ក្រោយ៧៥ បានលោកចូលក្នុងតំបន់ភូមិភាគពិសេស១៥ហ្នឹង?

**ឆ៖** ខ្ញុំមកចុង៧៤ បាទ។ ហើយចុះមកពេលហ្នឹងនៅប្រយុទ្ធគ្នានៅឡើយទេ។ រួចហើយបានចប់១ហើយបានរៀបចំ បានខ្ញុំបានចូលរួមចន្លោះចុង៧៤ ៧៥ បាទ។

**ស៖** បាទ សូមអរគុណ។ តើតំបន់ពិសេស១៥ ក្រោយមកបានត្រូវបានគេបង្រួមបញ្ចូលឲ្យទៅក្នុងភូមិភាគដោយឡែកណាមួយដែរឬទេ?

[១០:២០:១៦]

**ឆ៖** សង្គ្រាមចប់បានគេបញ្ចូលតំបន់១៥ ពីដើមហៅថា នៅក្នុងភូមិភាគពិសេស ទៅជានៅក្នុងតំបន់៣២បាទ។ ហើយតំបន់៣២នេះ តាមខ្ញុំចាំគឺនៅក្រោមភូមិភាគបស្ចិមបាទ។

**ស៖** បាទ អរគុណ។ លោកអាចបញ្ជាក់បានទេថា ការដាក់បញ្ចូលតំបន់១៥នេះទៅក្នុងភូមិភាគពិសេសនោះ បានកើតឡើងនៅក្នុងឆ្នាំណាពិតប្រាកដ?

**ឆ៖** តាមចាំអ្ហ៎! តាមខ្ញុំចាំ ប្រហែលជាចុង៧៥ហើយ ពេលចប់ហើយនិយាយឲ្យចំទៅ គឺពេលចប់សង្គ្រាមបាន១គេបញ្ចូលបាទ។

**ស៖** បាទ អរគុណ។ លោកមានដឹងទេថា ហេតុអីបានគេបញ្ចូលយ៉ាងដូច្នេះបាទ?

**ឆ៖** ខ្ញុំយល់មិនដល់ដែរ តែតាមមើលទាក់ទងរឿងគ្រប់គ្រង។ កាលសង្គ្រាមគេបំបែកឲ្យល្អិតដល់ចប់សង្គ្រាមគេប្រមូលឲ្យស្រួលគ្រប់គ្រង តាមខ្ញុំយល់ណ៎ាបាទ។

**ស៖** បាទ សូមអរគុណ។ កាលពីពេលដែលលោកកំពុងធ្វើការនៅក្នុងភូមិភាគពិសេស គឺតំបន់១៥ហ្នឹង តើសហករណ៍កើតមានតាំងពីពេលណាមក? លោកអាចដឹងទេបាទ?

[១០:២១:០៩]

**ឆ៖** នៅក្នុងតំបន់១៥ពេលនោះ មិនមានសហករណ៍ទេ មានក្រុមបង្កើនផល ក្រុមបង្កបង្កើនផលបាទ។ ក្នុងពេលសង្គ្រាមអត់មានទេ។

**ស៖** លោកអាចបញ្ជាក់ទេ សហករណ៍ ហើយនិងក្រុមបង្កបង្កើនផលហ្នឹង ខុសគ្នាដូចម្តេច?

**ឆ៖** ខ្ញុំបញ្ជាក់ជូនបានតាមការយល់របស់ខ្ញុំ តែត្រូវមិនត្រូវមិនដឹងដែរ ពីព្រោះខ្ញុំយល់បានប៉ុនណាជម្រាបជូនប៉ុណ្ណឹង។ បង្កើនផលហ្នឹង វាលក្ខណៈទាបណាស់ ហៅគ្នីហៅគ្នា ប្រមែ ប្រមូលគ្នាទៅបង្កើនផលហើយចែកផលគ្នា ប៉ុណ្ណឹងបាទ។ ហើយសហករណ៍កម្រិតគេខ្ពស់ ប៉ុន្តែកម្រិតខ្ពស់ហ្នឹងក៏មិនបានជ្រៅជ្រះអីដែរទេ ពេលវេលាវាខ្លីណាស់ ធ្វើពេលវេលាហ្នឹងខ្លីណាស់ ប៉ផាប់ពភឹងហើយ។ ចប់អាន់ុងភ្លាម សង្គ្រាមវៀតណាមវៃចូលភ្លាមទៀត។ ដូច្នេះមិនច្បាស់លាស់ទេ ខ្ញុំមិនច្បាស់ ខ្ញុំច្បាស់តែបង្កើនផល បង្កបង្កើនផល ៗហ្នឹងគឺ រួមគ្នាអីចឹងតែម្តង ផ្ទះប៉ុន្មានគ្រួសារអីចឹងរួមគ្នាទៅ ទៅធ្វើទៅ ឧបករណ៍រៀងខ្លួន បានមកចែកគ្នាទៅ តាមលទ្ធភាពដែលមានរៀងខ្លួន។

[១០:២៣:៤៥]

**ស៖** តើអ្នកណាគេជាអ្នកសម្រេចឲ្យបង្កើតសហករណ៍?

**ឆ៖** ដូចខ្ញុំជម្រាបលោកដដែល គឺខាងលើបាទ ឬគេហៅថា អង្គការខាងលើបាទ។

**ស៖** តើការបង្កើតសហករណ៍ហ្នឹង ក្នុងបំណងអ្វីដែរលោក នី កន បាទ?

**ឆ៖** ខ្ញុំយល់មិនអស់ទេ តែខ្ញុំយល់ថា ក្នុងការអនុវត្តនយោបាយ ដែលខ្ញុំជម្រាបខាងដើមដដែលតាមខ្ញុំយល់គឺ ឧបត្ថម្ភខ្លួន ហើយនយោបាយឯករាជ្យ ម្ចាស់ការ គឺមិនពឹងបរទេស។ ន័យអីចឹង នេះខ្ញុំយល់ណ៎ា ប៉ុន្តែជ្រៅទៅទៀតមិនដឹងដែរបាទ។

[១០:២៤:៥៨]

**ស៖** បាទ សូមអរគុណ។ នៅសម័យឆ្នាំ១៩៧៥ ចាប់ពីឆ្នាំ១៩៧៥ មក តើលោកមានបានឃើញទិដ្ឋភាព មានវត្តអារាម ត្រូវបានគេចាត់ទុក ឬក៏ប្រើប្រាស់ជាទីកន្លែងសម្រាប់សក្ការបូជាដែរឬទេ?

**ឆ៖** សូមជម្រាបជូនលោក ក្នុងពេលសង្គ្រាមដែលខ្ញុំឃើញ គឺវត្តអារាមអីទាំងអស់ គ្រប់ទិសទីក្នុងប្រទេសកម្ពុជា ត្រូវកប៉ាល់ហោះទម្លាក់ទាំងអស់។ ពីព្រោះកងទ័ពនេះ ក៏រត់ចូលក្នុងវត្តអារាម ហើយដល់អីចឹងទៅ វត្តហ្នឹង លោកក៏ទៅធ្វើទ័ពអស់ ដល់លោកទៅធ្វើទ័ពអស់ ទាំងអស់គ្នាចេះតែទៅជាចលនាមហាជនអីចឹងទៅ។ វត្តហ្នឹងក៏មិនបានឃើញថាអ្នកណាធ្វើសក្ការបូជាអីទេ។ នេះដែលខ្ញុំឃើញ

ដែលលោកសួរខ្ញុំ ខ្ញុំឆ្លើយបានប៉ុណ្ណឹងបាទ។

[១០:២៦:១២]

**សៈ** បាទ មានការហាមឃាត់ពីថ្នាក់លើដែរឬទេ ទាក់ទងនឹងការគោរពបូជាបែបសាសនានៅក្នុងទីវត្តអារាមបាទ?

**ឆៈ** ចំពោះខ្លួនខ្ញុំដូចមិនឃើញទេបាទ មិនឮទេ មិនឮថាហាមដាច់ខាតមិនត្រូវធ្វើ មិនឮទេ។ តែគ្រាន់តែជាចលនាវាទៅអ៊ីចឹងទៅ ស្រាប់តែវាអស់លោក អស់អីអ៊ីចឹងទៅ វាទៅអ៊ីចឹង មកតមកអ៊ីចឹងមក បាទ។

**សៈ** បាទ សូមអរគុណ។ តើហេតុអ្វីបានជាឲ្យព្រះសង្ឃ និមន្តព្រះសង្ឃចូលធ្វើកងទ័ព? តើមានការណែនាំ ក៏ដាក់បទបញ្ជាពីថ្នាក់ណាមក ឬក៏ព្រះសង្ឃស្ម័គ្រចិត្តដោយអង្គឯង ឬក៏យ៉ាងម៉េចបាទ?

**ឆៈ** កាលនោះ វាជាចលនាដូចខ្ញុំបានជម្រាប។ រហូតដល់ចម្រៀង កូនប្រុសដើមទ្រូងប្រាំហត្ថ បើមិនទៅសមរភូមិមុខទេ មិនស្រឡាញ់អ្នកឯងទេ។ ហើយបើបានស្បែកជើងកង់ឡាន បើបានក្រមាបង់ក វាមោទនភាព។ ម្ល៉ោះហើយវាទៅជាចលនាស្ម័គ្រចិត្តទៅអ៊ីចឹងតែម្តង ខ្ញុំឃើញ ខ្ញុំនៅក្បែរវត្តខ្លះដែរ។ ព្រោះម្តុំខដុង្គហ្នឹងមានវត្តដែរ។ ឃើញស្ម័គ្រចិត្តទៅសុំខ្លួនឯងទៅអ៊ីចឹងតែម្តង តែដល់ក្រោយមកវាម៉េចទៀត អាន់ុងជារឿងមួយ តែពេលនុំងវាអ៊ីចឹងបាទ។

[១០:២៧:៤៩]

**សៈ** បាទ សូមអរគុណ។ តើលោកមានបានធ្លាប់ឃើញក្មេងដែលជាអនីតិជនមិនទាន់គ្រប់អាយុចូលធ្វើកងទ័ពដែរឬទេ?

**ឆៈ** ចម្លើយខ្ញុំជាន់គ្នាដូចបានជម្រាប។ គេហៅ "ចលនាមហាជន" គឺមហាជនប្រុសស្រី ក្មេងចាស់ ទៅទាំងអស់គ្នាតែម្តង ទៅជាមោទនភាពថាទៅអ៊ីចឹងវាកិត្តិយស។ ដូច្នេះទៅៗជួយ ស្តាយអីៗអ៊ីចឹងទៅ។ បាទ នេះខ្ញុំឆ្លើយបានប៉ុណ្ណឹងបាទ។

**សៈ** បាទ សូមអរគុណ។ តើអ្នកណាដែលជាអ្នកទទួលខុសត្រូវលើភូមិភាគបស្ចិមបាទ?

**ឆៈ** ឈ្មោះ តាស៊ី បាទ។ តាស៊ី។

[១០:២៨:៤៤]

**សៈ** បាទ តាស៊ី គាត់មានមុខងារ ឬក៏តួនាទីអ្វីដែរនៅក្នុងពេលនោះបានទេ? នៅតំបន់នោះបាទ?

**ឆ៖** ពេលនោះគេហៅថា មេភូមិភាគ បាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ តើអ្នកណាខ្លះទៀតជាសមាជិករបស់គណៈដឹកនាំភូមិភាគនេះ?

**ឆ៖** សូមជម្រាបជូន ដូចបានជម្រាបខាងដើម គឺជាលាក់ការណ៍សម្ងាត់ខ្ពស់។ ដូច្នេះគ្រាន់តែដឹងថា តាស៊ី មេភូមិភាគ ហើយឃើញមាន តាប៉ាល់ អ៊ីចឹងទៅ តែឲ្យហៅថាច្បាស់មួយពីរបីអីហ្នឹង មិនច្បាស់ទេបាទ។

**ស៖** បាទ សូមអរគុណ។ តើ តាស៊ី ហើយនិង តាប៉ាល់ ក្រោយមកគាត់ធ្វើអ្វី? ហើយនៅកន្លែងណាដែរបាទ?

[១០:៣០:០១]

**ឆ៖** តាប៉ាល់ គាត់រៀសសឹកដែរ ហើយក៏ស្លាប់។ ហើយ តាស៊ី ខ្ញុំមិនដឹង ខ្ញុំចេញផុតហើយ។

**លោក ច័ន្ទ តារាស្មី៖**

បាទ អរគុណលោកប្រធាន ប្រហែលជាដល់ម៉ោងសម្រាកហើយបាទ សូមលោកប្រធានមេត្តាសម្រេច។ បាទ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ តាមម៉ោងពេលកំណត់។

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥០:៤៥]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលលើសាក្សី នី កន បន្ត ដោយតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តសំណួរសួរទៅលោកសាក្សី នី កន ជាបន្តទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក នី កន ខ្ញុំសូមសួរលោកបន្តទៀត ទាក់ទងទៅនឹងអ្វីដែលលោកបានឆ្លើយអម្បាញ់មិញ មុនពេលសម្រាកនេះបាទ។ នៅក្នុងតំបន់១៥ ដែលលោកស្ថិតនៅ ខ្ញុំសូមឲ្យលោកបញ្ជាក់បន្ថែមថា តើមានសមាសភាពផ្លាស់ប្តូរថ្មីដែរឬទេ នៅពេលដែលលោកស្ថិតនៅ ហើយនិងក្រោយពេលដែលលោកចាកចេញពីតំបន់ភូមិភាគ១៥ នោះបាទ?

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូនបាទ។ ក្នុងពេលខ្ញុំនៅអត់មានការផ្លាស់ប្តូរទេ។

**ស៖** បាទ សូមអរគុណ។ តើមានតំបន់ចំនួនប៉ុន្មាននៅក្នុងភូមិភាគបស្ចិម ក្រោយពីភូមិភាគពិសេសត្រូវបានគេដាក់បញ្ចូលឲ្យទៅក្នុងភូមិភាគបស្ចិមនោះ?

**ឆ៖** សូមជម្រាបជូន។ ភូមិភាគបស្ចិម ដែលខ្ញុំដឹងគឺមាន ៣២, ៣១ ដែលច្បាស់ គឺពីរហ្នឹង។ ឯ ៣៧ អី ខ្ញុំមិនច្បាស់ទេ ដូច-- ដូច្នេះមិនអាចជម្រាបជូនបាន។ ខ្ញុំដឹងច្បាស់តែ៣២, ៣១ បាទ។

[១០:៥៣:២៣]

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់តំបន់៣២ បន្តិចមើលបាទ។ តើតំបន់៣២ ហ្នឹងមានន័យដូចម្តេច? ហើយស្ថិតនៅទីតាំងណាបាទ? ហើយគេធ្វើអ្វីដែរតំបន់៣២ ហ្នឹងបាទ?

**ឆ៖** តំបន់ហ្នឹងគេគ្រប់គ្រងមូលដ្ឋាន បាទ។ ធម្មតាតែមានស្រុកបី គេហៅតំបន់។ ហើយគ្រប់គ្រងម្តុំតំបន់១៥ ចាស់ហ្នឹង មានឧដុង្គ ពញាឮ អីចឹងបាទ។

**ស៖** បាទ អរគុណ។ តើអ្នកទទួលខុសត្រូវគ្រប់គ្រងតំបន់៣២ នោះបាទ?

**ឆ៖** អ្នកទទួលខុសត្រូវគឺឈ្មោះ តាប៉ាល់ បាទ។

[១០:៥៤:៣០]

**ស៖** គាត់គ្រប់គ្រងតំបន់នេះចាប់ពីពេលណាមកបាទ រហូតដល់ពេលណាដែរ?

**ឆ៖** គាត់គ្រប់គ្រងពីពេលដែលគេសង្គ្រាមចប់ហ្នឹង គេបញ្ចូលតំបន់១៥ហ្នឹងទៅនឹងជាមួយគាត់ហ្នឹង គេហៅតំបន់៣២។ គ្រប់គ្រងនៅពេលសង្គ្រាមវៀតណាមវ៉ៃចូលហ្នឹងតែម្តងបាទ។ ត្រឹមហ្នឹងក៏បែកខ្ញែកអស់ហើយ។

**ស៖** បាទ អរគុណ។ ចុះតំបន់៣១វិញ ស្ថិតនៅតំបន់ណាដែរ ហើយអ្នកណាអ្នកទទួលខុសត្រូវ ហើយតំបន់៣១ហ្នឹង ធ្វើអ្វីដែរបាទ?

**ឆ៖** លំនាំចាត់តាំង គឺដូចគ្នា គឺគ្រប់គ្រងស្រុក រួចហើយ អ្ហឺ! អ្នកដែលគ្រប់គ្រងហ្នឹង ខ្ញុំឮឈ្មោះថា តាសារុន បាទ។

**ស៖** បាទ អរគុណ។ តំបន់៣១គ្រប់គ្រងស្រុក តើស្រុកណាដែរ ដែលស្ថិតនៅក្រោមតំបន់៣១នេះបាទ?

[១០:៥៦:០០]

**ឆ៖** ខ្ញុំចាំមិនអស់ទេ ដឹងច្បាស់តែកំពង់ឆ្នាំងមួយបាទ។

**ស៖** ហេតុអ្វីបានគេចាត់កំពង់ឆ្នាំងចូលក្នុងតំបន់៣១? តើមានហេតុផលអីបាទ?

**ឆ៖** ហេតុផលតាមខ្ញុំមើល ដូចជាមិនមានអីក្រៅពីការបែងចែកដើម្បីគ្រប់គ្រង បែងចែកជាតំបន់ៗ គ្រប់គ្រង។

**ស៖** អរគុណ។ តាសារុន ដែលលោកបញ្ជាក់អំមិញ ជាអ្នកគ្រប់គ្រង់តំបន់៣១ តើគាត់គ្រប់គ្រងចាប់ពីពេលណា ដល់ពេលណាដែរបាទ?

**ឆ៖** ខ្ញុំអត់ច្បាស់ទេ ព្រោះខ្ញុំទៅក្រោយ តំបន់៣២ទើបចប់ ទៅក្រោយ។ ដូច្នេះ៣១ហ្នឹងកើតពីថ្ងៃណា អីថ្ងៃណា មិនច្បាស់។

**ស៖** បាទ តំបន់៣៧ដែលលោកបញ្ជាក់អំមិញ ថាលោកអត់យល់ច្បាស់ អត់ដឹង អត់ច្បាស់ តើលោកអាចបញ្ជាក់ត្រួសៗនូវអ្វីដែលលោកអាចចងចាំបានទេ បាទ តំបន់៣៧ ស្ថិតនៅទីតាំងណា? ហើយអ្នកណាគ្រប់គ្រង? ហើយបង្កើតឡើងក្នុងគោលបំណងអ្វី?

**ឆ៖** សូមជម្រាបជូន គោលបំណងដូចគ្នាដដែល គឺគ្រប់គ្រង-- អឺ! បែងចែកដើម្បីគ្រប់គ្រង។ អាហ្នឹងជាគោលបំណង។ ឯឈ្មោះស្រុក ឬអ្អឺ! អឺ ខ្ញុំមិនច្បាស់ ខ្ញុំឮតែថា មានខេត្តកោះកុងមួយៗ។

**ស៖** អ្នកណាគេគ្រប់គ្រង់តំបន់៣៧បាទ?

**ឆ៖** សូមឆ្លើយ គឺអត់ច្បាស់ទេបាទ។

[១០:៥៨:០៤]

**ស៖** បាទ អរគុណ។ ខ្ញុំសូមបន្តសំណួរផ្សេងទៅទៀតបាទ។ នៅពេលដែលលោកបានទៅដល់ភូមិភាគបស្ចិម តើអ្នកណាជាអ្នកបំពាក់បំប៉នទ្រឹស្តីនយោបាយដល់លោក?

**ឆ៖** ជាលាក់ការណ៍ ធម្មតាគឺមេភូមិភាគមកទទួលពីខាងលើ រួចមេភូមិភាគហ្នឹង ហៅសមាសភាពនៅក្រោមការគ្រប់គ្រងហ្នឹងទៅផ្សព្វផ្សាយ។ រួចអ្នកផ្សព្វផ្សាយហ្នឹងដែលគេមានតួនាទីជាតំបន់ គេយកមកដកស្រង់ឲ្យផ្សព្វផ្សាយបន្តបាទ។

**ស៖** តើលោកអាចបញ្ជាក់ឈ្មោះបានទេ តើលោកណាដែលជាអ្នកបំពាក់បំប៉នទ្រឹស្តីនយោបាយដល់លោក?

**ឆ៖** អ្នកបំពាក់បំប៉នបន្តគឺ តាប៉ាល់។

**ស៖** បាទ សូមអរគុណ។ តាប៉ាល់ នៅក្នុងពេលនោះ តួនាទីគាត់ស្ថិតនៅក្នុងការទទួលខុសត្រូវកម្រិតណាបាទ?

**ឆ៖** តាមយល់ គឺគាត់មានតួនាទី គឺអាចជាបុគ្គលទីពីររបស់ភាគ ហើយជាបុគ្គលទីមួយរបស់តំបន់។

[១០:៥៩:៥៨]

**ស៖** ចុះតាស៊ី វិញបាទ? លោកបញ្ជាក់នៅមុនពេលសម្រាកអំមិញថា តាស៊ីមានវត្តមាននៅក្នុងតំបន់នោះដែរ។ តើតាស៊ី ហើយនិងតាប៉ាល់ ហ្នឹង តួនាទីគាត់យ៉ាងម៉េចបាទ? ប្រៀបធៀបតាស៊ី តាប៉ាល់ហ្នឹង តើអ្នកណាទទួលខុសត្រូវកម្រិតណា? ហើយទទួលខុសត្រូវក្នុងផ្នែកណា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនម្តងទៀត។ តាស៊ីហ្នឹង មេភូមិភាគ តាប៉ាល់ហ្នឹងបុគ្គលទីពីរពី តាស៊ី។ ហើយ តាប៉ាល់ ហ្នឹងមានជើងមួយមកខាងតំបន់បាទ។

**ស៖** បាទ សូមអរគុណ។ លោកមានដែលឮឈ្មោះបុគ្គលម្នាក់ដែលគេនិយាយហៅឈ្មោះថា ជូ ជេត ហៅស៊ី ៗ លោកដែលឮឈ្មោះហ្នឹងទេបាទ?

**ឆ៖** លាក់ការណ៍សម្ងាត់របស់បដិវត្តន៍ ឬហៅអង្គការហ្នឹងខ្ពស់ ដូចខ្ញុំជម្រាបជូនលោក។ ដូច្នេះពួកខ្ញុំស្គាល់តែឈ្មោះចំហទេ ដល់ឈ្មោះកំណើតហ្នឹងមិនស្គាល់ទេបាទ។ ឈ្មោះចំហហ្នឹងគឺ ស៊ី បាទ។

[១១:០១:៣០]

**ស៖** អរគុណបាទ។ តើតាស៊ីបានបង្រៀនបំពាក់បំប៉នឧយោបាយដល់លោកយ៉ាងដូចម្ដេច?

**ឆ៖** ខ្ញុំបានទទួលការបំពាក់បំប៉នក្រោយ ចុង៧៤ ដើម ៧៥ នេះ ចូលដាច់៧៥ហ្នឹងគឺខ្លឹមសារដូចបានជម្រាបខាងដើម លែងលើកពីបញ្ហារំដោះចក្រពត្តិហើយ។ លើកតែបញ្ហាបង្កបង្កើនផលឧបត្ថម្ភខ្លួនអនុវត្តន៍នយោបាយឯករាជ ម្ចាស់ការ។ ហើយទីពីរក៏មានការអប់រំពីរឿងអីទៀត រឿងខំកែប្រែបច្ចេកទេសទំនប់ប្រឡាយ ដើម្បីឲ្យបានទឹកធ្វើស្រែ បានពីរទៅបីដង។ នេះជាបញ្ហាធំ បាទ។

**ស៖** បាទ អរគុណ។ តើលោកតាស៊ីមកបង្រៀនបំពាក់បំប៉ននយោបាយដល់លោក តើបង្រៀនហ្នឹងក្នុងក្រុមមនុស្សច្រើន ឬក៏បង្រៀនលក្ខណៈជាបុគ្គលរវាងលោក ហើយនិងគាត់?

**ឆ៖** ការរៀនសូត្រនៅពេលនោះ គឺមានតែ២០០ ទៅ ៣០០ ទៅ ៥០០ ហើយគេមានកម្រិតទៅតាមផ្នែក។ បើគេហៅថា សូត្របើកទូលាយហ្នឹងគឺចម្រុះហើយ។ ខ្ញុំក៏ចូលបាន ហើយសមាសភាពដែលគេហៅថា នៅតាមក្រុមបង្កើនផលក៏ទៅបាន ដោយគេជ្រើសរើស។ ដូច្នេះមានតែពីរ ទៅបីរយ ដូចលើសហ្នឹងទៀត។ ដូច្នេះមិនមានអាគោលការណ៍ដែលថា ពីរនាក់ទេ អត់មានទេ។ ផ្សព្វផ្សាយអីចឹងដល់មកបានគេបំបែកបន្ត។

**ស៖** អរគុណ។ លោកអាចបញ្ជាក់បន្ថែម ការបើកវគ្គបណ្ដុះបណ្ដាលជាចំហដែលមានគ្នាច្រើនចូលរួម ហើយនិងការបណ្ដុះបណ្ដាលវគ្គនយោបាយក្នុងលក្ខណៈចង្អៀត ដែលលោកនិយាយអំមិញថាគេបំបែកជាបន្តហ្នឹង ទម្រង់ពីរហ្នឹងខុសគ្នាយ៉ាងដូចម្ដេច?

[១១:០៤:០៦]

**ឆ៖** ក្នុងន័យប្រតិបត្តិ គេធ្វើអីចឹងបាទ គឺទទួលរួមហើយបានគេមកបំបែក។ មកបំបែកនៅក្នុងន័យគេបំបែក ដើម្បីឲ្យសមស្របនឹងកន្លែងរបស់គេ ដើម្បីគេតាមដានថា ធ្វើបាន ឬមិនបាន។ ប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ជាធម្មតានៅក្នុងពេលធ្វើការជាធម្មតា នៅសម័យកាលដែលលោកនៅជាមួយនឹងតំបន់១៥ហ្នឹង តើលោកឃើញតាស៊ី ធ្វើការយ៉ាងដូចម្ដេច? ធ្វើការអ្វី? ហើយការិយាល័យគាត់ធ្វើការហ្នឹងនៅកន្លែងណា?

[១១:០៤:៥៨]

**ឆ៖** ជម្រាបជូន អត់ឃើញទេ តាស៊ី បាទ នៅក្នុងពេលតំបន់១៥។ ពីព្រោះពេលហ្នឹងកំពុងប្រយុទ្ធខ្លាំង។ ហើយជាលាក់ការណ៍សម្ងាត់ គេមិនឲ្យឃើញទេ គ្មានណាចេញទៅឲ្យឃើញទេបាទ។

**ស៖** អរគុណ។ តើលោកមានធ្លាប់បានឃើញ ឬក៏ឮថា តាស៊ី ហ្នឹង មានធ្វើការនៅតំបន់ត្រង់៣២ ដែរឬទេ? មានដែលឮគេនិយាយ ឬក៏ធ្លាប់ដឹងឮថា តាស៊ី ហ្នឹង ធ្វើការនៅតំបន់៣២ ឬក៏តំបន់ណាផ្សេងដែរឬទេបាទ?

**ឆ៖** ថ្នាក់ភូមិភាគគេមានកន្លែង។ បាទ គេមានកន្លែងរបស់គេ។ ដូច្នេះ គ្រាន់កន្លែងហ្នឹង វាអាចជួនកាលគេតាំងនៅចំតំបន់៣២ ឬតំបន់៣១ អាន់ុង ស្រេចតែគេចល័តទេ។ ប៉ុន្តែគេមានតំបន់-- មានកន្លែងរបស់គេបាទ។

**ស៖** បាទ អ៊ីចឹងមានន័យថា លោកអត់ដឹងច្បាស់ថា តាស៊ី ធ្វើការនៅតំបន់ណាមួយជាក់ច្បាស់ទេ ឬយ៉ាងម៉េចបាទ?

**ឆ៖** អត់ច្បាស់ទេ ច្បាស់ថាត្រង់ថាភាគច្រើន គាត់នៅក្នុងទីតាំងរបស់គាត់ នៅខាងតំបន់៣២ខាងលើ មិនមែននៅតំបន់១៥ទេ។

[១១:០៦:៣៦]

**ស៖** បាទ សូមអរគុណ។ តើលោកមានដែលឮពាក្យ ឬក៏ឮគេនិយាយថា មន្ទីរ៤០១ ដែរឬទេ? មន្ទីរ៤០១ លោកដែលឮគេនិយាយដែរឬទេ? ធ្លាប់ឮគេថា ឬក៏ឮ-- មានឃើញឯកសារណា ដែលគេសរសេរមន្ទីរ៤០១ ដែរឬទេបាទ?

**ឆ៖** ចំពោះមន្ទីរ៤០១ នេះ ខ្ញុំអត់ដែលឮទេបាទ។

**ស៖** បាទ អរគុណ។ តើលោកមានដែលឮ គេនិយាយលេខកូដសម្ងាត់នៃមន្ទីរដែលលោក តាស៊ី ហ្នឹង ធ្វើការដែរឬទេ?

**ឆ៖** ចំពោះបញ្ហានេះ អត់ទេបាទ។

**ស៖** សូមអរគុណ។ តើលោកមានបានចងចាំទេថា ជូ ជេត ហៅ ស៊ី បានចូលរួមវគ្គបំពាក់បំប៉ននយោបាយហ្នឹងដល់លោកដែរឬទេ? ឬក៏មិនដែរទេបាទ? ជូ ជេត ហៅ ស៊ី ហ្នឹង តើគាត់បានធ្លាប់បំពាក់បំប៉នអប់រំនយោបាយដល់លោកដែរឬទេ? បើមាននៅពេលណា? ហើយប៉ុន្មានដងបាទ?

**ឆ៖** ចំពោះសំណួរនេះ គឺខ្ញុំសូមបញ្ជាក់ជូន គឺទទួលបំពាក់បំប៉ន ដូចខ្ញុំបានជម្រាបអម្បាញ់មិញ គឺបំពាក់បំប៉នរួម កម្រិតរយនាក់ ដូចបានជម្រាប។ បាទ ឯបំពាក់បំប៉នផ្ទាល់ អត់ទេ។ ផ្ទាល់ដូចថា ពីរនាក់ បីនាក់ អីអត់ទេបាទ។ ហើយឈ្មោះដឹងថាឈ្មោះចំហ គឺថាហៅឈ្មោះ ស៊ី ហើយ ជូ ជេត ហ្នឹង អត់ទេ។

[១១:០៨:៣៦]

**ស៖** អរគុណ។ តើលោកធ្លាប់បានចូលរួមវគ្គបំពាក់បំប៉ននយោបាយក្នុងតំបន់៣២ ដែរឬទេ?

**ឆ៖** ការបំពាក់បំប៉នក្របខ័ណ្ឌតំបន់ អាហ្នឹង គេធ្វើញឹកញាប់ដែរ។ តាមវិធីដែលខ្ញុំបានបញ្ជាក់ជូន គឺគេទទួលពីរួមមកហើយ។ ពីរួមគឺពីភូមិភាគមកហើយ គេយកមកបំពាក់បំប៉នបន្ត។ អាហ្នឹងច្រើនដងដែរ គេលម្អិត គេបំពាក់អីចឹងហើយទៅ ទៅអនុវត្តទៅ ហើយមកអនុវត្តបានផល មិនបានផលម៉េច គេមកសរុបទៀតទៅ ប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ នៅមុនពេលដែលតំបន់១៥ ក្លាយមកជាតំបន់៣២វិញ តើលោកកាន់កាប់មុខតំណែង ឬក៏តួនាទីអ្វីពិតប្រាកដបាទ?

**ឆ៖** ខ្ញុំទទួលភារកិច្ចជាគណៈអប់រំ។ ផ្នែកអប់រំក្នុងតំបន់។ ឃោសនាអប់រំ ដូចបានជម្រាបខាងដើម។

[១១:១០:០០]

**ស៖** បាទ អរគុណ។ តើការទទួលខុសត្រូវក្នុងនាមជាអ្នកអប់រំក្នុងតំបន់៣២ទាំងមូល ឬក៏ផ្នែកណាខ្លះនៃតំបន់៣២?

**ឆ៖** ខ្ញុំទទួលការអប់រំខាងប្រជាជនផង ហើយនិងការអប់រំខាងដូចជា សមាសភាពដែលគេចុចឈ្មោះឲ្យមករៀនផង ពីភូមិ ពីឃុំអីចឹងបាទ។

**ស៖** បាទ អរគុណ។ ចុះតំបន់ភូមិភាគ១បស្ចិមវិញ តើលោកនៅតែចូលរួមក្នុងការឃោសនាដដែល ឬក៏យ៉ាងម៉េចដែរ? ឬក៏លោកធ្វើទាំងពីរ ឃោសនានៅក្នុងភូមិភាគបស្ចិមផង និងតំបន់៣២ផង ឬក៏តែផ្នែកណាមួយបាទ?

**ឆ៖** ខ្ញុំត្រឹមតំបន់ទេ អត់ដល់ភូមិភាគទេ។

**ស៖** អរគុណ។ តើលោកអាចពន្យល់ជូនអង្គសវនាការ ឲ្យបានជ្រាបច្បាស់ទេ អំពីរចនាសម្ព័ន្ធនៃតំបន់១៥។ តើតំបន់១៥ហ្នឹង នៅពេលដែលមុនពេលក្លាយជាតំបន់៣២វិញ តើរចនាសម្ព័ន្ធរៀបចំ

គ្រប់គ្រងចាត់តាំងហ្នឹងមានយ៉ាងដូចម្ដេចបាទ?

[១១:១១:៥៣]

**ឆ៖** ការរៀបចំរចនាសម្ព័ន្ធតំបន់១៥ ពេលនោះ សូមជម្រាបជូនអង្គសវនាការថា មិនរលូនទេ ពីព្រោះអី? ពីព្រោះស្ថិតក្នុងសភាវៈសង្គ្រាម។ ដូច្នេះគេគ្រាន់តែប្រកាសថា នរណាខាងមូលដ្ឋាន អ្នកណាខាងទ័ព នរណាខាងសេដ្ឋកិច្ចផ្គត់ផ្គង់ សេដ្ឋកិច្ចហ្នឹងគឺ ដឹកជញ្ជូន ផ្គត់ផ្គង់ តែប៉ុណ្ណឹង។ ដូច្នេះគ្រាន់តែប្រកាសថា អ្នកនេះខាងទ័ព អ្នកនេះខាងមូលដ្ឋាន។ មូលដ្ឋានហ្នឹង គឺប្រជាជន។ ហើយអ្នកនេះខាងដឹកជញ្ជូនផ្គត់ផ្គង់។ អ្នកនេះខាងឃោសនាកៀងគរ។ តែប៉ុណ្ណឹង។ ដូច្នេះ មិនរលូនទេបាទ មិនច្បាស់លាស់ជាចាត់តាំងអីច្បាស់លាស់ទេ។

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់ឲ្យបានលម្អិតបន្តិច បើសិនជាលោកអាចបញ្ជាក់បាន ទាក់ទងនឹង តើបុគ្គលណាជាអ្នកទទួលខុសត្រូវ ឬក៏គ្រប់គ្រងតាមផ្នែកនីមួយៗដែលលោកបានបញ្ជាក់អម្បាញ់មិញ ដូចជាខាងកងទ័ព ខាងមូលដ្ឋាន ខាងសេដ្ឋកិច្ច ខាងដឹកជញ្ជូន ខាងផ្គត់ផ្គង់ ខាងឃោសនាជាដើម។ល។ អ៊ីចឹងសូមលោកជួយបញ្ជាក់ឈ្មោះបុគ្គលដែលទទួលខុសត្រូវ ឬក៏ថ្នាក់លើចាត់តាំងអីហ្នឹង សូមឲ្យបញ្ជាក់ជូនអង្គសវនាការជ្រាបឲ្យច្បាស់អំពីបញ្ហានេះបន្តិចបាទ?

[១១:១៣:៣៥]

**ឆ៖** សូមជម្រាបជូនបាទ ខ្ញុំដកមកតំបន់១៥ហ្នឹងមក ខ្ញុំស្គាល់ច្បាស់តែ ចេង អន ដែលទទួលយោធាតំបន់។ ហើយក្រៅពីនុ៎ងទៀត ភ្លេចដែរហើយមិនចាំទេ មានម្នាក់ទៀតខាងមូលដ្ឋាន។ ហើយបានម្នាក់ទៀតខាងសេដ្ឋកិច្ចគឺរកអង្ករ រកអីជូនសមរភូមិ។ ហើយខ្ញុំគេប្រកាសថាឲ្យខាងឃោសនា។ មានប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ តើ ចេង អន គឺជានរណា ហើយពីមុនធ្វើការអ្វីដែរបាទ? ស្ថិតនៅក្នុងតំបន់ណាដែរ ចេង អន ពីមុនមក?

**ឆ៖** ជម្រាបជូនលោកប្រធានគឺ ចេង អន ហ្នឹងខ្ញុំស្គាល់ បើភាសាខ្មែរគេថា វាក់អឺ ទេ ស្គាល់តែគេប្រាប់ថានេះឈ្មោះ ចេង អន ទទួលបន្ទុកនៅកន្លែងហ្នឹង។ ឯប្រវត្តិរូបលម្អិត មកពីខាងណាអីខាងណីអត់ដឹងទេបាទ។ ហើយគេក៏មិនប្រាប់យើងដែរបាទ។

**ស៖** បាទ សូមអរគុណ។ តើអ្នកណាខ្លះជាផ្នែកនៅក្នុងគណៈតំបន់៣២ លោកអាចបញ្ជាក់តំបន់៣២ហ្នឹង មានអ្នកណាខ្លះជាសមាសភាពនៅក្នុងហ្នឹង ជាប្រធាន? ជាសមាជិក? ជាអនុប្រធាន?

ឬក៏អ្នកទទួលខុសត្រូវនៅក្នុងតំបន់៣២ហ្នឹងបាទ?

[១១:១៥:៣៨]

**ឆ៖** ជម្រាបជូន ក្រោយពីតំបន់៣២ បញ្ចូលគ្នាហ្នឹងគឺមាន តាប៉ាល់ ហ្នឹងហើយ រួចហើយមាន ចេង អន ហ្នឹងហើយ ព្រោះតំបន់២ គេយកប្រធាន និងប្រធាន បូកជាមួយគ្នា។ បានគេហៅថា តំបន់បញ្ចូលគ្នា រួចហើយក៏ពួកខាងក្រោមៗ ដូចខ្ញុំ នៅខាងឃោសនាអប់រំនៅដដែល នៅក្នុងគណៈអប់រំដដែល។

**ស៖** បាទ អរគុណ។ តើ តាប៉ាល់ ក្នុងតំបន់៣២ហ្នឹង តាប៉ាល់ មានតួនាទីជាអ្វី? ហើយ ចេង អន ហ្នឹង មានតួនាទីជាអ្វីក្នុងតំបន់៣២ហ្នឹងបាទ?

**ឆ៖** តាប៉ាល់ ហ្នឹង ដូចជម្រាបខាងដើមអំមិញ តាប៉ាល់ គាត់ជាបុគ្គលទីពីរ បន្ទាប់ពី ស៊ី-- តាស៊ី ហើយគាត់ជាលេខាតំបន់ ចេង អន ហ្នឹងគាត់ជាបុគ្គលទីពីរ ពី តាប៉ាល់ ព្រោះពីដើម ចេង អន នៅមួយផ្នែកខាងតំបន់១៥ បាទ។

**ស៖** អរគុណ។ ចុះ ចេង អន វិញ ឥឡូវនៅឯណាដែរ នៅក្រោយពេលលោកជួបហើយ តើ ចេង អន ផ្លាស់ទីទៅនៅកន្លែង ឬធ្វើការអ្វីក្រោយមក ឬក៏លោកដឹងថា ចេង អន ហ្នឹង ឥឡូវនៅឯណាដែរ? លោកបានដឹងព័ត៌មាននេះដែរឬទេ?

**ឆ៖** ខ្ញុំក្រោយពីសង្គ្រាមចប់ទៅ បែកគ្នាខ្ញុំលែងដឹងហើយ តែគ្រាន់ដំណឹងខាងក្រៅថា ស្លាប់ហើយ ខ្ញុំដឹងប៉ុណ្ណឹងបាទ។

[១១:១៧:២៣]

**ស៖** អរគុណបាទ។ លោកមិនបានឮឈ្មោះ គេហៅឈ្មោះ ទេព ហៃ ឬក៏ អ៊ូ ពិន ដែរឬទេ ឬក៏ ហម មានដែលឮឈ្មោះនេះទេបាទ?

**ឆ៖** សូមជម្រាបជូន អត់ស្គាល់ទេបាទ។

**ស៖** បាទអរគុណ។ លោកស្គាល់ច្បាស់លោក សេង ប៉ាល់ ដែរឬទេ សេង ប៉ាល់? ហើយ សេង ប៉ាល់ ហ្នឹងមានទំនាក់ទំនងយ៉ាងដូចម្ដេច ជាមួយនឹងលោក សុន សេន តើលោកបានដឹងទេបាទ?

**ឆ៖** សូមជម្រាប អត់ស្គាល់ទេ អត់ដឹងទេ បាទ។

**ស៖** អរគុណ។ ខ្ញុំសូមសួរបន្តទៀត លោក នី កន បាទ។ តើអ្នកណាខ្លះជាលេខាស្រុកនៅឧដុង្គ លេខាស្រុកនៅពញាឮ និងលេខាស្រុកនៅអង្គស្នួល? តើលោកស្គាល់បុគ្គលណាដែលជាអ្នក-- ជា

លេខាស្រុកបាទ?

**ធ៖** ខ្ញុំស្គាល់ ឮនោះគឺថាប្រពន្ធតាស៊ី ឧដុង្គបាទ។ ហ្នឹងដែលសង្គ្រាមជិតចប់បាទ ហើយក្រៅពីនោះអត់ចាំទេ។ យូរពេកហើយ។

[១១:១៩:០៨]

**ស៖** បាទអរគុណ។ លោកមានដែលឮគេនិយាយឈ្មោះ អ៊ុម នេន ហៅ លី ដែរឬទេ? អ៊ុម នេន ហៅ លី ដែលឮឈ្មោះហ្នឹងគេហៅទេបាទ? ដែលឮឈ្មោះហ្នឹងទេ?

**ធ៖** អត់ឮទេបាទ។

**ស៖** បាទអរគុណ។ លោកដែលឮគេហៅឈ្មោះ កែវ ទេបាទ កែវ?

**ធ៖** ឈ្មោះ កែវ ឮបាទ។

**ស៖** អរគុណ។ តើ កែវ ជានរណាបាទ?

**ធ៖** កែវ ហ្នឹងក្នុងសង្គ្រាម កែវ ហ្នឹងហើយដែលខ្ញុំនឹកមិនឃើញអំមិញ។ កែវ ហ្នឹងទទួលខាងការផ្គត់ផ្គង់ហ្នឹងហើយបាទ។

**ស៖** បើនិយាយអំពីស្រុកពញាឮវិញ តើកែវហ្នឹងមានតួនាទីនៅក្នុងស្រុកពញាឮដែរឬទេ?

**ធ៖** គាត់មានតួនាទីផ្គត់ផ្គង់ ព្រោះគាត់-- ហើយនិងតួនាទីនៅក្នុងស្រុកនុ៎ងដែរ ពីព្រោះគាត់ជាម្ចាស់មូលដ្ឋានហ្នឹងបាទ។ ម្ចាស់មូលដ្ឋាននៅក្នុងសង្គ្រាម។

**ស៖** អរគុណ។ តើលោកមានធ្លាប់ឮគេនិយាយថា កែវ ហ្នឹងធ្លាប់ធ្វើការនៅមន្ទីរ៤០១ដែរឬទេ? លោកដែលឮគេនិយាយ ឬក៏អានឯកសារណាប៉ះដែរឬទេបាទ ករណីហ្នឹង?

**ធ៖** សូមជម្រាបជូន គឺខ្ញុំមិនដែលឮទេបាទ។

**ស៖** អរគុណ។ ខ្ញុំសូមសួរបន្តទៀត តើលោកស្គាល់ឈ្មោះ ហាំង នូវ ដែលឬទេ? ហាំង នូវ-- ហាំង ងូវ។? តើលោកស្គាល់ឈ្មោះ ហ្នឹងទេ ដែលឮគេនិយាយឈ្មោះហ្នឹងទេបាទ?

[១១:២១:១៨]

**ធ៖** ខ្ញុំឮតែឈ្មោះ តានៅ ឯ ហាំង នៅ អី ខ្ញុំមិនដែលឮទេ បាទ។

**ស៖** អរគុណ។ តើ តានៅ ហ្នឹងគឺជាអ្នកណា?

**ធ៖** តានៅ គាត់ជាបុគ្គលទទួលរណសិរ្សនៅស្រុកអង្គស្នួលអង្កាល់នោះ ឮគេតែងកាលដែលគេតែងតាំងណ៎ា! ខ្ញុំឮអ៊ីចឹងបាទ។

**ស៖** ក្រោយមកលោកបានដឹងឮថា មានព្រឹត្តិហេតុអីកើតឡើងចំពោះលោក១ ហាំង នៅ ដែរឬទេ? លោក ហង្ស នៅ១ តើលោកមានដែលឮទេ លោក ហង្ស នៅ ហ្នឹងគាត់មានបញ្ហាអីក្រោយមកបាទ?

[១១:២២:១៦]

**ឆ៖** ខ្ញុំអត់ដឹងទេ បាទ។ ខ្ញុំចេញផុតហើយ។

**ស៖** អរគុណច្រើនបាទ លោក នី កន។ ខ្ញុំសូមអនុញ្ញាតសួរបន្តទៀត នៅពេលដែលលោកស្ថិតនៅក្នុងតំបន់៣២ តើលោកបានដឹងថាអ្នកណាគេជាប្រធានសន្តិសុខតំបន់១២-- អំ សូមទោស តំបន់៣២? តំបន់ ៣២ តើលោកដឹងទេថា អ្នកណាគេជាប្រធានសន្តិសុខតំបន់៣២ បាទ?

**ឆ៖** សូមជម្រាបជូន រឿងនេះមិនដឹងទេ ព្រោះអានេះការសម្ងាត់ណាស់ ហើយជាភារកិច្ចរបស់ខាងលើ។

**ស៖** អរគុណច្រើន។ តើលោកធ្លាប់ឮគេថា ឬក៏ហៅឈ្មោះ ចាប ណម ដែរឬទេ? ចាប ណម១តើ ចាប ណម ជាអ្នកណាបាទ? តើលោកបានធ្លាប់ដឹងឮឈ្មោះហ្នឹងទេ បាទ?

[១១:២៣:១២]

**ឆ៖** អត់ទេ បាទ។

**ស៖** អរគុណ។ នៅក្នុងរចនាសម្ព័ន្ធនៃកម្មាភិបាលតំបន់៣២ តើលោកស្ថិតនៅក្នុងលំដាប់ទីប៉ុន្មាន នៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងតំបន់៣២? តើលោកស្ថិតនៅក្នុងកម្រិតណា?

**ឆ៖** ខ្ញុំស្ថិតនៅក្នុងគណៈអប់រំ ឃោសនាអប់រំរបស់តំបន់៣២ បាទ។ ផ្នែក គេចែកជាផ្នែក។

**ស៖** តើអ្នកណាគេជាមេរបស់លោកបាទ ពេលនុ៎ង?

**ឆ៖** ពេលដែលសភាពការណ៍ប្រចុចញ៉ុចហើយនេះ គឺតាមខ្ញុំដឹងដែលដើរតួសំខាន់ហ្នឹង គឺតាប៉ាល់ ដដែល។ រួចហើយបានមានឈ្មោះ បន្ទាប់មកមានឈ្មោះ រ៉ន តែទៅមិនបានច្បាស់លាស់អីទេ ពីព្រោះសភាពការណ៍រឹកររហើយ ហ្នឹងប៉ុណ្ណឹង។ ហើយក្រៅពីហ្នឹងមានតែខ្ញុំ ខាងផ្នែកគណៈអប់រំឃោសនារបស់តំបន់បាទ។

[១១:២៤:៤១]

**ស៖** បាទអរគុណ។ តើ តារ៉ន ជាអ្នកណាបាទ?

**ឆ៖** មិនដឹងជាអ្នកណាដែរ ប៉ុន្តែគេហៅ ខាងលើបញ្ជូនមក។ មិនច្បាស់បាទ។

**សៈ** បាទ អរគុណ។ តារ៉ន ហើយនិង តាស៊ី បើនិយាយអំពីរចនាសម្ព័ន្ធនៃកម្មាភិបាលក្នុងតំបន់៣២ តើអ្នកណាគេមានលំដាប់ខ្ពស់ជាងគេ? តារ៉ន ហើយនិង តាស៊ី ឬក៏ តាប៉ាល់? បីនាក់ហ្នឹង តើលោកមួយណាដែលមានឋានន្តរស័ក្តិលំដាប់ហ្នឹងខ្ពស់ ឬក៏ទាបបន្ទាប់?

**ឆៈ** ដូចជម្រាបដដែល គឺតាស៊ី ហ្នឹងគេហៅមេភូមិភាគហើយបាទ។ រួចហើយ តាប៉ាល់ ហ្នឹងបន្ទាប់មកកាន់តំបន់៣២ ឯ តារ៉ន ហ្នឹងអ្នកបញ្ជូនមកថ្មី នៅក្រោម តាប៉ាល់ ហើយមិនមែននៅនេះទេបាទ។ ដូច្នេះ តាស៊ី ទីមួយ តាប៉ាល់ ទីពីរ ឬអាចហៅថា តារ៉ន ហ្នឹងបីក៏បាន។ តែខ្ញុំតាមការខ្ញុំយល់ទេណា ខ្ញុំមិនច្បាស់ថាមួយរយភាគទេបាទ។ អស់ហើយបាទ។

**សៈ** អរគុណ។ តើក្រោយពេលដែល តាស៊ី ឈ្មោះ ស៊ី ហ្នឹងផ្តល់ការអប់រំវគ្គនយោបាយជូនលោក តើលោកនិងគាត់នៅតែបន្តការប្រាស្រ័យទាក់ទងគ្នាទៀត ឬក៏យ៉ាងណា?

[១១:២៦:២៨]

**ឆៈ** ខ្ញុំបានជម្រាបដែរ ដដែលហើយ គឺខ្ញុំទទួលបន្ត។ មានតែវគ្គ គេហៅប្រជុំបើកទូលាយទេដែលបានចូលរួម ឯក្រៅពីហ្នឹងទទួលបន្ត។ ទទួលបន្តពីតំបន់បាទ។

**សៈ** អរគុណ។ តើការបន្តទំនាក់ទំនងរវាងលោកជាមួយនឹងឈ្មោះ ស៊ី បន្តរហូតមក ឬក៏ដាច់ៗ? ហើយការបន្តទាក់ទងហ្នឹងតាមរយៈមធ្យោបាយណា? តាមទូរស័ព្ទ ឬក៏ការប្រជុំ ឬក៏ការជួបផ្ទាល់ ឬក៏តាមរយៈលិខិតដោយបញ្ជូនទៅមកតាមរយៈនីរសារណាមួយ?

**ឆៈ** សូមបញ្ជាក់ កាលនោះគ្មានទូរស័ព្ទទេ ទីមួយ។ ទីពីរ គេចាត់ចែងដឹកនាំតាមលំដាប់ថ្នាក់ គឺខ្ញុំតាមថ្នាក់តំបន់ ពីលើចុះមកតំបន់ ពីតំបន់ចុះមកខ្ញុំ មិនអាចទៅត្រង់បានទេបាទ។ ប៉ុណ្ណឹងបាទ។

**សៈ** តើការទាក់ទងទំនាក់ទំនងហ្នឹង គឺដោយរយៈទូរលេខ សារទូរលេខ ឬក៏តាមរយៈបុគ្គលនាំសារ ឬក៏លោកជួបផ្ទាល់ជាមួយនឹងគាត់?

[១១:២៨:០៨]

**ឆៈ** ទូរលេខ មូលដ្ឋានមិនអាចមានទេ ហើយកាលនោះក៏មិនសំបូរអីដែរ មានតែទាហានបានមាន។ ហើយទីពីរ ដូចខ្ញុំបញ្ជាក់ដដែលៗ គឺខ្ញុំតាមរយៈ តាប៉ាល់ បាទ មិនមែនទៅត្រង់ទេ។

**សៈ** បាទ អរគុណ។ តើ តាស៊ី បានណែនាំអ្វីខ្លះដល់លោក?

**ឆៈ** ការណែនាំដូចបានបញ្ជាក់ដែរ គឺនៅលើមូលដ្ឋានដដែល។ មូលដ្ឋានទីមួយ គឺមូលដ្ឋានឃោសនាក្រោយសង្គ្រាមនេះ ធ្វើម៉េចប្រជាជនរួមគ្នាបង្កបង្កើនផលឧបត្ថម្ភខ្លួនឲ្យបាន។ ទីពីរ រួមគ្នាធ្វើ

ទំនប់ប្រឡាយ ដើម្បីធ្វើស្រែឲ្យបានពីរទៅបីដង។ ហើយបានទីបីហ្នឹង លើកស្ទួយជីវភាព ខំធ្វើម៉េចឲ្យបានលើកស្ទួយជីវភាពឲ្យបានខ្ពស់ ប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ តើរវាងលោក និង តាស៊ី លោកមានធ្លាប់ធ្វើរបាយការណ៍ផ្ញើជូន តាស៊ីដែរឬទេ? បើមានតើរបាយការណ៍ហ្នឹងធ្វើរយៈពេលប៉ុន្មានម្តង?

**ឆ៖** ខ្ញុំធ្វើរបាយការណ៍ក៏ដោយ អីក៏ដោយ ត្រូវឆ្លងតំបន់ ពីរឿងលទ្ធផលការងារ ហើយប៉ុន្មានដងមិនចាំទេ។

[១១:៣០:០៥]

**ស៖** អរគុណ។ តើរបាយការណ៍របស់លោកហ្នឹងមានទម្រង់ដូចម្តេច? ទម្រង់វែង ទម្រង់ខ្លី ហើយជាទូទៅប្រហែលជាប៉ុន្មានទំព័រ? ហើយខ្លឹមសារសំខាន់នៅក្នុងរបាយការណ៍លោកផ្តោតទៅលើអ្វីជាសំខាន់?

**ឆ៖** របាយការណ៍នុ៎ង ក្នុងពេលនុ៎ង ក្នុងកាលៈទេសៈនុ៎ង ភាគច្រើនគេសរសេរនឹងក្រដាសសៀវភៅទេ។ ហើយក្រដាសសៀវភៅសរសេរដោយដៃ ទៅតាមសារៈសំខាន់ជូនគណៈតំបន់ទៅ មានរបាយការណ៍ថាធ្វើស្រែបានប៉ុណ្ណេះៗ ធ្វើទំនប់បានប៉ុណ្ណេះ សន្តិសុខនៅក្នុងភូមិឃុំមិនមានអីទេអីចឹងបាទ។ ហើយជួនកាលគ្រាន់តែ របាយការណ៍ថាឥឡូវសំណូមពរសូមឲ្យជួយអំបិល ជួយអង្ករអីទៅព្រោះភូមិនេះអត់។ បាទ មានប៉ុណ្ណឹង។

[១១:៣១:១៤]

**ស៖** អរគុណ។ នៅក្នុងពេលដែលលោកស្ថិតនៅក្នុងតំបន់១៥ ឬតំបន់៣២ អំឡុងពេលដែលលោកស្ថិតនៅក្នុងតំបន់១៥ ឬ៣២ ហ្នឹង តើលោកធ្លាប់បានគេតែងតាំងឲ្យធ្វើជាមេ ឬក៏ប្រធានណាមួយដែរឬទេ?

**ឆ៖** ខ្ញុំជាទូទៅគឺបានខាងឃោសនាហ្នឹងហើយ ឃោសនាអប់រំហ្នឹងហើយ។ តែងតាំងឲ្យនិយាយឃោសនាអប់រំ ឬក៏ក្នុងការប្រជុំរួមលើកគ្នាទៅច្រូត លើកគ្នាទៅធ្វើទំនប់ ហ្នឹងខ្ញុំនិយាយហើយបាទ។ មានប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ តើលោកធ្លាប់បានត្រូវបានគេតែងតាំងឲ្យធ្វើជាជំនួយការលេខាតំបន់១៥ ឬក៏៣២ ក្នុងរយៈពេលខ្លី ឬក៏វែង ឬក៏មធ្យមណាមួយដែរឬទេបាទ? មានធ្លាប់ទេបាទ?

**ឆ៖** ជាទូទៅ ខ្ញុំបានទទួលការអនុវត្តដូចបានជម្រាបខាងដើមអំមិញអីចឹង ឯការកត់ត្រា គេមិន

បានកំណត់ថាជាលេខាអីទេ គ្រាន់ថាអ្នកណាចេះអក្សរ ចេះលេខទទួលការកត់ត្រាបានច្បាស់ ក៏កត់ទៅម្តងម្កាលទៅ ឯថាឲ្យទៅជាលេខាអីអត់ ជាផ្លូវការអីគ្មានទេបាទ។

[១១:៣៣:១០]

**ស៖** បាទ សូមអរគុណ។ តើអ្នកណាជាសមាជិកគណៈកម្មាធិការតំបន់១៥ ឬក៏៣២? តើលោកធ្លាប់ស្គាល់ទេ អ្នកណាខ្លះជាសមាជិកគណៈកម្មាធិការតំបន់១៥ ឬក៏តំបន់៣២ បាទ?

**ឆ៖** សមាជិកហ្នឹង គឺគេភាគច្រើន គេយកអ្នកណាដែលទទួលខុសត្រូវតាមស្រុក គេបញ្ចូលជាសមាជិកហើយ។ ហ្នឹងគេហៅសមាជិក។ ឧបមាដូចឈ្មោះ តានៅៗ ហ្នឹង ហ្នឹងគេហៅសមាជិកហើយបាទ។ ហើយចាំមិនអស់ទេឥឡូវ។ និយាយរួមគឺឲ្យតែលេខាស្រុកហ្នឹង អ្នកទទួលខុសត្រូវស្រុកហ្នឹងគេធ្វើជាសមាជិកហើយ។

**ស៖** បាទ អរគុណ។ ហេតុ-- តើមានហេតុផលអីបានជាគេជ្រើសរើសយកលេខាស្រុក ឬក៏អ្នកទទួលខុសត្រូវស្រុកធ្វើជាសមាជិកនៃគណៈកម្មាធិការតំបន់១៥ ឬក៏៣២ នេះ?

**ឆ៖** ហេតុផលនុ៎ងខ្ញុំមិនយល់ទេ ពីព្រោះខ្ញុំយល់តែត្រង់ថា តែបីឃុំ គេហៅស្រុក តែបីស្រុក គេហៅតំបន់។ នេះជារបៀបរបបគ្រប់គ្រងរដ្ឋបាល។ ដូច្នេះ អ្នកណាធ្វើប្រធានហ្នឹង គេជាស្វ័យប្រវត្តិវាត្រូវទៅជាសមាជិក។ បាទ ខ្ញុំដឹងប៉ុណ្ណឹងបាទ។

[១១:៣៤:៥៣]

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់បន្ថែមអំពីរចនាសម្ព័ន្ធនៅតំបន់៣១។ សូមជួយបញ្ជាក់បន្ថែមអំពីរចនាសម្ព័ន្ធនៃតំបន់៣១ តើរចនាសម្ព័ន្ធនៃតំបន់៣១ ហ្នឹង ត្រូវបានគេរៀបចំបង្កើតឡើងយ៉ាងដូចម្តេច? ហើយអ្នកណាជាអ្នកទទួលខុសត្រូវដ៏ចម្បងសំខាន់បំផុតនៅក្នុងតំបន់នោះ?

**ឆ៖** រចនាសម្ព័ន្ធតំបន់៣១ ខ្ញុំដឹងដូចបានជម្រាបជូនថា តា សារុន តែក្រៅពីហ្នឹងអត់ដឹងទេ។

**ស៖** បាទ អរគុណ។

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំសូមលោកប្រធាន ខ្ញុំមានសំណួរ បីសំណួរចុងក្រោយបាទ មុននឹងខ្ញុំបញ្ចប់ការសួររបស់ ខ្ញុំហើយនិងជូនទៅសហការីរបស់ខ្ញុំដើម្បីសួរបន្តបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរ បីសំណួរចុងក្រោយ ដើម្បីឲ្យលោកឆ្លើយសំណួររបស់ខ្ញុំបាទ

សូមបន្តសំណួរបាទ។ សំណួរទីមួយ គឺតើលោកអាចបញ្ជាក់បានទេ អំពីរចនាសម្ព័ន្ធនៃតំបន់៣៧ តើតំបន់៣៧ហ្នឹងមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងយ៉ាងដូចម្ដេច? ៣៧ បាទ?

**ឆ៖** ជម្រាបជូន តំបន់៣៧ហ្នឹង ខ្ញុំរឹតតែអត់ដឹងហើយបាទ។

[១១:៣៦:៣១]

**ស៖** បាទ សូមសួរមួយទៀត សំណួរទីពីរចុងក្រោយ។ តើ-- លោកបញ្ជាក់អំមិញថាលោកធ្លាប់ធ្វើជាលេខាកត់ត្រាពេលប្រជុំម្ដងម្កាលនៅក្នុងពេលប្រជុំតំបន់៣២ និងតំបន់១៥។ តើនៅពេលនុ៎ងតើលោកមានបានដឹងអំពីផែនការវ៉ៃយកក្រុងភ្នំពេញរបស់កងទ័ពបដិវត្តន៍ដែរឬទេ? ហើយអ្នកចូលរួមនៅពេលនោះ មានអ្នកណាខ្លះ? តើលោកមានបានដឹងអំពីផែនការវាយយកក្រុងភ្នំពេញបាទ ហើយអ្នកចូលរួមពេលនុ៎ងមានអ្នកណាខ្លះ?

**ឆ៖** បាទខ្ញុំដឹងតែការផ្សព្វផ្សាយរួមថា ត្រូវតែប្រមូលកម្លាំងវ៉ៃសម្រុកយកក្រុងភ្នំពេញ។ ហើយយកមកផ្សព្វផ្សាយក្របខ័ណ្ឌអ្នកឃោសនា ដើម្បីកៀងគរប្រជាជនចូលរួម។ ឯរឿងអ្នកប្រជុំ អ្នកណាប្រជុំ ខាងលើប្រជុំយ៉ាងម៉េចៗ អាហ្នឹងហួសសមត្ថភាពខ្ញុំហើយ ខ្ញុំមិនដឹងទេ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមអនុញ្ញាត សួរសំណួរទីបីជាសំណួរចុងក្រោយរបស់ខ្ញុំ សំណួរទីបីគឺសំណួរចុងក្រោយ។ សូមលោកមេត្តាជួយបញ្ជាក់ឲ្យបានច្បាស់អំពីការប្រាស្រ័យទាក់ទង ទំនាក់ទំនងរវាងតំបន់៣១ និងថ្នាក់ស្រុក និងថ្នាក់ឃុំ តើការប្រាស្រ័យទាក់ទងគ្នានេះប្រើមធ្យោបាយអ្វីខ្លះ? ខ្ញុំអាចបញ្ជាក់ជូន ថាតើគេអាចប្រើមធ្យោបាយសាទូរលេខ ជាការជួបប្រជុំគ្នា ជាការជួបផ្ទាល់ ឬក៏ការបញ្ជូនព័ត៌មានតាមបុគ្គលជានីរសារជាដើម។ល។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់អំពីការទំនាក់ទំនងរវាងថ្នាក់តំបន់៣១ និងថ្នាក់ឃុំ ថ្នាក់ស្រុក តើគេប្រើមធ្យោបាយណាដើម្បីទំនាក់ទំនងគ្នាក្នុងការធ្វើកិច្ចការ-- ក្នុងអតីតកាលដែលលោកបានបញ្ជាក់ ក្នុងនាមដែលលោកជាសាក្សីដ៏សំខាន់នៅក្នុងរឿងនេះបាទ? សូមអរគុណ។

**ឆ៖** អ្ហ៎!ខ្ញុំអាចបញ្ជាក់ជូនបាន តាមការយល់ តាមការឃើញ ដឹងរបស់ខ្ញុំដូចតទៅនេះ៖ ទីមួយក្នុងសភាវៈ-- ក្នុងសភាពការណ៍នៃសង្គ្រាមពេលនោះ មធ្យោបាយទាក់ទងសំខាន់បំផុត គឺមនុស្សដើរក្រោយមកជិះម៉ូតូយកសំបុត្រពីកន្លែងមួយ ទៅកន្លែងមួយ នេះជាសំខាន់។ ឯប្រព័ន្ធទូរស័ព្ទ ប្រព័ន្ធតេអូប្រព័ន្ធទូរលេខអី គ្មានទេ។ ទើបមានមកចុងក្រោយ ដែលសង្គ្រាមកើតឡើងម្ដងទៀតដែលកងទ័ពវ៉ៃចូលនេះបានមាន។ តែមានហ្នឹង ទៅតាមថ្នាក់ទៀត មិនមែនចេះតែមានទេ ពីព្រោះវាចោទបញ្ហាឧបករណ៍

ចោទបញ្ហាអីៗច្រើន ហើយចោទបញ្ហាសម្ងាត់។ ដូច្នេះ គ្មានទេ មានតែជិះកង់ ជិះម៉ូតូ ទាក់ទងគ្នាពីក្រោមទៅលើ ពីលើទៅក្រោម ភូមិមកឃុំ ឃុំទៅស្រុក ស្រុកទៅតំបន់។ ហ្នឹងជាទូទៅ គឺអ៊ីចឹងបាទ។ សូមអស់។

[១១:៤០:០០]

**លោក ច័ន្ទ តារាស្មី៖**

បាទ ក្នុងនាមខ្ញុំសហព្រះរាជអាជ្ញា ក្នុងនាមសហព្រះរាជអាជ្ញា ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក នី កន ដែលបានផ្តល់នូវការឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមកម្មវិធីសវនាការនៅពេលនេះ។ បាទ សូមអរគុណ។

សូមអរគុណ លោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំសួរសំណួរទៅសាក្សីលោក នី កន នេះបាទ។ សូមអរគុណ។ ហើយជាបន្តខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីឲ្យលោក វាំងសង់ ឆ្លើយ-- សួរសំណួរបន្តទៀតទៅលោកសាក្សី ដោយសារពេលវេលារបស់ខ្ញុំមានកម្រិត។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:៤០:៣៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ និងជម្រាបសួរលោកសាក្សី។ មុនពេលឈប់សម្រាកនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបំភ្លឺទៅកាន់លោក។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** សំណួរទីមួយខ្ញុំចង់ដឹងថា តើមន្ទីររបស់លោក គឺមន្ទីរឃោសនានៅក្នុងតំបន់៣២នេះ ស្ថិតនៅឯណាដែរ? ថាតើស្ថិតនៅក្នុងស្រុកណា?

**លោក នី កន៖**

**ឆ៖** មន្ទីរសម្រាប់ឃោសនាអប់រំហ្នឹង គឺចល័ត។ ចល័តចុះចល័តឡើងក្នុងតំបន់១៥។ ឯឈ្មោះដែលកត់សម្គាល់បាន គឺគេហៅស្តុកគោល ហ្នឹងមួយ ឯពីរ អង្គរស្ស។ បាទ ដែលខ្ញុំចាំ ប៉ុណ្ណឹងបាទ។

**ស៖** គឺលោកនិយាយអំពីតំបន់១៥។ តើវាដូចគ្នាទេចំពោះតំបន់៣២នោះ? គឺលោកចល័តរហូត

ឬមួយក៏នៅពេលដែលមានវគ្គរៀនសូត្រ មនុស្សចូល-- ដែលមនុស្សច្រើនចូលរួមនោះ តើមានកន្លែងណាមួយដែលថា សម្រាប់ធ្វើការប្រជុំរៀនសូត្រនេះ?

**ឆះ** ក្នុងសង្គ្រាម តំបន់១៥ និង តំបន់៣២ ញែកពីគ្នា ចែកព្រំប្រទល់ពីគ្នា ហើយកន្លែងដែលគេតែងប្រជុំរៀនសូត្រ បានគ្នាច្រើន គេហៅស្តុកតោល។ ពីព្រោះកន្លែងនោះមានព្រៃ ការពារកប៉ាល់ហោះ បើអង្គរស្ស មិនអាចប្រមូលបានទេ។ ពីព្រោះនៅកណ្តាលវាលបាទ។

[១១:៤៣:១១]

**សះ** សូមអរគុណ។ អម្បាញ់មិញ លោកនិយាយអំពីកិច្ចប្រជុំធំៗ ដែលមានមនុស្សរាប់រយនាក់ចូលរួម ហើយលោកក៏បានចូលរួមដែរ នៅថ្នាក់ភូមិភាគ គឺនិយាយអំពីការបំពាក់បំប៉នមនោគម៌វិជ្ជាដល់មហាជន គឺមិនមែននៅតំបន់៣២ ទេ គឺភូមិភាគ។ តើកិច្ចប្រជុំធំដែលលោកបានចូលរួមនេះ ប្រព្រឹត្តទៅនៅឯណាដែរ ដែលមានមនុស្សរាប់រយនាក់ចូលរួមនេះ?

**ឆះ** សូមជម្រាបជូន កន្លែងមនុស្សដែលរាប់រយនាក់ចូលរួមក្នុងការទទួលការបំពាក់បំប៉នហ្នឹងគេភាគច្រើនគេហៅចម្ការដូង ចាន់ថ្នាល់បាទ។ ប៉ុណ្ណឹងបាទ។

**សះ** សូមអរគុណ។ តើចម្ការដូងមានទីតាំងនៅឯណាដែរ? តើនៅតំបន់៣១ ឬក៏៣២? នៅជិតកំពង់ស្ពឺ ឬក៏ជិតកំពង់ឆ្នាំង?

**ឆះ** ចម្ការដូង ឬហៅថា ចាន់ថ្នាល់ហ្នឹង វានៅជិតកំពង់ស្ពឺ វានៅក្នុងតំបន់៣២ បាទ។

[១១:៤៥:០០]

**សះ** សូមអរគុណ។ អម្បាញ់មិញនេះ តាសារុន គឺជាប្រធានតំបន់៣១ តើគាត់មានតួនាទីអីទេនៅភូមិភាគបស្ចិមនេះ ក្នុងឋានៈគាត់ដែលជាប្រធាននៃតំបន់៣១នេះ?

**ឆះ** ធម្មតា ដូចខ្ញុំបានជម្រាបអំពីរចនាសម្ព័ន្ធពេលនោះ ហើយពេលនេះ ខ្ញុំមិនសូវជាយល់ទេ។ បើមានឋានៈជាប្រធានតំបន់ វាត្រូវជាស្វ័យប្រវត្តិ វាជាសមាជិកភូមិភាគហើយ។ ដូច្នេះ នាទីអាចមួយសមាជិក មួយប្រធានតំបន់ បាទ។

**សះ** សូមអរគុណ។ មុនពេលដែលភូមិភាគពិសេសត្រូវបានលុបចោល ហើយបញ្ចូលទៅក្នុងភូមិភាគបស្ចិម។ តើលោកដឹងទេ ថាអ្នកណាជាលេខាភូមិភាគពិសេសនេះ?

**ឆះ** សូមជម្រាបជូនថានេះ វាពាក់ព័ន្ធនឹងលាក់ការណ៍សម្ងាត់ហើយ។ ដូច្នេះ ក្នុងពេលនុំង រឹតតែសម្ងាត់ទៀត។ អ្នកណាជាលេខា? អ្នកជាអីៗ មិនអាចដឹងបានទេ ហើយក៏មិនអាចស្គាល់រូបបាន

ទៀត។ ដូច្នេះសរុបទៅ ខ្ញុំមិនដឹងទេ មិនស្គាល់ទេ បាទ។

**ស៖** តើលោកដឹងទេ ថាបងរបស់លោកនោះ មានតួនាទីអ្វី-- មានតួនាទីនៅក្នុងគណៈកម្មាធិការនៃភូមិភាគពិសេសដែរឬទេ? នេះ ជាបងរបស់លោក ដូច្នេះប្រហែលជាវាមិនមានការសម្ងាត់ទេចំពោះលោក ព្រោះគាត់ជាបងលោក។ តើអ៊ីចឹងលោកដឹងទេ ថាបងរបស់លោកមានតួនាទីអីដែរនៅក្នុងគណៈកម្មាធិការភូមិភាគពិសេសនេះ?

[១១:៤៧:២៤]

**ឆ៖** ខ្ញុំសូមឆ្លើយ គឺខ្ញុំមិនច្បាស់ទេ តែខ្ញុំច្បាស់តែត្រង់ថា បងខ្ញុំនេះ ដឹកនាំខាងទាហាននៅក្នុងភូមិភាគហ្នឹង តែជាបុគ្គលទីប៉ុន្មានអីប៉ុន្មាន តួនាទីអីនៅក្នុងគណៈកម្មាធិការភូមិភាគពិសេសនេះ អត់ដឹងទេ បាទ។

**ស៖** តើលោកធ្លាប់ឮឈ្មោះ វន វ៉េត នៅក្នុងពេលដែលលោកមកដល់តំបន់១៥ នៃភូមិភាគពិសេសដែរឬទេ? គឺថានៅពេលដែលភូមិភាគនោះ នៅមាននៅឡើយ តើលោកស្គាល់ឈ្មោះ? ធ្លាប់ឮឬក៏ធ្លាប់ឮឈ្មោះ វន វ៉េត ដែរឬទេ?

**ឆ៖** បាទ ឈ្មោះនេះ ធ្លាប់ឮបាទ។

**ស៖** តើលោកអាចបានបញ្ជាក់បានទេ ថា វន វ៉េត ធ្វើអ្វីដែរ នៅក្នុងភូមិភាគពិសេសនេះ?

**ឆ៖** ចំពោះឈ្មោះ វន វ៉េត ឮ តែឲ្យដឹងថាតួនាទីច្បាស់លាស់ជាស្អី ដូចខ្ញុំជម្រាបខាងដើម មិនច្បាស់ទេ។ ខ្ញុំដឹងមិនច្បាស់ទេ។ អ៊ីចឹង ខ្ញុំមិនហ៊ានបញ្ជាក់ជូនបានទេ ពីព្រោះខ្ញុំមិនច្បាស់បាទ។

**ស៖** ក្រៅពីតំបន់១៥ តើមានតំបន់អ្វីផ្សេងទៀត ដែលស្ថិតនៅក្នុងភូមិភាគពិសេសនៅក្នុងសម័យនោះ?

[១១:៤៩:២២]

**ឆ៖** ខ្ញុំធ្លាប់បាននៅតំបន់១៥ហ្នឹង តាំងពីចុះពីលើមក ចុះពីមកចូលរួមក្នុងតំបន់១៥ហ្នឹង ខ្ញុំឮតែឈ្មោះ គេឲ្យឈ្មោះថា តំបន់១៥ៗ មួយគត់នេះ អត់មានឮឯណាទៀតទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីកាលប្រវត្តិនៃហេតុការណ៍មុនឆ្នាំ-- មុនខែមេសា ឆ្នាំ៧៥។ លោកបាននិយាយអម្បាញ់មិញថា លោកបានចាប់ផ្តើមធ្វើការនៅឆ្នាំ៦៦ ក្នុងឋានៈជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយ ហើយលោកបាននិយាយថាលោកបានធ្វើកម្មសិក្សាក្នុងរយៈពេលមួយឆ្នាំ។ បន្ទាប់មកលោកចូលទៅបដិវត្តន៍ក្រោយពីមានរដ្ឋប្រហារ តើលោកធ្វើអ្វីដែរនៅក្នុងចន្លោះឆ្នាំ៦៧ ហើយ

និងឆ្នាំ៧០ នៅក្នុងពេលមានរដ្ឋប្រហារនោះ គឺថាខ្ញុំមិនបានយល់អំពីការងាររបស់លោកនៅក្នុងអំឡុងរយៈពេលបីឆ្នាំនេះទេ។

**ឆ៖** ក្នុងចន្លោះហ្នឹង ខ្ញុំអត់មានធ្វើអីជាដុំកំភួនទេ។ ខ្ញុំបានតែទទួលការឃោសនាអប់រំឱ្យកៀងគរ កម្លាំងសម្ងាត់ឱ្យចូលតស៊ូ ហៅថា “ម៉ាគី”។ បានតែប៉ុណ្ណឹងទេ ចន្លោះហ្នឹង អត់មានបានធ្វើសកម្មភាពចំហអីទេ។

**សៈ** ដូច្នេះគឺមានន័យថាលោកចូលទៅក្នុងចលនាបដិវត្តន៍រួចទៅហើយ ចាប់ពីពេលដែលលោកបានបញ្ចប់ការងារនៅកំពង់ក្ដី គឺនៅឆ្នាំ៦៧ អ៊ីចឹងមិនមែនឆ្នាំ៧០ទេ។ គឺមានន័យថា លោកបានចាប់ផ្ដើមចូលបដិវត្តន៍ហើយ ធ្វើឱ្យបដិវត្តន៍ហើយ ចាប់តាំងពីឆ្នាំ៦៧មក តើមែនទេ?

**ឆ៖** មិនមែនទេ គ្រាន់តែគេហៅជាចលនាខ្សឹបខ្សៀវពីមួយទៅមួយអ៊ីចឹងទៅ រួចហើយមិនទាន់ប្រកាសប្រាកដ ថាធ្វើអីប្រាកដទេ។ ហើយដល់ពេលនិយាយតៗគ្នាអ៊ីចឹងទៅ ដល់ពេលឃើញរដ្ឋប្រហារពិតប្រាកដបានចាប់ប្រឡូកមែនទែន ចូលមែនទែនបាទ។

[១១:៥២:៤២]

**សៈ** តើលោកបានចូលចលនានេះមុនពេលរដ្ឋប្រហារមែនដែរឬទេ បន្ទាប់ពីលោកបានបញ្ចប់ការងាររបស់លោកដែលមានរយៈពេលមួយឆ្នាំពី៦៦ មកនោះ តើលោកចូលចលនានេះតែម្ដង ឬក៏ម៉េច?

**ឆ៖** ខ្ញុំយូរពេក ខ្ញុំមិនចាំអស់។ តែខ្ញុំធ្វើគ្រូវាបានរយៈពេលខ្លីដែរ ចេញពីភ្នំពេញទៅ។ រួចហើយដល់ពេលចលនាហ្នឹងគេចាប់ផ្ដើមទៅ គឺក្រោយពីមានការធ្វើរដ្ឋប្រហារជាទូទាំងប្រទេសហើយ ពេលហ្នឹងបានខ្ញុំមកភ្ជាប់ជាមួយនឹងចលនាហ្នឹង តែពីមុនអត់ទេ អត់មានច្បាស់លាស់អីទេបាទ។ មិនទាន់បានចូលជាអង្គការបដិវត្តន៍អីច្បាស់លាស់អត់ទេ មិនទាន់មានទេ។

[១១:៥៣:៤៣]

**សៈ** អ៊ីចឹងគឺមានន័យថា លោកមិនមានធ្វើការអីធំដុំទេនៅចន្លោះឆ្នាំ៦៧ ដល់ឆ្នាំ៧០ នេះ។ សំណួរតើលោកមានធ្វើដំណើរទៅណាទេនៅក្នុងប្រទេសហ្នឹង ឬក៏លោកនៅតែមួយកន្លែង ឬក៏នៅតែតំបន់តែមួយ?

**ឆ៖** ខ្ញុំសូមឆ្លើយ គឺខ្ញុំចល័តចុះចល័តឡើងនៅតែស្រុកសៀមរាបហ្នឹង ក្នុងស្រុកសៀមរាប។ ហើយ-- ក្នុងខេត្តសៀមរាប ហើយក្នុងខេត្តសៀមរាបហ្នឹងមានប៉ុន្មានស្រុក ខ្ញុំចុះឡើងនៅម្ដុំហ្នឹង។ សូមឆ្លើយប៉ុណ្ណឹងបាទ។ ឯទៅឯណាវែងឆ្ងាយអីមិនដែលបានទៅទេ ដល់ចាប់ពី៧០ រដ្ឋប្រហារនេះបានចាប់

ផ្តើម។

**ស៖** អម្បាញ់មិញនេះលោកក៏បាននិយាយផងដែរថា បន្ទាប់ពីមានរដ្ឋប្រហារគឺថា លោកបានចូលរួមនៅក្នុងចលនាបដិវត្តន៍ពិតប្រាកដ គឺថាលោកបានធ្វើការប្រហែលជាមួយឆ្នាំនៅខេត្តសៀមរាបដើម្បីឃោសនាអប់រំមហាជន។ ហើយលោកបាននិយាយផងដែរថា លោកបានទៅ-- ចូលទៅតំបន់១៥នៃភូមិភាគពិសេសនៅចុងឆ្នាំ៧៤ បើខ្ញុំគណនាទៅគឺថា ៧០ ដល់ ឆ្នាំ៧៤ មានរយៈពេលប្រហែល៤ឆ្នាំ។ ហើយលោកបាននិយាយថា ធ្វើការតែមួយឆ្នាំទេនៅខេត្តសៀមរាប។ តើលោកអាចបញ្ជាក់អំពីចំណុចនេះបានទេថា នៅចន្លោះឆ្នាំ៧០ និងចុងឆ្នាំ៧៤នោះ តើលោកធ្វើអ្វីខ្លះ?

[១១:៥៥:៣៧]

**ឆ៖** សូមឆ្លើយ គឺរយៈពេលយូរខ្ញុំចាំមិនអស់ តែចន្លោះហ្នឹង ខ្ញុំធ្វើការចុះឡើយតែរវាងខេត្តសៀមរាប។ ហើយចេញពីខេត្តសៀមរាបមក បានមានការ-- សង្គ្រាមផ្ទុះខ្លាំងទៅ បានខ្ញុំបានចេញពីនុំងមកៗមកចូលតំបន់១៥ហ្នឹងតែម្តង។ ប៉ុន្តែ ចន្លោះពេលហ្នឹង ខ្ញុំវាចាំមិនអស់ដែរ ចុះឡើងៗនៅម្តុំហ្នឹងបាទ។

**ស៖** នៅសម័យនោះ នៅពេលដែលលោកធ្វើការឃោសនាអប់រំមហាជននៅខេត្តសៀមរាប តើលោកទៅកាន់មុខងារខាងយោធាដែរឬទេ? ឬមួយក៏លោកគ្រាន់តែជាជនស៊ីវិលនៅក្នុងបក្ស?

**ឆ៖** ខាងយោធា ឬហៅថា ទាហាន ខ្ញុំអត់ទេ ខ្ញុំនៅតែខាងផ្នែកស៊ីវិលបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន នៅពេលនេះគឺជិតពេលថ្ងៃត្រង់ហើយ ខ្ញុំចង់ចូលទៅកាន់ជំពូកមួយទៀត ដូច្នេះតើយើងគួរតែសម្រាកសិន ឬក៏បន្តទៀតលោកប្រធាន? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកបន្តទៀតទៅ រហូតដល់ចប់ពេលវេលាដែលបានកំណត់ទៅ តាមលទ្ធភាពដែលអាចធ្វើទៅបាន។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមើលទៅឃើញសល់តែពីរនាទីទៀតទេ។

[១១:៥៧:៥៥]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមសួរសំណួរទៅកាន់សាក្សី។ មុនឆ្នាំ២០០៤ គឺមុនពេលដែលអ្នកស៊ើបអង្កេត នៃ អ.វ.ត.ក ទៅសម្ភាសលោក ទៅស្តាប់ចម្លើយលោក គឺខ្ញុំគិតថា នៅឆ្នាំ២០០៧ អ៊ីចឹងមុនឆ្នាំ២០០៤ នៅពេលដែលអ្នកស៊ើបអង្កេតទៅសួរសំណួរលោក តើលោកមានធ្លាប់ជួបអ្នកសារព័ត៌មាន ដែលជាអ្នកនិពន្ធអង់គ្លេសដែលធ្វើការឲ្យ ប៊ី.ប៊ី.ស៊ី ដែលមានឈ្មោះថា ហ្វីលីព ស្សូត ដែរឬទេ? តើលោកមានចាំទេថាលោកបានជួបគាត់?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ខ្ញុំមិនចាំទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

នៅក្នុងសំណុំរឿងគឺមានសៀវភៅមួយ ដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០០៤ ដោយលោក ហ្វីលីព ស្សូត ដែលមានចំណងជើងថា "ប៉ុល ពត ប្រវត្តិនៃសុបិនអាក្រក់" ដែលមានលេខ E8/9 ឬក៏លេខ D222/1.1។ ឯកសារនេះមិនមានជាភាសាខ្មែរទេ មានតែជាភាសាបារាំង និងភាសាអង់គ្លេស។ ដូច្នេះ ខ្ញុំមិនបង្ហាញឯកសារនេះ ជូនសាក្សីទេ ព្រោះថាអត់មានភាសាខ្មែរ ក៏ប៉ុន្តែដើម្បីឲ្យសាក្សីមានការចងចាំនោះ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះ ក្នុងការអាននូវសម្រង់ខ្លីៗចេញពីសៀវភៅនេះ ដែលលោក ហ្វីលីព ស្សូត បានលើកឡើងអំពីសេចក្តីប្រកាសរបស់សាក្សី នី កន ដែលជាប្អូនប្រុសរបស់ សុន សេន ដើម្បីឲ្យសាក្សីរូបនេះ ឆ្លើយតបទៅនឹងការលើកឡើងនៅក្នុងសៀវភៅរបស់លោក ហ្វីលីព ស្សូត នេះ។ តើលោកប្រធានអនុញ្ញាតទេ?

[១១:៥៩:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជាដំបូងគឺនៅទំព័រ ERN ជាភាសាអង់គ្លេស 00396185 ឯកសារនេះមិនមានការបក-- ទំព័រនេះមិនមានការបកប្រែជាភាសាបារាំងទេ។ គឺនៅជំពូកសេចក្តីថ្លែងអំណរគុណ នៅដើមសៀវភៅនេះ លោក ហ្វីលីព ស្សូត បានថ្លែងអំណរគុណដល់អ្នកដែលគាត់បានសួរ ហើយខ្ញុំនឹងដកស្រង់នូវអ្វីដែលគាត់បានលើកឡើងនៅក្នុងសៀវភៅនេះជាភាសាអង់គ្លេស៖ "មេដឹកនាំខ្មែរក្រហមមួយចំនួនបាន

និយាយអំពីប្រវត្តិរបស់ពួកគាត់ គឺមាននិយាយការដែលកើតឡើងក្នុងរយៈពេលជាច្រើនខែ ក្នុងនោះមាន អតីតប្រមុខរដ្ឋ ខៀវ សំផន បងថ្លៃរបស់ ប៉ុល ពត ហើយមានឧបនាយករដ្ឋមន្ត្រី អៀង សារី, នី កន ដែលប្អូន-- ដែលបងរបស់គាត់លោក សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ"។ សូមបញ្ចប់ការដកស្រង់។

[១២:០១:១០]

ហើយអ្នកនិពន្ធនេះក៏បានលើកឡើងអំពីឈ្មោះ ភី ភួន, សួង ស៊ីគឿន និង អ៊ិន សុភាព ផងដែរ។ លោកសាក្សី តើលោកមាននឹកឃើញទេ អំពីសៀវភៅនេះ ហើយលោកអាចនិយាយបានទេថា លោកធ្លាប់ជួប ហ្វីលីព ស្សូត ហើយលោកបានរៀបរាប់អំពីខ្សែជីវិតរបស់គាត់ទៅឱ្យអ្នកសារព័ត៌មានហើយ និងជាអ្នកនិពន្ធសៀវភៅរូបនេះ?

**លោក នី កន៖**

**ឆ៖** សូមបញ្ជាក់ជូន ខ្ញុំមានសម្ភាសម្តងដែរ តែខ្ញុំមិនចាំថាអ្នកមកសម្ភាសខ្ញុំហ្នឹងឈ្មោះអីទេ។ បាទប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអានអត្ថបទដកស្រង់មួយទៀត។ ជាភាសាបារាំង គឺ ERN 00639630 គឺនៅទំព័រ១៩១ នៃសៀវភៅនេះ។ ជាភាសាអង់គ្លេស 00396347 នៅទំព័រ១៤៧។ លោក ហ្វីលីព ស្សូត បាននិយាយពាក់ព័ន្ធទៅនឹងសេចក្តីចម្លងនៃអត្ថបទដែលធ្វើឡើងដោយខ្មែរក្រហមនៅក្នុងព្រៃជាមួយនឹងមធ្យោបាយជាបឋម។ ខ្ញុំសូមដកស្រង់ដូចតទៅនេះ៖ "ប្អូនរបស់ សុន សេន ឈ្មោះ នី កន បាននឹកឃើញថា នីរសារបានលាក់អត្ថបទនៅក្នុងធំ ឬក៏នៅក្នុងក្រឡប្រហុក ឬក៏មួយមូលអត្ថបទទាំងនេះដាក់នៅក្នុងបំពង់ឫស្សីដើម្បីកុំឱ្យនគរបាលរបស់ សីហានុ រកឃើញ"។ សូមបញ្ចប់ការដកស្រង់។

[១២:០៣:២២]

ហើយនៅទំព័រដដែលនេះជាភាសាបារាំង ប៉ុន្តែនៅចុងទំព័រ-- គឺនៅភាសាអង់គ្លេសនៅចុងសៀវភៅ គឺមានលេខ ERN 00396699 ដោយមានការបញ្ជាក់ថា៖ "រឿងរ៉ាវនៃដំណើរការនៃរោងពុម្ព គឺមានរៀបរាប់ដោយ នី កន គាត់បានធ្វើការនៅទីនោះនៅចុងឆ្នាំ៦៧-- ពីឆ្នាំ៦៧ រហូតទៅដល់ដើមឆ្នាំ-- ពាក់កណ្តាលឆ្នាំ៦៨ មុននឹងគាត់ត្រូវបានផ្ទេរទៅរតនគិរី"។ សូមបញ្ចប់ការដកស្រង់នៃកំណត់សម្គាល់ចុងទំព័រនេះ។ លោកសាក្សី តើលោកមានធ្លាប់បាននិយាយទៅកាន់ជនបរទេសមួយរូបដែលជាលោក ហ្វីលីព ស្សូត នេះ អំពីរបៀបដែលគេបោះពុម្ពឯកសារនៅក្នុងព្រៃមុនឆ្នាំ៧០ ហើយនិងរបៀបដែលគេនាំ

អត្ថបទទាំងអស់នោះដោយនីរសារដែរឬទេ?

[១២:០៤:៣៦]

**ឆ៖** ខ្ញុំសូមឆ្លើយ នេះជារឿងដែលនិយាយតៗគ្នា។ ហើយដល់ពេលមានការសម្ភាស ខ្ញុំក៏បញ្ជាក់ជូនជាពិសោធន៍អ៊ីចឹងជូនមែនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅក្នុងអំឡុងពេលឈប់សម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០៥:៤៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំសូមសំណើតុលាការដើម្បីតាមដានសវនាការនៅក្នុងបន្ទប់ខាងក្រោមនៅពេលល្ងាចនេះ ហើយគាត់បោះបង់សិទ្ធិក្នុងការវត្តមានដោយផ្ទាល់នៅក្នុងសាលសវនាការនេះ ហើយខ្ញុំនឹងជូនឯកសារសំណើនេះជូនតុលាការដើម្បីសម្រេចក្នុងពេលនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលថ្ងៃរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយក្រុមមេធាវីការពារក្តីបានសន្យាថា ខ្លួននឹងប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សូមទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅពីក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍

សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:០៦:៥៤]

អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដី នួន ជា ប្រគល់មកអង្គជំនុំជម្រះ-- មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដែលធ្វើឡើងដោយ និងចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះ ក្នុងអំឡុងពេលកិច្ចដំណើរការសវនាការបន្តធ្វើសម្រាប់រសៀលនេះ។

ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ព្រមទាំង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យ នួន ជា បន្តតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមតាមរយៈឧបករណ៍សោតទស្សន៍។ ដោយឡែក ឲ្យនាំលោក ខៀវ សំផន មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៣:៣៣:១២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** មុននឹងពេលសម្រាកថ្ងៃនេះ ខ្ញុំបានអានសម្រង់ទីមួយនៃសៀវភៅរបស់លោក ហ្វីលីព ស្បូត ដែលជាមានចំណងជើងថា "ប្រវត្តិអាក្រក់នៃ-- សុបិនអាក្រក់"។ លោកសាក្សីបាននិយាយថា "លោកបានគ្រាន់តែថា និយាយរៀបរាប់ឡើងវិញអំពី-- ទាក់ទងទៅនឹងចំណាប់អារម្មណ៍របស់ខ្លួន-- ទាក់ទងទៅនឹងពេលដែលគាត់ទៅក្នុងព្រៃម៉ាគី ហើយទាក់ទងនឹងឯកសារដែលបញ្ជូនដោយនីរសារ"។ ខ្ញុំចង់បានប្រតិកម្មរបស់ទាក់ទងទៅនឹងកំណត់សម្គាល់ជើងទំព័រ ដែលខ្ញុំបានអានអម្បាញ់មិញនេះ ដែល លោក ហ្វីលីព ស្បូត បានលើកឡើងថា "លោកទៅធ្វើការពីឆ្នាំ-- ចុងឆ្នាំមួយពាន់ប្រាំមួយហុក-- ១៩៦៧ ដល់ ៦៨ នៅក្នុងរោងពុម្ពនៅក្នុងព្រៃម៉ាគី ហើយបន្ទាប់ពីពេលដែលរោងពុម្ពនេះបានធ្វើផ្ទេរទៅរតនគិរីវិញ"។ តើលោកអាចជម្រាបបានទេថា ចន្លោះ៦៧ ដល់៦៨ នោះលោកធ្វើការនៅរតនគិរី គឺថាធ្វើការនៅក្នុងការបោះពុម្ពឯកសារនៅក្នុងព្រៃម៉ាគី? អ៊ីចឹងមែនទេ?

[១៣:៣៤:៣៣]

**លោក នី កន៖**

**ឆ៖** សូមគោរពលោកប្រធាន។ ចំពោះសំណួរនេះ គឺជាសំណួរដែលទាក់ទងនឹងការសម្ភាសរបស់ខ្ញុំ ហើយខ្ញុំក៏ចាំមិនអស់ដែរ។ ដូច្នេះការសម្ភាសហ្នឹង ខ្ញុំក៏ពេលខ្លះភ្ជាប់របៀបរឿងនិទាន ឬការនិយាយតៗគ្នាដែលឮយកមកបញ្ជាក់ ហើយក៏មិនបានគិតគូរថាជាការយល់ដឹង ជាការទទួលខុសត្រូវអីទេ ទៅតាមការដែរសម្ភាស ក៏សម្ភាសជាឯកជន ខ្ញុំក៏ឆ្លើយជាឯកជន។ ហើយសួរថាតើខ្ញុំបានទទួលខុសត្រូវរឿងរោងពុម្ពទេ? ខ្ញុំបានចូលរួមជាបុគ្គលម្នាក់ដែលចេះអក្សរ ចេះអីហ្នឹងក៏ធ្វើការអូសទាញឯកសារដែលទទួលពីលើទៅអ៊ីចឹងមែនបាទ។ ហើយការផ្លាស់ប្តូរក៏មាន ការផ្លាស់ប្តូរទីកន្លែងទៅតាមសភាពនៃសង្គ្រាម បើកន្លែងណាវាមិនធានាក៏ចេញពីកន្លែងហ្នឹងទៅកន្លែងមួយទៀត។ ហើយហៅថារោងពុម្ពនោះ មិនមែនជារោងពុម្ពអីធំដុំទេ ស្ពាយនឹងសាក់កាដូទេ ហើយដាក់សាក់កាដូ ដាក់ស្បែកជើងផ្ទាត់ហ្នឹងទៅ ហើយគេហៅអី *ស្តាំងស៊ីល* ហ្នឹងទៅ ក៏ទៅអូសទៅបាទ។ នេះសូមជម្រាបជូនប៉ុណ្ណឹងបាទ។

[១៣:៣៦:៤០]

**ស៖** បាទដើម្បីបំភ្លឺបញ្ហានេះ ព្រោះថាលោកបាននិយាយថា ដាក់យកសម្ភារៈនៅក្នុងសាក់កាដូ ហើយយើងទៅកន្លែងផ្សេងដើម្បីបោះពុម្ព តើនៅពេលនោះលោកធ្វើការក្នុងការបោះពុម្ពឯកសារនៅក្នុងរយៈពេលបន្ទាប់មក បន្ទាប់ពីការធ្វើរដ្ឋប្រហារនៅខែមីនា ឆ្នាំ១៩៧០ ដែរឬទេ?

**ឆ៖** បាទ ទទួល។ ខ្ញុំជាបុគ្គលិក ដែលអ្នកសរសេរនោះ ត្រូវជាអ្នកសរសេរអក្សរស្អាត។ ឯខ្ញុំគ្រាន់អ្នកអូសទៅឲ្យចេញជាឯកសារទៅ ហើយសំណួរលោកសួរហ្នឹង គឺខ្ញុំដំណើរតាមហ្នឹងទេបាទ។

**ស៖** តើលោកជាអ្នកសរសេរឯកសារទាំងអស់នោះ? ព្រោះថាលោកនិយាយថា លោកជាអ្នកសរសេរអក្សរស្អាត តើលោក ឬក៏អ្នកផ្សេង អ្នកសរសេរអក្សរស្អាតនុ៎ង?

**ឆ៖** សូមជម្រាប ខ្ញុំមានមតិអម្បាញ់មិញ បែបលោកស្ដាប់មិនទាន់។ ខ្ញុំអ្នកអូស ឯអ្នកសរសេរនោះគឺម្នាក់ទៀត គេអក្សរល្អបាទ។ មិនមែនខ្ញុំទេបាទ។

**ស៖** បាទ សូមអរគុណ។ បាទ លោកបាននិយាយថាលោកបានធ្វើការរយៈពេលមួយឆ្នាំនៅខេត្តសៀមរាប គឺថាចន្លោះឆ្នាំ១៩៦៦ ដល់៦៧ ហើយបន្ទាប់មកទៀត លោកបានធ្វើដំណើរនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោក ដែលជាអ្នកអូសឯកសារនេះនៅខាងភូមិភាគពាយ័ព្យដែរឬទេ? លោកធ្លាប់បានធ្វើដំណើរនេះដែរឬទេ?

[១៣:៣៩:០៤]

**ឆ៖** សូមជម្រាបជូនលោកប្រធាន។ ការអូសនេះ គឺអូសឯកសារនេះ គឺអូសនៅភូមិភាគខាងនេះហើយ កណ្ដាលហើយ ចុះមកកណ្ដាល ខាងកំពង់ចាម។ ហើយក្រោយមកចុះមកត១មក១ខាងជិតខាងពាយព្យហើយបាទ។ សូមឆ្លើយប៉ុណ្ណឹងបាទ។

**ស៖** តើពេលណាមួយនោះ ដូចដែលលោក ហ្វីលីព ស្សុត បានលើកឡើងថាតើមន្ទីរដែលទទួលខាងអូសឯកសារនេះត្រូវផ្ទេរពីភូមិភាគកណ្ដាលមកភូមិភាគពាយព្យវិញ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** សូម--

**អ្នកបកប្រែ៖**

អូ៎! អ្នកកែប្រែសូមកែប្រែ តាមពិតទៅខាងភូមិភាគពាយ័ព្យ។

**លោក នី កន៖**

**ឆ៖** បញ្ជាក់ជូន គឺឯកសារដែលខ្ញុំជម្រាបជូននេះ វាអាចលោកស្ដាប់ច្រឡំហើយ គឺជាឯកសារ

មិនមែនឯកសាររបស់ថ្នាក់លើទេ ឯកសារដែលគេបំបែកតាមតំបន់ ហើយឯកសារបំបែកតាមតំបន់នេះ គេដកស្រង់បាទ។ បើអ៊ីចឹងទៅ អូសតាមតំបន់ទៅ ហើយបើកន្លែងណាដែលមានការប្រយុទ្ធតឹងតែង គេចល័តមកទៀតមក បាទ។

[១៣:៤០:៥៧]

**ស៖** តើមានប្រភេទឯកសារអ្វីខ្លះដែលបានអូសនោះ ហើយបន្ទាប់មកទៀតត្រូវបញ្ជូនទៅ ថាបញ្ជូនពីកន្លែងមួយ ទៅកន្លែងមួយនោះ តើប្រភេទឯកសារអ្វីខ្លះទៅ?

**ឆ៖** សូមជម្រាបជូន ឯកសារនេះ គឺជាឯកសារទទួលពីលើ រួចហើយពីលើហ្នឹងយកបន្តមកតំបន់ រួចហើយតំបន់ហ្នឹងមកដកស្រង់ឲ្យអូសទៅ អូសទៅហើយផ្សាយទៅតាមមុខសញ្ញាដែលកំពុងប្រយុទ្ធហ្នឹង ហើយនិងផ្សាយទៅមូលដ្ឋានដែលនៅជាប់កន្លែងប្រយុទ្ធហ្នឹង។ មិនមែនជាឯកសារដែលយកទាំងស្រុងពីលើមកទេ ទីមួយ។ តែទីពីរ ជាឯកសារអប់រំដូចខ្ញុំបានជម្រាបដដែលៗ គឺថាឃោសនាឲ្យប្រជាជនហ្នឹង អ្នកខាងក្រោយបង្កបង្កើនផល ឧបត្ថម្ភខ្លួន។ ឯអ្នកខាងមុខ-- ឯទីពីរឲ្យឧបត្ថម្ភទៅខាងមុខ បានជាស្រូវ ជាអង្ករហើយ យកទៅឧបត្ថម្ភខាងមុខ។ ហើយមួយទៀត ក៏ឃោសនាឲ្យចូលរួមការតស៊ូបាទ។ ខ្លឹមសារប៉ុណ្ណឹងបាទ។

**ស៖** លោកនិយាយថា គឺជាឯកសារដែលមកពីខាងថ្នាក់លើ តើថ្នាក់លើនោះនៅឯណា គឺថានៅក្នុងចន្លោះឆ្នាំ៦៧ ដល់ឆ្នាំ៧០នេះ ហើយឯកសារទាំងអស់នេះបានបញ្ជូនមកលោកនោះ តាមរបៀបណា? ហើយគឺកាលនោះលោកនៅសៀមរាបនោះ បើខ្ញុំមិនច្រឡំទេ?

**ឆ៖** សូមជម្រាបជូនបាទ ឯកសារហ្នឹង គឺគេផ្ញើតាមសាខា។ សាខាហ្នឹងគេយកមកបន្ត។ ដូច្នេះប្រធានសាខាដែលបានទៅទទួលពីខាងណា ខាងខ្ញុំអត់ដឹងទេបាទ។

[១៣:៤៣:៣២]

**ស៖** តើវាជាឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្លឹមសារ បើខ្ញុំយល់ ពេលនុ៎ងគឺជាឯកសាររណសិរ្ស មិនមែនបានបញ្ចេញថា ជាបក្សកុម្មុយនីស្តកម្ពុជាអីអត់មានទេ។ ឯកសារនិយាយកម្រិតរណសិរ្សអ៊ីចឹងម្តង។

**ស៖** បើតាមលោកដឹង តើថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅឯណា? នៅចន្លោះឆ្នាំ១៩៦៧ ដល់ឆ្នាំ៧០ហ្នឹង នៅក្នុងតំបន់ណាដែលថាពួកគាត់ហ្នឹងស្នាក់នៅ នៅក្នុងព្រៃម៉ាគីនោះ?

**ឆ៖** សុំឆ្លើយបាទ។ ទីស្នាក់នៅ អ្ហឺ!កន្លែងណា អីកន្លែងណា ពួកខ្ញុំ អ្ហឺ! ខ្លួនខ្ញុំនេះអត់ដឹងទេបាទ។

ព្រោះជាការសម្ងាត់។

[១៣:៤៥:០៥]

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមអានសម្រង់ទីពីរនៃសៀវភៅអម្បាញ់មិញនេះ សៀវភៅរបស់លោក ហ្វីលីព ស្ស៊ត គឺនៅទំព័រ១៩៣ ជាភាសាអង់គ្លេស គឺថាលេខ ERN 00396393 ហើយនិងទំព័រ២៥០ ជាភាសាបារាំង គឺថា ERN 00639706។ លោក ហ្វីលីព ស្ស៊ត និយាយអំពីវិន័យដ៏តឹងរ៉ឹងជាធរមាន នៅក្នុងចលនាកុម្មុយនីស្ត។ គាត់លើកឡើងយ៉ាងដូច្នេះ "ប្អូនប្រុសរបស់លោក សុន សេន ឈ្មោះ នី កន បានស្ថិតនៅអស់រយៈពេលបីខែ នៅក្នុងខ្ទមស្រែមួយ នៅក្នុងខេត្តកំពង់ចាម ដែលក្នុងពេលដែលគាត់រត់គេចខ្លួននៅក្នុងឆ្នាំ១៩៦៨។ គេមិនអនុញ្ញាតឲ្យគាត់ចេញមកលាងខ្លួន ឬក៏បន្ទោបង់អ្វីទេ ដោយសារគេហេតុថា មានបញ្ហាសន្តិសុខ ហើយប៉ុន្តែតាមពិតទៅ គេធ្វើយ៉ាងណា ឲ្យក្លាយគាត់ជាជនសង្គ្រាម និងធ្វើឲ្យគាត់បង្ហាញនូវភាពស្មោះត្រង់របស់គាត់ ដែលចំពោះបក្ស ដែលពុំមានព្រំដែន"។ ខ្ញុំសូមបញ្ចប់សម្រង់ត្រង់នេះ។ តើលោកអាចបញ្ជាក់ថា លោកបាននៅអស់រយៈពេលបីខែ នៅខេត្តកំពង់ចាម គឺថានៅស្រុកស្រែ នៅក្នុងឆ្នាំ១៩៦៨ ហើយនៅពេលនោះ គឺថាលោកកំពុងតែលាក់ខ្លួន។ លោកអាចបញ្ជាក់បានដែរឬទេ?

[១៣:៤៦:៥១]

**ឆ៖** សូមឆ្លើយ ការលាក់ខ្លួន ដែលខ្ញុំបញ្ជាក់តាមការសម្ភាសន៍។ ពេលនោះ គឺមានការគេចដែរ គេចខ្លួនដែរបាទ។ ពីព្រោះចាប់ផ្ដើមមាន ប្រទេសយើងចាប់ផ្ដើមមានវិបត្តិហើយ។ វិបត្តិរដ្ឋប្រហារអីចុះឡើងហ្នឹង ផ្ទៃក្នុងច្របូកច្របល់ ហើយខ្ញុំផ្ទាល់ក៏អាចមានឈ្មោះក្នុងអ្នកដែលឃោសនិកមួយដែរ។ អ៊ីចឹង ខ្ញុំក៏គេចខ្លួន។ គេចខ្លួនតាមសាខា តាមនេះដែរ តាមគ្រូដូចគ្នាដែរ។ បាទ ពេលហ្នឹងមានអ៊ីចឹងបាទ។

**ស៖** បាទ នេះខ្ញុំនិយាយអំពីរយៈកាលឆ្នាំ៦៨ ទៅ៧០ តើនេះនៅក្នុងឆ្នាំ៦៨ មែនទេ ដែលលោកបានលាក់ខ្លួននោះ? ហើយលោកលាក់ខ្លួនអំពីអ្នកណា នៅក្នុងឆ្នាំ១៩៦៨នេះ?

**ឆ៖** ជម្រាបបាទ លាក់ខ្លួនពេលនុ៎ង គឺវាមានចលនាទូទៅហើយ។ ជាចលនាចូលព្រៃហ្នឹង វាខ្សឹបខ្សៀវបន្តបន្ទាប់ គួបផ្សំគ្នា។ ដល់អ៊ីចឹង លោកគ្រូ អ្នកគ្រូគ្គី អ្នកណាដែលចូលចិត្តពីរឿងហ្នឹង តែប្រព័ន្ធចាត់ចែងរបស់ខាងសន្តិសុខ លន់ នល់ ហ្នឹងដឹង នៅមិនបានទេ ត្រូវគេច។ បាទ ហ្នឹងមានប៉ុណ្ណឹងបាទ។

**ស៖** តើលោកគាំទ្រ-- លោកយល់ស្របនឹងការវិភាគរបស់លោក ហ្វីលីព ស្បូត ដែរឬទេ? នៅក្នុងការដែលថា គេធ្វើតែស្ដលើភាពស្មោះត្រង់របស់លោក ជាពិសេសនៅឆ្នាំ៦៨ នោះ នៅពេលដែលលោកត្រូវលាក់ខ្លួន។ តើលោក-- គឺថាលោកអាចបញ្ជាក់បានដែរឬទេ ថាលោកហ្នឹងស្មោះត្រង់នឹងបុព្វហេតុរបស់បក្សកុម្មុយនីស្ដកម្ពុជា និងចំពោះបុព្វហេតុបដិវត្តន៍នោះ?

[១៣:៤៩:៥០]

**ឆ៖** សូមបញ្ជាក់ជូនបាទ ភាពស្មោះត្រង់នឹងបក្ស នឹងអីពេលនោះ ខ្ញុំមិនយល់ទេ។ ខ្ញុំយល់ តែភាពស្មោះត្រង់ ដើម្បីជាតិ ប្រជាជន ហើយរួបរួមកម្លាំងគេហៅ "រណសិរ្សតស៊ូ" ហ្នឹងខ្ញុំយល់។ តែឲ្យចេញពាក្យថា ជាឈ្មោះបក្ស ជាឈ្មោះអីអត់ទាន់មានទេបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ឥឡូវ ខ្ញុំមានសម្រង់ពីរទៀតដែលត្រូវអាចចេញពីសៀវភៅនេះ គឺសម្រង់ទីមួយ គឺទំព័រ២៥២ ជាភាសាអង់គ្លេស គឺថាលេខERN 00396452 ហើយនិងទំព័រជាភាសាបារាំងគឺ 325 ERN 00639780។ នៅក្នុងទំព័រនេះលោក ស្បូត បាននិយាយអំពីរដូវរំហើយ ឆ្នាំ១៩៧៣ គឺថាពេលក្រោយមកហើយដែរ។ គាត់បាននិយាយអំពីកាលដែល ប៉ុល ពត ចុះទៅភូមិភាគពិសេសនៅក្នុង-- នៅជិតក្បែរស្រុក ច្រកស្ដេច ដែលមានមូលដ្ឋានថ្មីមួយជឿនលឿន ត្រូវបានសាងសង់ឡើងនេះជាអ្វីដែលលោក ហ្វីលីព ស្បូត បានលើកឡើង។ គាត់បាននិយាយថា តាមគោលការណ៍ការត្រួតពិនិត្យប្រតិបត្តិការយោធាខ្មែរក្រហមស្ថិតនៅក្រោមកណ្ដាប់ដៃរបស់លោក សុន សេន ដែលលោក ប៉ុល បានហៅគាត់ឲ្យមកពីភូមិភាគឦសាន ដើម្បីឲ្យគាត់កាន់មុខងារជាអគ្គសេនាធិការ។ កន្លែងបញ្ជាការរបស់គាត់ស្ថិតនៅប្រហែលជា១៥គីឡូម៉ែត្រនៅខាងនិរតីនៅក្បែរស្ថានីយរថភ្លើង វ៉ាស្មាច់ នៅលើផ្លូវផ្សារភ្ជាប់ពីភ្នំពេញទៅបាត់ដំបងដែលឥឡូវនេះបានបោះបង់ចោលហើយ។ គឺជាតំបន់មួយដែលពោរពេញទៅដោយដំបូកកណ្ដៀរដែលមាន-- ធំៗ ដែលមានខ្លះនោះខ្ពស់ជាងប្រាំមួយម៉ែត្រទៅទៀត ហើយនិងនៅពីលើដែលមានដើមឈើដុះ ហើយនិងមានឫស្សីដុះទ្រុបទ្រុល។

[១៣:៥២:២៨]

ប្អូនរបស់លោក សុន សេន ឈ្មោះ នី កន បាននិយាយរៀបរាប់ដូចតទៅនេះ៖ ខ្ញុំសូមលើកឡើងសម្រង់ដែលលោក នី កន បានរៀបរាប់។ "យើងបានសង់មន្ទីរបញ្ជាការដែលនៅក្នុងដីជាមួយនឹងត្រង់សេ ហើយនិងជម្រកនៅក្នុងដំបូកកណ្ដៀរ ហើយនិងប្រព័ន្ធរូង ដែលអាចឲ្យយើងចេញពីដំបូកកណ្ដៀរ

មួយទៅដំបូកកណ្តៀរមួយទៀត។ ហើយនៅក្នុងករណីដែលមានទម្លាប់គ្រាប់បែក យើងពួននៅក្នុងនោះ ដូចជាកណ្តៀរអ៊ីចឹង។ ហើយនៅពេលដែលរួចផុតពីគ្រោះថ្នាក់ហើយ យើងចេញមកក្រៅវិញ ហើយ យើងចាប់ផ្តើមធ្វើការងារយើងបន្តទៅទៀត។ ហើយជាទូទៅ នៅពេលដែលយើងជីកត្រង់សេគឺថា យើងដាក់កម្រាលឈើពីលើ ហើយដាក់បាវអង្កាមដើម្បីកាត់បន្ថយថាមពល ឥទ្ធិពលគ្រាប់បែកហើយ ដីដំបូកកណ្តៀរនេះមាំស៊ូនឹងគ្រាប់បែកបាន។ ហើយដើមឫស្សីវាអាចឲ្យយើងលាក់ខ្លួនបាន”។ សូម បញ្ចប់សម្រង់ត្រង់នេះ។

[១៣:៥៣:៤៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

**ផ៖** សំណួរខ្ញុំគឺថា តើលោកពិតជាបានធ្វើការចាប់ពីឆ្នាំ១៩៧៣ មកនោះជាមួយបងប្រុសរបស់ លោក លោក សុន សេន ដែលជាអគ្គសេនាធិការនៅក្នុងភូមិភាគពិសេសដែលនៅជិតវ៉ាស្នាច់ហ្នឹងដែរ ឬទេ? ដែលមិននៅឆ្ងាយប៉ុន្មានពីស្រុក ច្រកស្តេច ដែលស្ថិតនៅភូមិភាគពាយព្យ-- នៅខាងពាយព្យ ហើយនៅក្បែរឧដុង្គ ហើយនៅខាងត្បូងស្លាន ហើយនិងពាម នៅខាងបស្ចិម នៅក្នុងតំបន់ដែលស្ថិតនៅ ក្នុង-- នៅព្រំប្រទល់នៃរវាងខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង។ តើលោកពិតជាបានធ្វើការនៅទីនោះដូចដែល លោក ហ្វីលីព ស្បូត បានលើកឡើងនៅក្នុងសៀវភៅគាត់ដែរឬទេ?

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូនបាទ កន្លែងដែលសៀវភៅសម្ភាសខ្ញុំបានសរសេរនោះ គឺជាកន្លែងដែលគេ ហៅថា “តំបន់១៥”។ ហើយតំបន់១៥ នេះគឺវាស្ថិតក្នុងពាយព្យភ្នំពេញ ដូច្នេះកន្លែងនោះជាសមរភូមិ ក្តៅបំផុត។ គ្រាប់បែកធ្លាក់គ្មានពេលវេលាទេ កប៉ាល់ហោះបាញ់គ្មានពេលវេលាទេ កាំភ្លើងធំចេញ ក៏គ្មានពេលវេលា។ អ៊ីចឹងទាំងប្រជាជន ទាំងពួកខ្ញុំជាយោសនិកទាំងអស់ ទាំងយោធាអីទាំងអស់ ត្រូវតែ ធ្វើលេណដ្ឋាន។ ឯលេណដ្ឋានដែលខ្ញុំបានបញ្ជាក់ គឺលេណដ្ឋានប្រសិទ្ធភាពគឺដំបូក។ ដំបូក មានដើមឈើ មានឫស្សីដុះពីលើ ហើយវារឹង កណ្តៀរវាពួន អ៊ីចឹងគេលុងដំបូកហ្នឹង គេចូលទៅជ្រកក្នុងហ្នឹង តែពេល ខ្លះក៏គ្រោះថ្នាក់ដែរ។ ហ្នឹងសូមជម្រាបអ៊ីចឹង ពីព្រោះគ្រាប់បែកណាប៉ាល់ វាហូរចូល។ បាទ ប្រជាជន អីៗទាំងអស់ស្វ័យភាពខ្លួនឯងទាំងអស់ ជីករៀងខ្លួន។ លោកអាចឃើញខ្លះដែរក៏មិនដឹង បើមើលពីលើ កប៉ាល់ហោះមកឃើញរណ្តៅគ្រាប់បែកដូចអីរន្ធបាយខុម ឬអម្បែងនំគ្រក់។ ដូច្នេះការនេះជាការពិត ដែលខ្ញុំបាននិយាយបាទ។ សូមអស់។

[១៣:៥៦:៤៣]

**ស៖** តើគ្រាប់បែកទម្លាក់នុ៎ង ទម្លាក់មកពីណា អ្នកណាអ្នកទម្លាក់ គឺជាទ័ពរបស់ លន់ នល់ ឬក៏ជាគ្រាប់បែករបស់ទាហានអាមេរិកាំង?

**ឆ៖** សូមជម្រាប។ ខ្ញុំមិនដឹងទេ តែដឹងតែកាលណោះ ចម្បាំងវាំងជលនេះ វាជាមួយ លន់ នល់ ហើយមានអាមេរិកាំងគាំទ្រ។ ឯគ្រាប់បែកនោះមកពីណាយីហោអី ខ្ញុំក៏មិនដឹងដែរបាទ។ តែគ្រាប់បែកហ្នឹងទម្លាក់មករៀងរាល់ថ្ងៃអ៊ីចឹងបាទ។

**ស៖** អម្បាញ់មិញនេះ លោកបានទៅភូមិ-- តំបន់១៥នៅចុងឆ្នាំ១៩៧៤ ក៏ប៉ុន្តែតាមឯកសារនេះថា នៅរដូវរំហើយឆ្នាំ១៩៧៣ ដែលថា ក្នុងឯកសារនេះមានចែងថា លោកនៅក្នុងដំបូកកណ្ដៀរ តើនេះធ្វើឲ្យលោកចាំ-- ឲ្យលោកចាំឡើងវិញ គឺថាលោកបានមកដល់កន្លែងនេះ តើប្រហែលជាឆ្នាំ១៩៧៤ នៅចុងឆ្នាំ១៩៧៤វិញទេ តើអ៊ីចឹងមែនទេ?

**ឆ៖** សូមជម្រាបជូន ខ្ញុំចាំមិនអស់ដែរ ប៉ុន្តែតាមខ្ញុំនឹកឡើងវិញប្រហែលជាចុង៧៣ ដើម៧៤ ហើយមិនចាំ ចាំមិនអស់ទេ ប៉ុន្តែរវាងប៉ុណ្ណឹងបាទ។

[១៣:៥៨:៥២]

**ស៖** នៅពេលដែលលោកនៅជាមួយ សុន សេន នៅក្នុងដំបូកកណ្ដៀរនោះ តើមានថ្នាក់ដឹកនាំនៃបក្សផ្សេងទៀត តើបានមកលេងគាត់ទេ មកកន្លែងគាត់ដែរឬទេ?

**ឆ៖** សូមឆ្លើយ។ អ្នកសរសេរនោះ អាចច្រឡំហើយ ពីព្រោះខ្ញុំមិនបាននៅជាមួយបងខ្ញុំទេ។ ខ្ញុំជាឃោសនិក នៅជាមួយតំបន់១៥ ឯខ្ញុំនិយាយថា សូម្បីតែបងខ្ញុំក្ដី ឬមេទ័ពក្ដី ដូចជម្រាបអម្បាញ់មិញ នរណាក៏ដោយត្រូវតែដឹកអ៊ីចឹងហើយ ដឹកចូលជ្រកអ៊ីចឹង បើមិនចូលជ្រក មិនដឹកអ៊ីចឹងទេនៅមិនបានទេបាទ។ សូមជម្រាបបញ្ជាក់បន្ថែមប៉ុណ្ណឹងបាទ។

**ស៖** តើលោកពិតជានៅវ៉ាស្នាច់ ហ្នឹងមែនឬទេ គឺថានៅ តំបន់១៥?

**ឆ៖** បាទ គឺចល័តចុះ ចល័តឡើងរវាងវ៉ាស្នាច់ និងអង្គរស្សហ្នឹងបាទ។ អង្គរស្សសព្វថ្ងៃ។

**ស៖** ដូច្នេះនៅពេលដែលយើងនៅច្រកស្ដេចនោះ តើលោកបានជួប ប៉ុល ពត ដែរឬទេ ដែលពេលគាត់មកត្រួតពិនិត្យនៅ-- ត្រួតពិនិត្យកន្លែងមូលដ្ឋានជឿនលឿននោះនៅពេលនោះ?

**ឆ៖** ច្រកស្ដេចខ្ញុំមិនដែលបានទៅទេបាទ។ ហើយរហូតថ្ងៃនេះក៏ស្គាល់មិនច្បាស់ថា ច្រកស្ដេចនៅត្រង់ណាផង។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែហើយ ពីព្រោះអម្បាញ់ខ្ញុំឮថា លោកធ្លាប់បានទៅរ៉ាស្នាច់ ហើយនិងច្រកស្តេច។ ឥឡូវនេះ លោកថាលោកមិនស្គាល់ច្រកស្តេច។ អ៊ីចឹងលោកអាចពន្យល់ពីបញ្ហានេះយ៉ាងដូចម្តេចទៅ? ប្រហែលជាមកពីការអានរបស់ខ្ញុំហ្នឹងអានមិនច្បាស់ ឬក៏យ៉ាងម៉េច?

[១៤:០១:៤៦]

**ឆ៖** សូមជម្រាប ខ្ញុំមិនមែនជាអ្នកភូមិសាស្ត្រនៅឧដុង្គ ឬក៏នៅម្តុំរ៉ាស្នាច់ ស្អីហ្នឹងច្បាស់លាស់ទេ។ ខ្ញុំឆ្លើយនឹងលោកដែលសួរខ្ញុំអម្បាញ់មិញនេះ សួរត្រង់ថារ៉ាស្នាច់ ខ្ញុំសម្គាល់ត្រង់អាផ្លូវខ្វែងផ្លូវរទេះភ្លើងហ្នឹង។ ឯហួសពីហ្នឹងទៅ ច្រកស្តេចត្រង់ណា ក៏ខ្ញុំមិនដែលឮដែរ ខ្ញុំចុះមកភ្លាមៗអ៊ីចឹង ខ្ញុំស្គាល់តែត្រង់ផ្លូវខ្វែងផ្លូវរទេះភ្លើងហ្នឹង ហើយចាក់ពីហ្នឹងមក ខ្ញុំមកនៅច្រើនជាងគេគឺភ្នំអង្គរស្ស ក្បែរភ្នំអង្គរស្ស។ ចុះឡើងម្តុំហ្នឹង។ ហើយអត់មានទីលំនឹងអីច្បាស់លាស់ទេ។ ដូច្នេះរ៉ាស្នាច់ហ្នឹង ខ្ញុំក៏មិនច្បាស់លាស់ដែរ ខ្ញុំមិនស្គាល់ដែរ ចំណុចខ្វែងត្រង់ហ្នឹង ខ្វែងផ្លូវរទេះភ្លើង។ ដល់លោកសួរខ្ញុំថា ច្រកស្តេចនៅត្រង់ណា។ ខ្ញុំមិនច្បាស់ដែរបាទ។ ហើយតើបានធ្វើការជាមួយ បានទទួលការស្វាគមន៍អី។ ខ្ញុំក៏អត់ដែលបានដែរ ព្រោះនេះជាក្របខ័ណ្ឌថ្នាក់លើ ថ្នាក់ខ្ពស់បំផុតមិនអាចកម្រិតខ្ញុំបានជួបទេបាទ។

**ស៖** ប៉ុន្តែទាក់ទងទៅនឹងបងប្រុសរបស់លោក ដែលបាននិយាយនៅក្នុងសម្រង់នៃសៀវភៅដែលខ្ញុំលើកឡើងនេះ គឺថាគាត់មានទីស្នាក់ការបញ្ជានៅចម្ងាយពីប្រហែលជា១៥គីឡូម៉ែត្រ ពីច្រកស្តេច ហើយនៅក្បែររ៉ាស្នាច់។ តើបងប្រុសរបស់លោកពិតជាមានទីបញ្ជាការនៅរ៉ាស្នាច់ ដែលប្រហែលជាអាចជាកន្លែងដែលនៅក្បែរៗគ្នា ឬក៏ខុសគ្នាបន្តិចពីកន្លែងដែលលោករស់នៅកាលពីសម័យនោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** សូមឆ្លើយ។ ទីបញ្ជាការរបស់គាត់ខ្ញុំមិនស្គាល់ទេ។ គេសម្ងាត់។ ហើយចំណុចរបស់ខ្ញុំ ជាចំណុចចំហ។ ចំហព្រោះអ្នកឃោសនា មិនសម្ងាត់ទេបាទ។

[១៤:០៤:៣៧]

**ស៖** អម្បាញ់មិញនេះលោកបាននិយាយថា លោកបានទៅដល់តំបន់នោះគឺថាចុងឆ្នាំ១៩៧៣ ដល់ដើមឆ្នាំ១៩៧៤ លោកមិនពូកែខាងភូមិសាស្ត្រទេ ក៏ប៉ុន្តែរ៉ាស្នាច់នេះនៅជិតទីក្រុងឧដុង្គ តើពិតជាអ៊ីចឹងមែនទេ?

**ឆ៖** សូមជម្រាបលោកម្តងទៀតថា ខ្ញុំស្គាល់មិនច្បាស់ទេ ខ្ញុំស្គាល់ចំណុចខ្វែងហ្នឹងខ្ញុំថា ស្នាច់ ពីព្រោះមានភូមិស្នាច់មួយ តែដល់មែនទែនទៅរ៉ាស្នាច់ហ្នឹងនៅត្រង់ឧដុង្គត្រង់ណា ខ្ញុំអត់ច្បាស់ទេពេល

នោះបាទ។

**ស៖** តើលោកដឹងពីអ្វីដែលកើតមានឡើងទៅដល់ប្រជាជននៅឧដុង្គនៅក្នុងខែមីនា ឆ្នាំ១៩៧៤ ដែរឬទេ?

**ឆ៖** ចង់សួរថាម៉េច?

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្តងទៀត សំណួរចុងក្រោយអម្បាញ់មិញនេះ សាក្សីស្តាប់មិនយល់ទេ សំណួរដែលលោកសួរចុងក្រោយអំមិញនេះ។

[១៤:០៦:១៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំនិយាយទៅ យោងឯក-- ថានៅឆ្នាំ៧៤ ហ្នឹងគាត់នៅវ៉ាស្នាច់ តើលោកដឹងទេ លោកសាក្សី លោកដឹងថាមានរឿងអ្វីកើតឡើងដល់ចំពោះប្រជាជននៅឧដុង្គ នៅខែមីនា ឆ្នាំ១៩៧៤ គឺថារយៈពេលបន្តិចក្រោយពេលដែលលោកបានទៅដល់តំបន់នោះ? តើលោកដឹងថាមានរឿងអ្វីកើតឡើងទៅដល់ប្រជាជននៅស្រុកឧដុង្គនុ៎ងដែរឬទេ?

**លោក នី កន៖**

**ឆ៖** បាទ រឿងនេះ ខ្ញុំអត់ដឹងទេបាទ។

[១៤:០៧:១៧]

**ស៖** តើលោកដឹង ឬក៏លោកបានឮក្នុងពេលណាមួយ គឺថាពេលហ្នឹង ឬក៏ក្រោយមកទៀត គឺថាទីក្រុងឧដុង្គត្រូវបានជម្លៀសនៅដើមឆ្នាំ១៩៧៤ តើលោកដឹងដែរឬទេ?

**ឆ៖** ក្នុងពេលដែលសង្គ្រាមរីកាន់តែខ្លាំងក្នុងនេះ-- ក្នុងពេលនោះ មានការជម្លៀសប្រជាជនចុះឡើងច្រើនដែរ។ តែការថា ឲ្យខ្ញុំកត់ចំណាំថា ប្រជាជនឧដុង្គ ឬត្រង់ណា ខ្ញុំអត់ចាំ អត់ច្បាស់ទេ។ តែការចលនាប្រជាជនគេចសង្គ្រាម គឺមាន បាទ។ ពីព្រោះចៀសវាងការរងគ្រាប់បែក និងគ្រាប់កាំភ្លើងធំ។

**ស៖** នៅពេលដែលប្រជាជនត្រូវបានជម្លៀសចេញពីតំបន់សង្គ្រាម ដើម្បីគេចពីការទម្លាក់គ្រាប់បែកនោះ តើនៅពេលណាមួយនោះ គេបានឲ្យគាត់មកទីក្រុងវិញ ឬក៏នៅក្នុងតំបន់ដែលគាត់ត្រូវបាន

ជម្លៀសចេញពីមុនមកនោះ ឬក៏គេជម្លៀសគាត់ចេញទៅរហូតតែម្តង ដោយមិនឲ្យត្រឡប់មកវិញ?

**ឆ៖** តាមខ្ញុំចាំ គឺគេជម្លៀសបណ្តោះអាសន្ន បើកាលណាសភាពការណ៍អនុគ្រោះ គេចលនាឲ្យត្រឡប់មកវិញ ពីព្រោះប្រជាជននៅជិតសមរភូមិមុខនេះ ជួយដល់ការដឹកជញ្ជូន។ ទាំងដឹកជញ្ជូនគ្រាប់រំសេវ ស្បៀងអាហារ របួស ពលីកម្ម។ ដូច្នេះ គេមិនចលនាទៅរហូតទេ តែបើសិនកន្លែងនុ៎ងវានៅតែក្តៅអ៊ីចឹង គេឲ្យនៅ ទៅខាងក្រោយៗ ដើម្បីឲ្យជួយ ដើម្បីធានាសន្តិសុខ។ ហើយខាងក្រោយហ្នឹងគេជួយបាយ ជួយទឹក នេះតាមខ្ញុំដឹងបាទ។ ប៉ុណ្ណឹងបាទ។

[១៤:១០:១០]

**ស៖** តើនៅទីក្រុង ជាពិសេសគឺថាក្រុងខដុង្គនោះ តើមានតែអ្នកដែលគាំទ្របដិវត្តន៍ ឬក៏មានវណ្ណៈ ដែលថាគេចាត់-- ដែលគេចាត់ទុកថាជាសត្រូវដែរឬទេ?

**ឆ៖** កាលនោះតាមខ្ញុំយល់ ខ្ញុំដឹង គឺដូចមិនមានការបែងចែកទេ គេត្រូវការតែអ្នកចូលរួម ជួយឧបត្ថម្ភជាស្បៀងអាហារ ជួយឧបត្ថម្ភជាការដឹកជញ្ជូន។ ហេតុនេះមិនមានការបែងចែកទេ បាទ។

**ស៖** នៅតំបន់១៥ គឺថានៅមុនខែមេសា ឆ្នាំ១៩៧៥ គឺនៅឆ្នាំ៧៣-៧៤ តើលោកមានដឹងថាមានកិច្ចប្រជុំសំខាន់ៗរបស់បក្ស ដែលបានប្រព្រឹត្តឡើងដែរឬទេ?

[១៤:១១:៣៤]

**ឆ៖** សូមជម្រាបជូន។ ការប្រជុំបក្សសំខាន់ៗនៅតំបន់នុ៎ង ខ្ញុំអត់ដឹងទេ។ តែបើប្រជុំ គេហៅថាការប្រជុំរួម ឃោសនារួម តាមភារកិច្ចរបស់គណៈតំបន់១៥នោះ មានបាទ។

**ស៖** បាទ សូមអរគុណ។ សម្រង់ចុងក្រោយនៃសៀវភៅនេះ គឺជាភាសាអង់គ្លេសថា 00396476 ERN ជាភាសាបារាំង គឺ00639800។ នៅក្នុងសម្រង់នេះលោក ហ្វីលីព ស្បូត និយាយអំពីការដែលខ្មែរក្រហមចូលមកក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយគាត់លើកឡើងរៀបរាប់យ៉ាងដូច្នេះ ខ្ញុំសូមដកស្រង់៖ “ប្អូនប្រុសរបស់លោក សុន សេន គឺលោក នី កន ជាអ្នកនៅក្នុងជួរមុខក៏បានចូលទៅក្នុងទីក្រុងជាមួយនឹងកងពលនៃភូមិភាគពិសេស”។ ហើយគាត់រៀបរាប់យ៉ាងដូច្នេះ “យើងទៅដល់ទីក្រុងភ្នំពេញពីគ្រប់ទិសទី ពេលទាំងអស់ គឺមានប្រហែលជា-- កន្លែងច្រកចូលប្រហែលជា១៤ ដើម្បីវាយផ្តាច់។ មនុស្សនៅផ្តុំច្រើនជាងគេបំផុត នៅភាគខាងលិច គឺនៅ-- កងកម្លាំងរបស់យើង គឺមានមូលដ្ឋាននៅទីនេះឯង ហើយ សុន សេន ជូនគាត់នៅទីកន្លែងទីបញ្ជាការដ្ឋាននៃ--នៅវ៉ាស្នាច់ ហើយនិងនៅទីបញ្ជាការសមរភូមិមុខ នៅភ្នំអង្គរស្ស ដែលពីភ្នំនោះមកគាត់អាចមើលកម្លាំង-- ដំណើរ

ទៅមុខ ឈានទៅមុខនៃកងទ័ព។ យើងគិតថា ទីក្រុងភ្នំពេញនឹងធ្លាក់មកក្នុងកណ្ដាប់ដៃយើងនៅចន្លោះម៉ោងដប់កន្លះ ឬដប់ពីរ។ ក៏ប៉ុន្តែតាមពិតទៅ យើងបានវ៉ៃយកបានមួយម៉ោងមុនហ្នឹងទៅទៀត។ ចំពោះយើង គឺថាជា-- យើងមានសុភមង្គលសម្បើមណាស់ ពីព្រោះមុខសញ្ញាយុទ្ធសាស្ត្រទាំងអស់ យើងបានសម្រេច។ ហើយខ្ញុំចាំថាៗ អង្កាល់នោះ ខ្ញុំធ្លាប់គិតថា អ្វីៗទាំងអស់នឹងប្រសើរជាមុន ហើយប្រជាជននឹងមានជីវភាពប្រសើរជាងមុន។ ហើយនៅក្នុងរង្វង់ក្រចកនេះ គឺមានសរសេរថា (នី កន កិច្ចសម្ភាសន៍របស់លោក នី កន)"។

[១៤:១៤:៤១]

ក្រៅពីវ៉ាស្នាច់ លោកធ្លាប់និយាយអំពីភ្នំអង្គរស្បូវដែរឬទេ? ព្រោះថានៅក្នុងសម្រង់នេះមាននិយាយអំពីភ្នំអង្គរស្បូវដែរ?

**ឆ៖** សូមជម្រាបជូន គឺខ្ញុំទទួលភារកិច្ចជាអ្នកឃោសនា ឬហៅថាឃោសនិកហ្នឹង គឺឃោសនាអប់រំតាមតែក្រោយកងទ័ព។ ដូចបានជម្រាប ឃោសនាឲ្យឧបត្ថម្ភជាម្ហូបចំណី ឃោសនាឧបត្ថម្ភជួយដឹកជញ្ជូន ហើយក៏ចល័តចុះចល័តឡើងម្ភុំអស់នេះ ពីព្រោះមុខព្រួញដែលវ៉ៃសម្រុកចូលក្រុងភ្នំពេញវាមានច្រើនមុខព្រួញ តែខ្ញុំនៅមុខព្រួញនេះ តាមពីក្រោយហ្នឹង។ អ៊ីចឹងបានខ្ញុំបញ្ជាក់ថាខ្ញុំដឹងរឿងវ៉ាវនៅមុខព្រួញនេះត្រង់ថាចូលបានម៉ោងប៉ុន្មានៗ ប្រហាក់ប្រហែលទេ មិនច្បាស់លាស់ថាមួយរយភាគរយម៉ោងប៉ុណ្ណេះ ម៉ោងប៉ុណ្ណោះទេ ប៉ុន្តែប្រហាក់ប្រហែល ហើយនិយាយតគ្នា។ មនុស្សច្រើនណាស់ ហើយទាំងប្រជាជន ទាំងកងទ័ពហ្នឹងវាច្របូកច្របល់គ្នាច្រើនណាស់។ ដូច្នេះខ្ញុំនៅច្រកនេះបានខ្ញុំបញ្ជាក់ជូនថាខ្ញុំចូលតាមច្រកហ្នឹង ម្ដុំហ្នឹងបាទ។

[១៤:១៦:៤០]

**ស៖** តើលោកបានចូលនៅក្នុងភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ជាមួយនឹងកងពលនៃកងកម្លាំងពិសេសដែរឬទេ?

**ឆ៖** ខ្ញុំចូលតាមក្រោយកងទ័ព ហើយក្រុមរបស់ខ្ញុំក្រុមឃោសនាអប់រំទៅតាមក្រោយហ្នឹងបាទ។

**ស៖** តើកងពលធំនៃភូមិភាគពិសេសហ្នឹងឈ្មោះអ្វីដែរ?

**ឆ៖** សូមឆ្លើយ ខ្ញុំអត់ចាំទេ កងពលវាច្រើន។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញនេះ លោកបានឆ្លើយថា លោកគិតថានៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ នេះកសិករនឹងទទួលបាននូវជីវិតដ៏ប្រសើរមួយ។ ហេតុអ្វីបានលោកគិតថាប្រជាជន

នោះ ឬក៏កសិករនោះនឹងទទួលបាននូវជីវភាពមួយដ៏ប្រសើរថ្លៃថ្នូរជាងមុននោះ?

**ឆ៖** សូមជម្រាបជូន នេះគឺជាគំនិតគិតគូររបស់ខ្ញុំ ដោយផ្អែកទៅលើគោលនយោបាយឃោសនាអប់រំថា លើកស្ទួយជីវភាពប្រជាជន។ អ៊ីចឹងខ្ញុំយល់តាមគំនិតខ្ញុំអ៊ីចឹងទៅ។ តែការពិតជាក់ស្ដែងមកថ្ងៃក្រោយយ៉ាងម៉េច ខ្ញុំអត់បានគិតទេបាទ។

[១៤:១៩:០០]

**ស៖** ក៏ប៉ុន្តែ នៅក្នុងតំបន់រំដោះដែលលោកធ្វើការកាលពីមុននោះ តើលោកបានកត់សម្គាល់ឃើញថាប្រជាជនមានជីវភាពល្អប្រសើរដែរឬទេនៅក្នុងតំបន់រំដោះ? ហើយតើផ្អែកលើលក្ខខណ្ឌអ្វីដែលលោកគិតថាវាមានការរីកចម្រើននោះ?

**ឆ៖** ខ្ញុំមានការគិតគូរថារីកចម្រើនហ្នឹងដោយសារថា ពេលនុំខាងមុខចេះតែរ៉ៃរុញទៅ ខាងក្រោយចេះតែបង្កើនផលម្ដុំដីជិតភ្នំពេញហ្នឹង ដីល្អ មានត្រី មានសាច់អីហូបទៅ ព្រោះសង្គ្រាមអ៊ីចឹងទៅគ្មានជាកំណត់ថាជាកម្មសិទ្ធិរបស់អ្នកណាទេ។ ទាហាន ឬហៅថាយោធាមានអំណាច ចេះតែរុញទៅមុខ ហើយប្រជាជនដែលដឹកជញ្ជូនតាមក្រោយ ចេះតែធ្វើស្រែ ធ្វើចម្ការម្ដុំហ្នឹងទៅ ហើយបានត្រីបានសាច់ពីទន្លេហ្នឹងហូបទៅ។ ខ្ញុំថា អើ! នេះជាជីវភាពគ្រាន់បើបាទ។ បញ្ជាក់ជូនលោកដែលសរសេរហ្នឹងគឺប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលលោកចូលដល់ភ្នំពេញនោះ តើមានសមាសភាពប្រជាជនអ្វីខ្លះនៅក្នុងទីក្រុង? តើមានកសិករច្រើនទេនៅទីក្រុង នៅពេលនោះ?

**ឆ៖** សូមឆ្លើយ ខ្ញុំមិនអាចសន្និដ្ឋានបានទេ ពីព្រោះមនុស្សច្របូកច្របល់ទៅត្បូង ទៅជើង ទៅលិច ទៅកើត ស្លៀកពាក់ចម្រុះ មកពីខេត្ត មកពីទីប្រជុំជន មិនដឹងជាអ្នកណា ជាអ្នកណា។ ខ្ញុំមិនអាចកត់សម្គាល់ថា អូ៎!ប្រភេទនេះ កសិករប៉ុណ្ណេះភាគរយ អីអត់បានទេបាទ។

[១៤:២១:៣១]

**ស៖** ឧទាហរណ៍ដូចជានៅទីក្រុងភ្នំពេញ តើមានប្រជាជនដែលមានវណ្ណៈផ្សេងអ្វីទៀត ក្រៅពីវណ្ណៈកសិករដែរឬទេ? ហើយប្រសិនបើមាននោះ តើមានវណ្ណៈអីខ្លះ? បើតាមការរៀបចំជាចំណាត់ថ្នាក់របស់បក្សកុម្មុយនីស្តកម្ពុជានោះ តើមានចាត់ជាវណ្ណៈអ្វីខ្លះ?

**ឆ៖** ក្នុងពេលសង្គ្រាម ទើបតែមិនទាន់ចប់ស្រួលបួល កំពុងតែច្បាំងគ្នាអ៊ីចឹង ហើយទើបដណ្ដើមបានទីតាំងអ៊ីចឹង។ ការកំណត់ប្រភេទវណ្ណៈអី អត់មានទេ។ រួចហើយពួកខ្ញុំចុះផ្ទាល់ ដឹងឮតែថា

មានប្រជាជនតាមខេត្តជិតៗរត់ចូលទីក្រុង។ ហើយនិងមានមន្ត្រីរាជការ ក្រសួងណា ក្រសួងណី ខ្ញុំក៏មិនដឹងដែរ កំណត់បានតែពីរហ្នឹងទេលោក។ ដូច្នេះ មិនអាចកំណត់ថាប្រភេទវណ្ណៈនេះ វណ្ណៈនោះអត់ដឹងទេបាទ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហានេះនៅពេលក្រោយ។ ប៉ុន្តែលោកមិនដែលធ្លាប់គេនិយាយនៅក្នុងក្របខ័ណ្ឌចលនាបដិវត្តន៍ ឬក៏ក្នុងបក្សកុម្មុយនីស្តកម្ពុជាក្នុងឋានៈដែលលោកជាឃោសនិកអប់រំនោះ លោកមិនដែលឮការនិយាយអំពីការតស៊ូវណ្ណៈទេឬ?

**ឆ៖** ចំពោះបញ្ហានេះ ក៏ឮដែរ តែមិនទាន់យកមកចោទក្នុងពេលនោះទេ។ គ្រាន់តែឮថា តស៊ូដើម្បីលើកស្ទួយជីវភាពអ្នកក្រីក្រ តែមិនទាន់យកជាបញ្ហាសំខាន់ទេ ពីព្រោះធ្វើម៉េចឲ្យតែឈ្នះភាគីម្ខាងសិន។ នេះតាមខ្ញុំទទួលជាការផ្នែកឃោសនិក ហើយដឹងឮតាមសមត្ថភាពខ្ញុំ ពេលហ្នឹងបាទ។

[១៤:២៣:៥៥]

**ស៖** ខ្ញុំយល់អំពីតួនាទីរបស់លោក ប៉ុន្តែការតស៊ូវណ្ណៈនោះ គឺមានន័យថាការប្រឈមមុខគ្នារវាងវណ្ណៈផ្សេងៗ អ៊ីចឹងតើមានវណ្ណៈអ្វីខ្លះដែលមានការតស៊ូប្រយុទ្ធគ្នាហ្នឹង?

**ឆ៖** ពេលនុ៎ង តាមខ្ញុំចាំ គឺគេហៅថាមហាចលនាប្រជាជន ហើយជាការបង្រួបបង្រួមបង្កើតជារណសិរ្ស។ ដូច្នេះ គ្មានការតស៊ូប្រយុទ្ធទេ គឺប្រមូលគ្រប់ជាន់ស្រទាប់ទាំងអស់។ ខ្ញុំជាគ្រូបង្រៀនដូច្នេះប្រមូលគ្រូបង្រៀនទាំងអស់ហ្នឹងមកចូលរួម ហើយអត់ប៉ាន អត់មានគោលការណ៍ថា លើកថាគ្រូបង្រៀនស្រទាប់នេះ ស្រទាប់នោះទៅប្រឆាំងនឹងស្រទាប់នេះ ស្រទាប់នោះបានទេ។ បើលើកអ៊ីចឹង វាបែកបាក់អស់ហើយ មិនមានប្រមូលកម្លាំងមកបានទេបាទ។ ពេលក្រោយខ្ញុំមិនដឹងទេ អាហ្នឹងពេលក្រោយតទៅទៀត។ ប៉ុន្តែចំពោះពេលនុ៎ង គ្មានទេ។

[១៤:២៥:១៣]

**ស៖** នៅពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញ តើគេមានការចេញបញ្ជាអ្វីខ្លះទៅដល់ប្រជាជន ពីខាងសំណាក់យោធា-- កងទ័ពនោះ?

**ឆ៖** ផ្នែកកងទ័ពបញ្ជាយ៉ាងម៉េច ខ្ញុំមិនដឹង។ តែផ្នែកខ្ញុំ គ្រាន់តែលើកពាក្យស្លោកឲ្យឃោសនាថា "ចេញ ខ្លាចកប៉ាល់ហោះទម្លាក់គ្រាប់បែកទៀត។ ជុំគ្នាងាប់ច្រើន អ៊ីចឹងគេច បំបែកគ្នាទៅក្រៅ"។ នេះ ខ្ញុំដឹងឮប៉ុណ្ណឹងបាទ។ ឯផ្នែកកងទ័ព មិនដឹងទេ ព្រោះគេបញ្ជាតាមខ្សែៗរបស់គេ។

**ស៖** តើមានការចេញបញ្ជាជាពិសេសទៅដល់ក្រុមប្រជាជនជាក់លាក់ណាមួយ។ ឧទាហរណ៍

ដូចជា កងទ័ពរបស់សាធារណរដ្ឋខ្មែរលន់ នល់ ដែរឬទេ? តើគេធ្វើយ៉ាងម៉េច ចំពោះឃោធារបស់កង--របស់លន់ នល់ នោះ នៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥នោះ?

**ឆ៖** ខ្ញុំចាំបាន គឺថាជាការឃោសនារួម ចលនារួមទាំងអស់គ្នា ត្រូវចេញពីក្រុង។ ឯបែងចែកថាអ្នកណាចេញ មិនចេញអី អត់មានទេ គ្រាន់តែឃោសនារួមឲ្យចេញពីក្រុងទាំងអស់។ បាទ នេះដែលខ្ញុំដឹង។

[១៤:២៧:០៦]

**ស៖** តើអ្នកណាជាអ្នកឲ្យលោកពាក់កាំភ្លើងនៅទីក្រុងភ្នំពេញ នៅពេលជម្លៀសនោះ? (សូមទោស) តើអ្នកណាជាអ្នកឲ្យលោកពាក់ស្លាក ដើម្បីប្រាប់ដល់ប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញនោះ?

**ឆ៖** ជម្រាបជូនបាទ។ ផ្នែកតំបន់បាទ។ តំបន់គេមានសិទ្ធិណែនាំទៅផ្នែកការងារផ្សេងៗ។ ការងារឃោសនាណែនាំយ៉ាងម៉េច? ការងារដឹកជញ្ជូនណែនាំយ៉ាងម៉េច? ដូច្នេះ យើងថ្នាក់ក្រោមទទួលការណែនាំពីតំបន់ហើយ យើងអនុវត្តតាមហ្នឹងបាទ។

**ស៖** តើលោករៀបចំស្លាកសញ្ញានេះ នៅថ្ងៃហ្នឹងតែម្តង ឬក៏លោករៀបចំទុកជាមុន ដោយដឹងថាប្រជាជននឹងត្រូវជម្លៀសនោះ?

**ឆ៖** អត់បានរៀបចំអីទេ ប្រាប់តៗគ្នា។ ប្រាប់ថា ខាងលើឲ្យឃោសនាប្រាប់ថា ឲ្យប្រជាជនចេញទៅ នៅមិនបានទេ។ បន្តិចទៀត កប៉ាល់ហោះមកទម្លាក់ងាប់ហើយ តែប៉ុណ្ណឹង។ ឯរឿងឲ្យចេញជាសារចរ ចេញជាពាក្យសម្តី ជាស្លាកអី កត់សម្គាល់លើដើមទ្រូងអី គ្មានទេពេលនោះ។ មានតែពាក្យសម្តីប៉ុណ្ណឹងគត់។ ហើយដូចខ្ញុំបានជម្រាបថាជាវិន័យដែកថែប គេលាក់ការណ៍ខ្ពស់បំផុត។ មួយម៉ាត់ពីរម៉ាត់ ទទួលហើយ អត់មានចាំបាច់និយាយច្រើន។ ហើយអត់មានអីសរសេរស្លាកសញ្ញាអី អត់មានទេបាទ។ បាទ មានប៉ុណ្ណឹងបាទ។

[១៤:២៩:៣៣]

**ស៖** ពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែក ហើយនិង-- ខ្ញុំគិតថា មិនមានការទម្លាក់គ្រាប់បែកទៀតទេ តាំងពីឆ្នាំ៧៣ ដោយពួកអាមេរិកនោះ។ តើលោកខ្លួនឯងហ្នឹង លោកជឿទៅលើមូលហេតុនៃការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញថា ដោយសារតែមានការភ័យខ្លាច ក្នុងការទម្លាក់គ្រាប់បែកហើយត្រូវតែជម្លៀសប្រជាជន តើលោកជឿអីចឹងទេ?

**ផ៖** ខ្ញុំយល់មិនដល់ដែរ តែខ្ញុំស្តាប់វិន័យ ហើយខ្ញុំជឿថាចលនាទូទៅវាអ៊ីចឹងហើយ ទៅតាមហ្នឹងទៅបាទ។

**ស៖** តើគេបាននិយាយប្រាប់ប្រជាជនទីក្រុងភ្នំពេញថា តាមពិតទៅពួកគាត់ត្រូវចេញទៅរហូតគឺមិនអាចត្រឡប់មកវិញបានទេ ហើយគឺថានៅក្នុងអំឡុងរបបខ្មែរក្រហម។ តើគេមាននិយាយអ៊ីចឹងប្រាប់ប្រជាជនទេ?

**ផ៖** ខ្ញុំឮ ហើយខ្ញុំទទួលថា ចេញបណ្តោះអាសន្នប៉ុណ្ណឹងបាទ។

**ស៖** ក្នុងជួរកម្លាំង ហើយនិងក្នុងសាខាឃោសនាអប់រំរបស់លោក ហើយនិងជាទូទៅនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើមិនមានការភ័យខ្លាច ឬក៏ការមិនទុកចិត្តពាក់ព័ន្ធទៅនឹងប្រជាជនដែលបានគេច-- សូមទោស ដែលបានទៅទីក្រុងភ្នំពេញ ដើម្បីឲ្យមានការគាំទ្រពីខាងទ័ព លន់ នល់។ តើខាងខ្មែរក្រហមមានការមិនទុកចិត្តចំពោះប្រជាជនអ្នកទីក្រុងទេ ជាទូទៅ?

[១៤:៣១:២៣]

**ផ៖** ចំពោះរឿងនេះ កាលណោះមានការបែងចែកជាពីរ។ ខាងក្នុង និងខាងក្រៅ។ តែពាក្យស្លោកណែនាំគឺទទួលស្វាគមន៍ប្រជាជនទាំងអស់ ហើយយកមកជួយដោះស្រាយជីវភាពបាយទឹក កន្លែងរស់នៅទៀត។ ឯការទទួលបានល្អ មិនបានល្អ អាហ្នឹងខ្ញុំយល់មិនដល់ទេ ទៅតាមសភាពជាក់ស្តែងកន្លែងនីមួយៗ។ តែឲ្យទុកជាសត្រូវ អត់មានទេ។ គឺគិតថាស្វាគមន៍ឲ្យល្អទាំងបាយ ទាំងទឹក ទាំងទីកន្លែង អីទាំងអស់។ ប៉ុណ្ណឹងដែលខ្ញុំបានទទួលបាទ។

**ស៖** ឥឡូវនេះមកនិយាយអំពីថ្ងៃទី១៧ មេសា ហើយនិងពីរថ្ងៃក្រោយមក។ តើការជម្លៀសប្រជាជននេះត្រូវបានរៀបចំយ៉ាងដូចម្តេច? ហើយវាមានការប្រព្រឹត្តទៅយ៉ាងណាដែរ?

**ផ៖** ខ្ញុំបានជម្រាបម្តងហើយ។ ការឃោសនាអំពាវនាវឲ្យចេញពីក្រុង គឺដោយហេតុផលដើម្បីធានាសន្តិសុខពីរឿងគ្រាប់បែក ពីរឿងវ៉ៃដណ្តើមទៅវិញទៅមកម្តងទៀត។ តែសំខាន់គ្រាប់បែកទីមួយ។ ទីពីរ ការអំពាវនាវឲ្យចេញនេះ ឲ្យចេញទៅតាមសំណូមពរ អ្នកកំពង់ចាម អ្នកកំពង់ធំ ឬអ្នកនៅម៉្លុំជិតអីនេះទៅរៀងខ្លួនទៅ។ ឲ្យតែស្គាល់កន្លែងណាទៅកន្លែងហ្នឹងទៅ។ នេះតាមខ្ញុំក្តាប់បានប៉ុណ្ណឹង។ មិនមានជាការចាត់តាំងបង្ខំថាត្រូវតែទៅកំពង់ស្ពឺ ទៅកំពង់ចាម អត់ទេ ធ្វើម៉េចឲ្យតែចេញឲ្យផុតពីទីក្រុង។ ហើយខ្ញុំបានទទួលការណែនាំប៉ុណ្ណឹងបាទ។

[១៤:៣៤:៣០]

**ស៖** តើគេបានឲ្យមធ្យោបាយធ្វើដំណើរអ្វីខ្លះទៅឲ្យប្រជាជន ពីសំណាក់ខាងកងទ័ពខ្មែរក្រហម? ជាពិសេសចំពោះមនុស្សងាយរងគ្រោះ ដូចជា មនុស្សចាស់ជរា អ្នកជំងឺ ស្ត្រីមានផ្ទៃពោះ និងកុមារជាដើម។ ពាក់ព័ន្ធទៅនឹងខាងសម្ភារៈសម្រាប់ធ្វើដំណើរនោះ តើគេមានផ្តល់ជាសម្ភារៈអ្វីខ្លះដើម្បីឲ្យពួកគាត់ត្រឡប់ទៅកាន់ភូមិកំណើតវិញនោះ?

**ឆ៖** តាមខ្ញុំមើលដូចមិនមានលទ្ធភាពអី យកមធ្យោបាយអីមកទទួលទេ គឺទៅតាមលទ្ធភាពរបស់គ្រួសាររបស់បុគ្គល ហើយបើជួបទាហាន ទាហានជួយសែងជួយអីខ្លះអ៊ីចឹងទៅ។ តែឲ្យថាមានចាត់តាំងជាក្បួនខ្នាតអីមកទទួលដូចអត់មានទេ។ ហើយទៅនេះ ទៅដល់ត្រង់ណា សំណាក់ត្រង់ហ្នឹងបណ្តើរៗអ៊ីចឹងទៅ។ ដូច្នេះ អត់មានទេ អត់មានការចាត់តាំងអីច្បាស់លាស់ គ្មានមធ្យោបាយអីទេ ព្រោះស្ថិតក្នុងសភាពវឹកវរវៀងខ្លួនបាទ។

[១៤:៣៥:៥៧]

**ស៖** លោកនិយាយអំពីស្ថានភាពវឹកវរ ប៉ុន្តែយើងដឹងហើយថា គោលដៅចុងក្រោយហ្នឹងគឺថាដើម្បីយកទីក្រុងភ្នំពេញ។ អ៊ីចឹងថា គាត់មានការរៀបចំទុកជាមុនទេ សម្រាប់ការជម្លៀសប្រជាជនភ្នំពេញនោះ?

**ឆ៖** រៀបចំ ខ្ញុំចាំមានតែប៉ុណ្ណេះទេ គ្រាន់តែថា អ្នកដែលនៅកន្លែងចាស់ហើយ ចាំទទួលអ្នកថ្មី អ្នកថ្មីហ្នឹងមកទទួលផង ឲ្យរស់នៅផងទៅ ចែកបាយចែកទឹកផងទៅ។ តែខ្ញុំកត់សម្គាល់ ចែកយ៉ាងណាក៏មិនគ្រប់ដែរ ពីព្រោះមកជាគំនរអ៊ីចឹងមកហើយ ហើយអ្នកនុ៎ងក៏មិនមែនជា អ្នកដែលនៅខាងក្រោយហ្នឹងជាអ្នកមានលទ្ធភាពអីគ្រប់គ្រាន់ដែរបាទ។

**ស៖** ពេលនោះ គឺខែមេសា ហើយយើងដឹងហើយថាពេលនៅប្រទេសកម្ពុជានោះ ខែមេសា គឺក្តៅណាស់។ តើខ្មែរក្រហមមានបានគ្រោងទុកអីជាមុនទេ ដើម្បីផ្តល់ជាអាហារហូបចុករបស់ប្រជាជនដូចជា ផ្តល់ទឹក ឬក៏សម្រាប់ឲ្យពួកគាត់រស់នៅ សម្រាប់ការពារពួកគាត់ពីម្ងស ហើយដើម្បីព្យាបាលប្រឆាំងទៅនឹងជំងឺគ្រុនចាញ់ ឬក៏ជំងឺរាគរូស នៅក្នុង-- នៅតាមផ្លូវនោះ ព្រោះថាពេលនោះគឺក្តៅខ្លាំងណាស់?

[១៤:៣៧:៣៨]

**ឆ៖** បញ្ហាល្អិត ដូចលោកបានលើកឡើងនេះ តាមខ្ញុំយល់ដូចជាមិនបានគ្រោងល្អិតអ៊ីចឹងទេបាទ។

**ស៖** ចំពោះអ្នកដែលប្រកែកមិនព្រមចេញ តើមានដែរឬទេ? ហើយមានអីកើតឡើងប្រសិនបើមានអ្នករឹងទទឹងមិនព្រមចេញទៅនោះ?

**ឆ៖** ខ្ញុំឃើញតែចេញហែៗអ៊ីចឹង តែឲ្យឃើញថា ប្រទូសរ៉ាយអី ខ្ញុំមិនឃើញដែរព្រោះមុខព្រួញខ្ញុំចូលនោះវាមិនឃើញ មានអីទេឃើញតែនាំគ្នាចេញហែៗតាមឃោសនាថា ឲ្យចេញៗតែម្តង ចេះចេញអ៊ីចឹងមកបាទ។

**ស៖** លោកចង់ន័យថា មិនមានអ្នកណាម្នាក់ទេប្រឆាំង ទៅនឹងការបញ្ជាឲ្យចេញពីទីក្រុងភ្នំពេញ ហើយមិនមានអ្នកណាម្នាក់ព្យាយាមក្នុងការគេចវេះមិនទៅ សុខចិត្តនៅដើម្បីថា ទោះបីជាមានគ្រាប់បែកក៏ដោយ តើអ៊ីចឹងមែនទេ គឺថាអ្នកទាំងគ្នាព្រមចេញតែម្តង គ្មានអ្នកណារឹងទទឹងទេ មែនទេ?

[១៤:៣៩:១៨]

**ឆ៖** ខ្ញុំឆ្លើយមិនបានទេ ព្រោះក្តាប់មិនបានទាំងអស់ដែរបាទ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមចូលទៅដល់ប្រធានបទមួយទៀត។ ឥឡូវនេះ ម៉ោងពីរសែសិបហើយ តើយើងត្រូវសម្រាក ឬក៏ខ្ញុំបន្តទៅទៀតលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:១៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៥:០១:២៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំមានសំណួរពីរមុននឹងចូលទៅដល់ប្រធានបទថ្មី។ ចំពោះកសិករដែលរស់នៅទីក្រុងភ្នំពេញ ពួកគេត្រូវបានជម្លៀសទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ។ ចុះចំពោះអ្នកដែលមានដើមកំណើតនៅទីក្រុងភ្នំពេញ តើពួកគេត្រូវទៅណាវិញ បើគាត់រស់នៅទីក្រុង-- បើកើតនៅទីក្រុងភ្នំពេញនោះ ព្រោះថាគាត់មិនដឹងថាតើចេញទៅណានោះទេ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយបាទ។ ចំពោះបញ្ហានេះ ខ្ញុំដឹងជាគោលការណ៍រួមថា អ្នកចាស់នៅមូលដ្ឋានចាស់មានតួនាទីទទួលអ្នកថ្មី ហើយអ្នកថ្មីនុំងមិនបានកំណត់រើសអើងថា ស្រុក ភូមិ ឃុំនៅឯណាទេ ឲ្យតែទៅចំចំណុចណា ចំណុចនុំងទទួលខុសត្រូវ ទទួលបាទ។

[១៥:០២:៤៦]

**ស៖** លោកសាក្សី លោកបាននិយាយថា លោកចូលទៅទីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ ៧៥ មកពីតំបន់១៥ នៃភូមិភាគពិសេស។ តើលោកស្នាក់នៅទីក្រុងភ្នំពេញបានប៉ុន្មានដែរ បន្ទាប់ពីរំដោះភ្នំពេញបាទ?

**ឆ៖** សូមឆ្លើយបាទ។ ខ្ញុំវិលមកវិញទាំងយប់ ចូលម៉ោងប្រាំបួន ម៉ោងដប់ពីរខ្ញុំជិះម៉ូតូត្រឡប់

មកវិញ មកនៅតំបន់១៥វិញ។ អត់បានដេកនៅក្រុងភ្នំពេញទេ។

**ស៖** នៅពេលដែលលោកជិះម៉ូតូត្រឡប់ទៅវិញនៅពេលយប់ តើលោកមានបានជួបអ្នកដែលធ្វើដំណើរទៅកាន់ខដុង្គ ដែលបានជម្លៀសចេញពីទីក្រុងទេ?

**ឆ៖** ជួបច្រើនបាទ ហូរហែតាមផ្លូវរហូត ពីព្រោះមនុស្សក្រុងភ្នំពេញច្រើនណាស់ មុននឹងរើរំដោះយកបាននោះ។ ហេតុនេះចេញមកគ្រប់ច្រកតាមផ្លូវហ្នឹងច្រើនណាស់។ បាទសូមឆ្លើយប៉ុណ្ណឹងបាទ។

[១៥:០៤:២៧]

**ស៖** តើអ្នកដែលចាកចេញតាមផ្លូវហ្នឹង មានសេចក្ដីសប្បាយរីករាយទេក្នុងការចាកចេញ ឬក៏ពួកគាត់មានការលំបាកក្នុងការចាកចេញ?

**ឆ៖** សូមឆ្លើយ។ តាមមើលខ្ញុំយល់ជាសច្ចធម៌ អ្នកដែលបោះបង់ភូមិកំណើត គឺបោះបង់ផ្ទះសម្បែងចេញមិនសប្បាយទេ តែសង្គ្រាម ហើយមានការអំពាវនាវអ៊ីចឹងតាមមើល ចេះតែទៅតាមហ្នឹងទៅបាទ។

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីមុខងាររបស់លោក ក្នុងនាមជាឃោសនិកអប់រំ លោកបាននិយាយថា លោកបានបំពេញការងារនេះនៅខេត្តសៀមរាបក្នុងមួយរយៈ ហើយបន្ទាប់មកលោកបានបំពេញមុខងារដដែលនេះនៅតំបន់១៥ នៃភូមិភាគពិសេស។ ហើយបន្ទាប់មកទៀតលោកទៅតំបន់៣២ នៃភូមិភាគបស្ចិម ដែលនៅទីនោះលោកធ្វើជាអ្នកទទួលខុសត្រូវក្នុងការឃោសនាអប់រំមហាជន។ តើយើងអាចនិយាយបានទេ ថាលោកមានបទពិសោធន៍ច្រើនខាងផ្នែកអប់រំឃោសនាអប់រំមហាជននេះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូន។ បទពិសោធន៍របស់ខ្ញុំមានតែត្រឹមថាចេះចងក្រងជាឃ្លាឃ្លោង លំនាំដើម ខ្លឹមសារចង់បានប៉ុណ្ណឹង។ តែត្រង់ក្រៅពីហ្នឹងទៀតលទ្ធផលអ្នកដែលស្ដាប់ខ្ញុំហ្នឹង គេទទួលបានប៉ុន្មាន គេយកទៅអនុវត្តប៉ុន្មាន ខ្ញុំមិនដឹងដែរ មិនច្បាស់លាស់ដែរបាទ។

[១៥:០៦:៤៨]

**ស៖** អម្បាញ់មិញនេះលោកនិយាយថា លោកត្រូវបំពេញភារកិច្ចឃោសនាអប់រំចំពោះ ប្រជាជនដើម្បីបញ្ចុះបញ្ចូលឲ្យពួកគាត់គាំទ្រចលនាបដិវត្តន៍។ ដូច្នេះខ្ញុំគិតថា លោកមានទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាជន មិនត្រឹមតែមានទំនាក់ទំនងតាមរយៈការសរសេរទេ គឺលោកបានទាក់ទងផ្ទាល់តែ

ម្តង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ហ្នឹងគេហៅថាឃោសនាអប់រំហ្នឹង គេមានកន្លែងគេ។ ហើយប្រធានភូមិ ឬអ្នកទទួលខុសត្រូវផ្នែកមួយៗគេនាំកម្លាំងគេមកប្រមូលផ្តុំកន្លែងហ្នឹង។ ដូច្នេះចន្លោះហ្នឹង យើងអប់រំ យើងស្គាល់អ្នកហ្នឹងពេលដែលសម្រាក សន្ទនាអីខ្លះៗតាមហ្នឹងបាទ។

**ស៖** នៅពេលដែលលោកបំពេញភារកិច្ចរបស់លោកក្នុងឋានៈជាឃោសនិកអប់រំមហាជន ក្នុងអំឡុងវគ្គរៀនសូត្រ ឬក៏ក្នុងពេលដែលលោកទំនាក់ទំនងប្រជាជន តើលោកត្រូវតែគោរពគោលការណ៍ ឬក៏មាគ៌ានយោបាយ ឬក៏មាគ៌ាយុទ្ធសាស្ត្រជាមូលដ្ឋានរបស់បក្សដែរឬទេ?

[១៥:០៨:៣៤]

**ឆ៖** មាគ៌ានុំង គេមិនបានចែងថាធ្វើអីៗទេ។ តែបើលើកជាខ្លឹមសារថា បង្កបង្កើនផលឧបត្ថម្ភខ្លួន ហ្នឹងគេហៅថាមាគ៌ា ដែលគេដកស្រង់ថាឲ្យប្រជាជនហ្នឹងខំរកស៊ីខ្លួនឯង ឧបត្ថម្ភខ្លួនឯង ហើយឧបត្ថម្ភសមរភូមិផង។ ហ្នឹងបានយល់បានប៉ុណ្ណឹង រួចហើយការពារសន្តិសុខខ្លួនឯង ជីកត្រង់សេ ជីកអីអីចឹងទៅ ហ្នឹងជាខ្លឹមសារ។ ដូច្នេះខ្ញុំយល់ថាច្បាស់ជាគេដកស្រង់ពីគោលនយោបាយឬមាគ៌ាអីចឹងហើយ តែឲ្យយល់ជ្រៅថាមាគ៌ាយុទ្ធសាស្ត្រយ៉ាងម៉េច វែងឆ្ងាយទៅទៀត ខ្ញុំមិនយល់ទេ ខ្ញុំយល់បានប៉ុណ្ណឹងបាទ។

**ស៖** ក្រោយឆ្នាំ១៩៧៥ តើលោកត្រូវតែផ្តល់ព័ត៌មានដល់មហាជននៅពេលដែលលោកទំនាក់ទំនងជាមួយមហាជននេះ។ តើអីចឹងមែនទេ? តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមបញ្ជាក់សំណួរហ្នឹងម្តងទៀតបាទ! ផ្តល់--

**ស៖** ក្នុងការបំពេញមុខងាររបស់លោក ខ្ញុំគិតថា វាជាការសំខាន់ណាស់ដែលថាលោកមិនត្រូវផ្តល់ព័ត៌មានខុសដល់មហាជននោះទេ គឺថាត្រូវតែដឹងថា តើបក្សចង់បានអ្វី ចង់ឲ្យលោកនិយាយអ្វីជូនមហាជននៅពេលដែលលោកជួបប្រជាជន។ តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយបែបនេះ?

**ឆ៖** ឆ្លងតាមអ្នកពាំនាំមកផ្សព្វផ្សាយបន្ត គឺខ្ញុំត្រូវតែអនុវត្តតាមហ្នឹងបាទ។ អត់មានអីនិយាយលើស និយាយខ្លះអីក្រៅពីអ្នកពាំនាំយកមកឲ្យខ្ញុំផ្សព្វផ្សាយទេ។ ដូច្នេះ ខ្ញុំគ្មានអីលាក់លៀមចំពោះមហាជន ប្រជាជនទេ។ ដឹងប៉ុនណា យល់ប៉ុនណា បញ្ជាក់ជូនប៉ុណ្ណឹងបាទ។

[១៥:១១:២៧]

**ស៖** តើមានឯកសារមួយចំនួន ដែលលោកត្រូវសិក្សាក្នុងឋានៈបក្ខជន ឬក៏ក្នុងឋានៈជាកម្មាភិបាលបក្ស ឬក៏ថាលោកត្រូវតែផ្តល់សារសំខាន់ទៅដល់មហាជន តើលោកអាចផ្តល់ឧទាហរណ៍អំពីឯកសារដែលលោកមាន សម្រាប់ជាការយោង សម្រាប់ជាការអប់រំឃោសនាដល់ប្រជាជននៅក្នុងក្របខ័ណ្ឌនៃការងារជាឃោសនិកអប់រំរបស់លោក? លោកអាចផ្តល់ជាឧទាហរណ៍ខ្លះៗបានទេ?

**ឆ៖** ឯកសារដែលខ្ញុំជម្រាបជូនបន្តបន្ទាប់ គឺវាមានលម្អិតក្នុងខ្លឹមសារដែលខ្ញុំជម្រាបជូន។ ខ្លឹមសាររួមគេថា “សម្រុកបង្កបង្កើនផល ឧបត្ថម្ភខ្លួន ដើម្បីអនុវត្តនយោបាយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន” ហ្នឹងជាខ្លឹមសារ។ ហើយការចងចាំ ខ្ញុំចងចាំអ៊ីចឹង ចងចាំថា អាហ្នឹងហើយដែលខ្លឹមសារដែលខ្ញុំបានអាន ដែលបានទទួល ហើយយកទៅអប់រំ។ ឯឃោសនាអប់រំ បំបែក ម៉េចទៅហៅថាបង្កើនផល? ម៉េចទៅហៅថាឧបត្ថម្ភខ្លួន? ម៉េចទៅហៅថាឯករាជ្យម្ចាស់ការ? អាហ្នឹងប៉ុណ្ណឹងបាទ។ ហើយពិចារណាដែរ មុននឹងទៅឃោសនា។ បើមិនពិចារណាទៅ យកទៅនិយាយអី ក៏វាមិនចេញដែរបាទ។ ត្រូវពន្យល់ព្រោះធម្មតាប្រជាជនយល់បានតិចណាស់។

**ស៖** លោកជាកម្មាភិបាលសំខាន់គួរសមនៅក្នុងភូមិភាគបស្ចិម ក្នុងឋានៈជាឃោសនិកអប់រំក្នុងតំបន់៣២។ ក្នុងឋានៈជាកម្មាភិបាល តើលោកធ្លាប់ស្គាល់លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** សូមឆ្លើយ។ លក្ខន្តិកៈបក្សហ្នឹង គេផ្សាយផ្ទៃក្នុង គេមិនផ្សាយចំហ ហើយបក្សហ្នឹងគេមានថ្នាក់ បក្សកម្រិតណា អីកម្រិតណា។ ដូច្នោះ មិនមែនយកលក្ខន្តិកៈទាំងមូលអីមកផ្សព្វផ្សាយអីទេ គេដកស្រង់តាមថ្នាក់ តាមជាន់។ ហើយកម្រិតឋានៈរបស់កម្មាភិបាល គឺមានកម្រិត។ ដូច្នេះ ខ្ញុំស្គាល់តែត្រួសៗទេ។ គ្រាន់តែខ្ញុំចាំបានខ្លះ គឺថាការងារគេ គេដឹង។ ការងារយើង យើងដឹង។ មិនអាចទៅចច្រប់សួររឿងនេះ រឿងនោះបានទេ។ ទីពីរ ថ្នាក់ក្រោមគោរពថ្នាក់លើ។ បាទដែលខ្ញុំចាំប៉ុណ្ណឹង។

[១៥:១៥:២០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញនូវឯកសារជាភាសាខ្មែរនូវលក្ខន្តិកៈរបស់បក្ស ដែលជាឯកសារលេខ E3/130 និងឯកសារលេខ D366/7.1.187។ ដូច្នេះ សុំអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងឯកសារនេះ នៅលើអេក្រង់ ហើយនៅពេលបញ្ចាំងហើយនោះ ខ្ញុំនឹងបញ្ជាក់ជូនថានៅទំព័រឲ្យច្បាស់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ប៉ុន្តែសូមបញ្ជាក់ឡើងវិញម្តងទៀតមើល ឯកសារ D366/7.1.187 ឬក៏188?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន គឺឯកសារលេខ E3/130 ឬក៏ឯកសារលេខ D366/7.1.187។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន តើខ្ញុំអាចផ្តល់ឯកសារនេះ ជូនទៅសាក្សីបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ជូនទៅសាក្សីពិនិត្យ។

[១៥:១៧:១៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមទុកពេលមួយចំនួនឲ្យសាក្សី ដើម្បីពិនិត្យមើលឯកសារនេះ។ សូមឲ្យលោកសាក្សីមេត្តាពិនិត្យមើលមាត្រាទាំង៣០នៃលក្ខន្តិកៈនេះ គឺចាប់ពីទំព័រ 00442257 គឺថាមានសេចក្តីផ្តើមពាក់ព័ន្ធទៅនឹងគោលការណ៍ និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្ស ក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះលោកនិយាយថា លោកដឹងអំពីលក្ខន្តិកៈនេះ ដែលត្រូវបានផ្សព្វផ្សាយផ្ទៃក្នុង ហើយលោកបានដឹងអំពីផ្នែកមួយចំនួននៃលក្ខន្តិកៈនេះ។ តើលោកស្គាល់ឯកសារដែលបានបង្ហាញជូនលោក នៅនឹងមុខលោកនេះទេ? ថាតើនេះជាលក្ខន្តិកៈរបស់បក្ស ឬក៏មិនមែនទេ?

[១៥:១៩:២៤]

**លោក នី កន៖**

**ឆ៖** បាទ ជារូបភាព និងខ្លឹមសារខ្លះៗ ដែលខ្ញុំបានដឹង បានទទួលផ្សព្វផ្សាយអប់រំមកលើបក្ខជនហ្នឹង ខ្ញុំឃើញថាជាការពិតហើយ បាទ។ តែមិនបានយល់ទាំងអស់ទេ ឃើញតែត្រួសៗ ទេបាទ។

**ស៖** សូមឲ្យលោកពិនិត្យមើលចំណុចមួយចំនួន ជាដំបូង គឺនៅទំព័រជាភាសាខ្មែរ 00442253 ទៅដល់ 54។ គឺចំណុចទីពីរ នៅទំព័រនេះ ហើយជាភាសាបារាំងគឺ 00292916 ERN ជាភាសាអង់គ្លេស 00184024។ នេះគឺជាទំព័រដែលមានចំណងជើងថា "លាក់ការណ៍ និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្សក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម"។ នៅចុងបញ្ចប់នៃចំណុចទីពីរ មានការសរសេរថា "បក្សកុម្មុយនីស្តកម្ពុជាជារបស់វណ្ណៈកម្មករ ហើយនិងតំណាងឲ្យផលប្រយោជន៍វណ្ណៈកម្មករ និងកសិករ ហើយនិងតំណាងឲ្យប្រជាជនប្រជាតិទាំងមូល"។ សូមបញ្ចប់ការដកស្រង់។ ប្រសិនបើនៅក្នុងក្រសែភ្នែករបស់បក្ស មានតែកម្មករនិងកសិករ តើអ្នកដែលស្ថិតនៅក្នុងវណ្ណៈដែលរបបចាត់ទុកថាជានាយទុន គហបតី ពួកសក្តិភូមិ ម្ចាស់ដី ឬក៏ពួកចក្រពត្តិនិយម។ តើអ្នកទាំងអស់នេះ មានស្ថានភាពបែបណា? តើពួកគេអាចចូលទៅក្នុងបក្សបានដែរឬទេ?

**ឆ៖** សូមឆ្លើយបាទ។ ខ្ញុំឆ្លើយនេះទៅតាមការ-- ទៅតាមកម្រិតយល់ដឹងរបស់ខ្ញុំទេ។ ខ្ញុំបានស្តាប់ទៅឃើញការសរសេរ ការផ្សព្វផ្សាយអ៊ីចឹង តែដែលលោកសួរខ្ញុំថា តើកម្លាំងដទៃទៀតទុកជាយ៉ាងម៉េចវិញ? ខ្ញុំមិនយល់ដែរ ខ្ញុំយល់ដូចខ្ញុំបានជម្រាបជូនក្នុងការដែលខ្ញុំឃោសនាអប់រំ គឺថាកម្លាំងជាតិទាំងមូល តាំងពីលើរហូតដល់ក្រោម ហើយរហូតពេលនោះមានតាំងព្រះមហាក្សត្រផងចូលរួមបានដែរ ខ្ញុំក៏រីករាយអបអរសាទរទៅតាមហ្នឹងទៅ។ តែដល់មានការចែងក្នុងផ្ទៃក្នុងអ៊ីចឹង ខ្ញុំមិនយល់ដែរ។ អត់យល់ទេបាទ ប៉ុណ្ណឹង។

[១៥:២៣:៥៦]

**ស៖** សូមអរគុណ។ ចំពោះចំណុចបី គឺនៅទំព័រដដែលនេះ គឺខ្ញុំគិតថាប្រហែលជាក្នុងភាសាទាំងបីហើយនៅក្នុងទំព័រដដែល។ ក្នុងទំព័រនោះនិយាយថា ក្នុងបរិបទនេះគឺថាត្រូវតែ បក្សកុម្មុយនីស្តកម្ពុជា ត្រូវការពារលទ្ធផលបដិវត្តន៍ និងការពារប្រទេសឲ្យបានល្អផង ហើយនិងដំណើរការកសាងប្រទេសឲ្យបានល្អផង។ គឺនៅកថាខណ្ឌទីពីរនៅខាងក្រោមចំណុចទីបី។

នៅទីនេះគឺមានគោលការណ៍ពីរ ដែលមានចែងនៅក្នុងលក្ខន្តិកៈនេះ គឺការពារបដិវត្តន៍ និងប្រទេស ហើយនិងកសាងប្រទេស។ តើលោកដឹងទេថា តើគេត្រូវការពារប្រទេស និងបដិវត្តន៍ប្រឆាំងនឹងអ្នកណា? តើអ្នកណាជាការគំរាមកំហែងដល់បដិវត្តន៍?

**ឆ៖** សូមឆ្លើយបាទ។ ខ្ញុំយល់ទៅតាមគោលការណ៍ចាស់ដដែល គោលការណ៍ចាស់ ខ្ញុំយល់ថា វៃចក្រពត្តិ ហើយលើកស្ទួយជីវភាពប្រជាជន ហើយការពារបូរណភាពដែនដី។ ខ្ញុំយល់បានតែប៉ុណ្ណឹងបាទ។ ឯវែងឆ្ងាយទៅទៀតមិនយល់ដែរ។

[១៥:២៦:០១]

**សៈ** និយាយអំពីការការពារប្រទេស និងបដិវត្តន៍ដដែលនេះ តើមានខ្មាំងខាងក្រៅ ឬក៏ខ្មាំងខាងក្នុងហ្នឹងដែរឬទេ? ព្រោះថាលោកនិយាយអំពីចក្រពត្តិ តើជាកម្លាំងខាងក្រៅ ឬក៏ជាកម្លាំងដែលលាក់បង្កប់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ឬក៏ក្នុងប្រទេស?

**ឆ៖** បាទ កម្លាំងដែលខ្ញុំកត់សម្គាល់អំមិញហ្នឹងគឺ ខ្ញុំសំដៅតែកម្លាំងដែលតស៊ូជាមួយគ្នា វៃជាមួយគ្នា ហើយក្នុងហ្នឹងមានជំនាន់នុ៎ងមានខាង លន់ នល់ ហើយនិងខាងអាមេរិក។ ដូច្នេះ ខ្ញុំយល់ប៉ុណ្ណឹង។ ឯយ៉ាងម៉េចទៀត មកតាមក្រោយមកទៀត ខ្ញុំមិនយល់ដែរហ្នឹង។

[១៥:២៧:១៨]

**សៈ** សូមចូលទៅដល់ចំណុចទី៦ ជាភាសាខ្មែរគឺ ERN 00442255 ជាភាសាបារាំង ERN 00292917 និងជាភាសាអង់គ្លេស 00184025។ ចំណុចទី៦ ឃ្លាទីពីរ ខ្ញុំសូមអានដូចតទៅនេះ៖ "បក្សត្រូវការពារបដិវត្តន៍ឲ្យខ្ពស់ដល់កម្រិត ចំពោះសកម្មភាព និងគ្រប់កលល្បិចរបស់ខ្មាំង ជាផ្ទាល់ ជាប្រយោល ជាចំហ ជាសម្ងាត់ ដែលប៉ងប្រាថ្នាបំផ្លិចបំផ្លាញបក្សតាមគ្រប់វិធី។ គ្រប់អង្គការបក្ស និងបក្ខជនគ្រប់រូបត្រូវល្អស្អាតបរិសុទ្ធខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជានិច្ច តាមការកសាងប្រវត្តិរូបច្បាស់លាស់ និងស្អាតបរិសុទ្ធជាបន្តបន្ទាប់ជាប់ជានិច្ច"។ សូមបញ្ចប់ការដកស្រង់។ ហើយប្រសិនបើយើងឡើងទៅលើបន្តិចទៅ នៅកថាខណ្ឌទី១ នៃចំណុចទី៦ ដដែលនេះគឺមាននិយាយថា៖ "បក្សកុម្មុយនីស្តកម្ពុជា ចាត់តាំងឡើងតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ហើយបន្ទាប់មកទៀតមានការនិយាយថា បក្សមានអង្គការវិន័យរឹងប៉ឹងតែមួយគត់"។ ហើយតមកទៀត៖ "បក្សប្រឆាំងដាច់ខាតនឹងអំពើល្មើសអង្គការវិន័យ"។

សំណួរទីមួយ តើលោកមាននិយាយអំពីវិន័យបក្សប្រាប់ដល់មហាជនដែរឬទេ នៅពេលដែលលោកឃោសនាអប់រំពួកគាត់ ឬមួយក៏លោកព្យាយាមបញ្ចុះបញ្ចូលពួកគាត់ឲ្យគាំទ្រចលនាបដិវត្តន៍ និងគាំទ្របក្សនោះ?

[១៥:២៩:៤២]

**ឆ៖** សូមឆ្លើយ។ តាមដែលខ្ញុំស្ដាប់សំណួរលោកអម្បាញ់មិញនេះ គឺវាទាក់ទិនដល់ការងារផ្ទៃក្នុង និងការងារមហាជន។ ទីមួយ អម្បាញ់មិញនេះជាការងារផ្ទៃក្នុងរបស់បក្ស។ ដូច្នោះខ្ញុំគ្មិ អ្នកដទៃទៀតក្ដី ថ្នាក់ក្រោមមិនអាចដឹងទេ មិនអាចយល់ទេ។ តើប្រជាធិបតេយ្យរៀបចំចាត់តាំងបក្សយ៉ាងម៉េចៗ សមត្ថភាពកម្រិតខ្ញុំទៅមិនដល់ទេ។ ដូច្នេះយកអីជាមូលដ្ឋានដើម្បីឆ្លើយនឹងលោកមិនបានទេ។ ទីពីរ ធម្មតា មួយគេហៅផ្ទៃក្នុង មួយគេហៅខាងមហាជន។ ដូច្នេះគេមិនអាចយករឿងផ្ទៃក្នុងទៅនិយាយទាំងអស់ឲ្យមហាជនស្ដាប់បានទេ។ គេមានលាក់ការណ៍ខាងក្នុងខាងក្រៅ។ អ៊ីចឹងសូម្បីតែខ្ញុំ ខ្ញុំទទួលបានកម្រិតដែលគេដកស្រង់។ សូម្បីតែថាមានតួនាទីជាសមាជិកក៏ដោយ ក៏គេដកស្រង់តាមថ្នាក់កម្រិតគុណភាពរបស់បុគ្គល។ ដូច្នោះបើប្រៀបធៀបទៅនឹងប្រជាជនមហាជនទៀត រឹតតែគេមិនអាចយកពាក្យសម្ដីហ្នឹងទៅនិយាយទេ។ បាទ សូមអស់មតិបាទ។

[១៥:៣១:៣៣]

**ស៖** តើលោកនិយាយអីខ្លះ ប្រាប់ទៅដល់មហាជនពាក់ព័ន្ធទៅនឹងវិន័យ ដែលត្រូវគោរពនោះ? តើមានវិន័យអ្វីខ្លះដែលប្រជាជន ឬក៏មហាជនត្រូវគោរពនោះ?

**ឆ៖** វិន័យដែលខ្ញុំបំពាក់នោះគឺ កម្រិតមហាជនត្រង់ថា ធ្វើការឲ្យទៀងទាត់ម៉ោងពេល។ ទីពីរ សន្សំសំចៃ។ ទីបី ខំធ្វើម៉េច ធ្វើស្រែ ធ្វើចម្ការហ្នឹងឲ្យបានផលលើសពីហូបចុក ហើយឧបត្ថម្ភសមរភូមិ ឬឧបត្ថម្ភអ្នកមកថ្មី តែប៉ុណ្ណឹង។ ហើយក្រៅពីហ្នឹងដូចគ្មានវិន័យអីទៀតទេ ពីព្រោះជាប្រជាជន បាទ។

**ស៖** ចំពោះសីលធម៌ តើគេអាចធ្វើអ្វីតាមចិត្ត ឬក៏មានសេចក្ដីណែនាំពាក់ព័ន្ធទៅនឹងសីលធម៌រស់នៅរបស់ប្រជាជន ទោះជាបក្ស ឬក៏ជាមហាជននោះ?

**ឆ៖** សូមបញ្ជាក់សំណួរនេះម្ដងទៀតមើល ចង់សួរសីលធម៌ពីរឿង ដូចរឿងអីបាទ។ ខ្ញុំមិនទាន់យល់ច្បាស់សំណួរបាទ។

[១៥:៣៣:២៦]

**ស៖** សំណួរខ្ញុំ គឺចង់ដឹងថា ក្នុងក្របខ័ណ្ឌនៃវិន័យដែលយើងត្រូវគោរព តើយើងត្រូវមានសីលធម៌រស់នៅល្អ ឬក៏ថាមានការ-- អ្នកថា មានតែអ្នកខ្លះមិនសូវមានសីលធម៌ល្អនោះ? អ៊ីចឹងមែនទេ? មានអ៊ីចឹងទេ?

**ឆ៖** អឺ! សូមឆ្លើយបញ្ជាក់។ សីលធម៌ដែលគេចែងក្នុងពេលនោះគឺចែងថា កុំលួច ហើយកុំខិលខូច ខុសប្រពៃណី មានការអឺស្នើយោបល់មកតាមថ្នាក់ៗ ហើយដោះស្រាយ។ បើមានប៉ះពាល់អី

ប្រជាជនត្រូវសុំទោស។ ហ្នឹងដែលខ្ញុំចាំ។ ម្ទេសមួយផ្លែ បើទៅបេះរបស់ប្រជាជន មិនបានសុំ គឺខុសហើយ។ ម្ចាស់មិននៅក៏ត្រូវសុំ ហើយបើចាំបាច់ កាលនោះមិនមានលុយកាក់ទេ តែត្រូវសុំ។ សុំៗទោស សុំជាផ្លូវការថា “សុំ”។ ដូច្នេះសីលធម៌ដែលគេអប់រំពេលនុ៎ង ខ្ញុំចាំ គឺអ៊ីចឹង។ តែការអនុវត្តបាន ឬមិនបានវានៅលើបុគ្គលទៀត បាទ។

**ស៖** សូមអរគុណ។ ចំពោះវិន័យនេះដដែល ឧទាហរណ៍ការចូលរួមប្រជុំសាខា តើមានការចាំបាច់ដែរឬទេ ជាពិសេសដូចជាការប្រជុំជីវភាព ឬសន្និបាតជាដើម តើវាមានការចាំបាច់សម្រាប់បក្ខជនក្នុងការចូលរួមប្រជុំសាខាដែរឬទេ?

**ឆ៖** ជាធម្មតាគេកំណត់ពេលវេលាប៉ុន្មានថ្ងៃជួបជុំគ្នាម្ដង អាហ្នឹងត្រូវតែមានមុខមកប្រជុំ តែបើមានធុរៈក៏គេមិនបង្ខំដែរ។ ធុរៈប្រពន្ធកើតកូន ធុរៈឈឺធ្ងន់ ធុរៈអីៗ ក៏អត់មានការបង្ខំ ថាដាច់ខាតត្រូវតែមកទេ។ នេះតាមខ្ញុំធ្លាប់បានទទួលការចូលរួម គឺមាន-- គឺសភាពការណ៍ហ្នឹងគឺអ៊ីចឹងបាទ។ ឯខ្ញុំកំណត់ថាគេអនុវត្តបាន១០០ភាគរយ ខ្ញុំមិនកំណត់បាទ មិនច្បាស់ទេបាទ។

[១៥:៣៦:២៨]

**ស៖** ក្នុងសម្រង់ដែលខ្ញុំអាននេះ និយាយអំពីប្រវត្តិរូបស្អាតស្អំជានិច្ចជាបន្តបន្ទាប់ជាប់ជានិច្ច។ តើអ្នកណាខ្លះនៅសម័យកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានចាត់ទុកថាមានប្រវត្តិរូបស្អាតស្អំនោះ? តើគេចង់បានន័យថាម៉េចនៅពេលដែលគេនិយាយថាមានប្រវត្តិរូបស្អាតស្អំនោះ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ឆ្លើយនេះឆ្លើយតាមការយល់របស់ខ្ញុំ។ តាមការចំណាំរបស់ខ្ញុំ មិនសន្និដ្ឋានថាឆ្លើយបានត្រូវ១០០ភាគរយទេ។ គេហៅស្អាតស្អំនោះ បានន័យថាយើងមិនខ្ជិលខិល ទីមួយ។ ទីពីរ យើងផ្សព្វផ្សាយអីទទួលខ្លឹមសារដែលឲ្យយកទៅផ្សព្វផ្សាយនេះ យើងផ្សព្វផ្សាយអស់ យើងមិនបិទបាំងអីហ្នឹងអ៊ីចឹង ស្អាតស្អំ។ ស្អាតស្អំមួយទៀត យើងទាក់ទង ប្រាស្រ័យទាក់ទងអីៗ ការគ្រប់គ្រងអីៗ ជាសម្ភារៈអីៗ ចែកចាយឲ្យប្រជាជនមហាជន គឺដោយតាមគោលការណ៍កំណត់។ ដូច្នេះគេហៅស្អាតស្អំហើយបាទ។

**ស៖** នៅពេលដែលគេនិយាយអំពីប្រវត្តិរូបច្បាស់លាស់ និងស្អាត តើនេះចង់មានន័យថា គឺថាមានមនុស្សមកពីវណ្ណៈមួយចំនួន ដូចជាមកពីមជ្ឈដ្ឋានកសិករ។ តើមាន-- ចង់មានន័យថាអំពីភាពបរិសុទ្ធនៃវណ្ណៈ ឬក៏ប្រជាជនដែលចេញមកពីតំបន់ណាមួយ ឬឧទាហរណ៍ថាមានបងប្អូន ឬក៏ឪពុកម្ដាយជាអ្នកកសិករនោះ តើអ៊ីចឹងមែនទេ ដែលថាស្អាតស្អំនោះ?

[១៥:៣៩:១១]

**ឆ៖** សូមឆ្លើយ ប្រវត្តិស្អាតស្អំដូចខ្ញុំបញ្ជាក់អំមិញអ៊ីចឹង។ ឧបមាថាមួយយើងមិនមែនស្ថិតក្នុងសភាពជាប្រវត្តិធ្វើចោរទេ ហ្នឹងស្អាតស្អំមួយ។ ហើយស្អាតស្អំពីរ យើងមិនស្ថិតក្នុងសភាពដែលជាអ្នកកេងប្រវ័ញ្ចគេឯងក្នុងសង្គម។ ហើយក្រៅពីនុ៎ងទៀត មិនមែនជាអ្នកប៉ែឡោ ផឹកស៊ី អាវ៉ាសែ ហ្នឹងគេហៅស្អាតស្អំ។ ដូច្នេះមិនមែន-- ខ្ញុំយល់ទេ គឺថាមិនមែនសំដៅថាមកពីណាពីណីទេ គេមើលអ៊ីចឹង។ មើលអតីតកាលហ្នឹងអ៊ីចឹង ហើយមកបច្ចុប្បន្នកាលដែលថ្ងៃដែលគេកំណត់ថា ល្អគ្រប់លក្ខណៈសម្បត្តិ គេមើលពេលហ្នឹង។ ហើយក៏មិនមែនបុគ្គលមើលដែរ ប្រជាជន មហាជន សាខាគេពិនិត្យខ្លួនគេ។ ហ្នឹងសូមឆ្លើយជូនប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅដល់អត្ថបទពីរទៀត-- សូមទោស គឺមាត្រាពីរទៀតគឺនិយាយអំពីលក្ខណៈសម្បត្តិ គឺឯកសារជាភាសាខ្មែរ គឺ 00442257 ជាភាសាខ្មែរ ជាភាសាបារាំង 00292919 និងជាភាសាអង់គ្លេស 00184027។ ខ្ញុំទុកពេលបន្តិចឲ្យលោករកមើលឃ្លាពាក់ព័ន្ធ គឺនៅមាត្រា១ ដែលនិយាយអំពីលក្ខណៈសម្បត្តិទីមួយ។ មាត្រា១ គឺនិយាយអំពី លក្ខណៈសម្បត្តិទទួលយកជាសមាជិកបក្ស។ លក្ខណៈសម្បត្តិទីមួយ គឺខ្ញុំសូមយកចំណុច(ខ) និង(គ)។ ចំណុច(ខ) លក្ខន្តិកៈចែងថា “ត្រូវមានវណ្ណភាពល្អ ជាវណ្ណភាពដើម ហើយជាពិសេសជាជំហរវណ្ណៈកម្មករ ហើយដែលខ្លួនបានខំកសាងជាបន្តបន្ទាប់ក្នុងចលនាបដិវត្តន៍ក្រោមការដឹកនាំរបស់បក្ស”។ ខ្ញុំចង់សួរថា តើវណ្ណភាពល្អ វណ្ណភាពដើមនៅក្នុងលក្ខន្តិកៈនេះមានន័យថាម៉េច បើតាមបក្សកុម្មុយនីស្តកម្ពុជានោះ?

[១៥:៤២:២៧]

**ឆ៖** សូមឆ្លើយជូន។ ឆ្លើយតាមការយល់បាទ ហើយការយល់ ក៏យល់មិនអស់ដែរ នូវអត្ថន័យនៃខ្លឹមសារនេះ គឺគេសំដៅថាវណ្ណភាពល្អហ្នឹង គឺបានន័យថា គ្មានជំពាក់វាក់វិនពីរឿងកេងប្រវ័ញ្ចពីរឿងអីៗទាំងអស់ ហើយវណ្ណៈហ្នឹងមិនសូវមានកម្មសិទ្ធិអីទេ ភាគច្រើនមិនមានកម្មសិទ្ធិអីទេ។ ហ្នឹងខ្ញុំយល់បានប៉ុណ្ណឹង។ ហើយទីពីរ កសាងបានល្អ បន្តបន្ទាប់ បានន័យថា មកពីខាងណា ខាងណីក៏ដោយ។ តែដល់មករួមជាមួយនឹង ក៏កសាងខ្លួនទៅបានល្អ។ បាទ យល់បានប៉ុណ្ណឹងទេបាទ។

**ស៖** ចំណុច(គ)ចែងថា ត្រូវមានសីលធម៌របស់នៅល្អស្អាតស្អំ និងស្អាតស្អំខាងនយោបាយ មិនមានអ្វី ជំពាក់ជំពិននឹងខ្លាំង។ សំណួររបស់ខ្ញុំ គឺចង់ដឹងថា តើការទាក់ទង-- ខ្ញុំប្រហែលជាទៅលឿនពេក គឺនៅទំព័រដដែលនុ៎ង គឺចំណុច(គ)។ ខ្ញុំចង់សួរថា តើការទាក់ទងជាមួយអ្នកដែលត្រូវបានចាត់ទុកថាជា

ខ្លាំងនោះ អាចកែប្រែប្រវត្តិរូបស្អាតស្អំមកជាប្រវត្តិរូបមិនស្អាតស្អំ ឬក៏អាចជាការខុសសីលធម៌អីដែរ ឬទេ?

[១៥:៤៤:២៨]

**ឆ៖** សូមឆ្លើយ។ គឺប្រវត្តិស្អាតស្អំអំមិញមានពីរ ខ្ញុំឆ្លើយរួចហើយ គឺថាមួយ ស្អាតស្អំដោយខ្លួនគេ មានប្រវត្តិគេល្អមកស្រេច នេះខ្ញុំយល់។ តែទីពីរ គេពីមុនមានប្រវត្តិមិនស្អាតស្អំដែរ មិនសូវល្អដែរ តែគេចូលមកប្រឡូកជាមួយគេ ជាមួយឯងទៅ ឃើញថាល្អ គេខំកសាងគេ ខ្លួនគេបានល្អ ក៏គេរាប់ថាល្អដែរ បាទ។ ហ្នឹងប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ សម្រង់ចុងក្រោយ គឺនៅក្នុងមាត្រា២ នៃលក្ខន្តិកៈនេះ ដែលជាភារកិច្ចរបស់បក្ខជន ផ្នែកទីពីរ ស្តីពីភារកិច្ចផ្ទៃក្នុង។ ខ្ញុំសូមអានចំណុច(ង) ដែលមាននៅទំព័រជាភាសាខ្មែរ ERN 00442261 ជាភាសាបារាំង ERN 00292922 និងភាសាអង់គ្លេស ERN 00184032។ ចំណុច(ង) ដែលនិយាយអំពីការរក្សាការសម្ងាត់។ ចំណុចនេះចែងថា “ខិតខំរក្សាការសម្ងាត់របស់បក្សជាដាច់ខាត ដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច”។ សំណួរ តើក្នុងឋានៈជាកម្មាភិបាល ឬក៏ជាសមាជិកបក្ស តើគេមានបានពន្យល់ប្រាប់លោក ថាលោកត្រូវតែមាន ភារកិច្ចការរក្សាការសម្ងាត់របស់បក្សឲ្យបានដាច់ខាតដែរឬទេ?

[១៥:៤៧:០៥]

**ឆ៖** សូមឆ្លើយ អឺ! គោលការណ៍រក្សាការសម្ងាត់នេះ ជាទូទៅ គេរំឮករហូតអ៊ីចឹង ទាំងលោកយកលក្ខន្តិកៈនេះ មកបញ្ជាក់សួរខ្ញុំ អាហ្នឹងវាមានហើយ តែខាងក្រៅ ក៏គេបញ្ជាក់អ៊ីចឹង ក្នុងមហាជន ប្រជាជន ក៏បញ្ជាក់អ៊ីចឹង។ ដូចខ្ញុំបានជម្រាបជូនថា ការងារគេ គេដឹង ការងារយើង យើងដឹង។ ដូច្នេះ មិនអាចទៅយកការងាររបស់ខាងនេះ ខាងនោះ មកផ្សព្វផ្សាយអ៊ីចេះអ៊ីចុះទេ ដឹងតែក្របខ័ណ្ឌរបស់ខ្លួន។ នេះហើយ ដែលវាទាក់ទងរក្សាការសម្ងាត់។ នេះហើយ ដែលគេអាចបន្ថែមបន្ថយថា ប្រុងប្រយ័ត្នខ្ពស់។ បាទ មានប៉ុណ្ណឹងបាទ។

**ស៖** លោកសាក្សី តើធ្លាប់មានស្ថានភាពដែលថា លោកខ្លាច ៗគឺថាប្រព្រឹត្តល្មើសនឹងការរក្សាការសម្ងាត់ដាច់ខាតនេះ ដែរឬទេ? តើបក្ខជនខ្លាចទេ នៅក្នុងការដែលនិយាយនូវអ្វីមួយ ដែលថាអាចជាការ-- អាចថាជាការនិយាយជាសាធារណៈ ប៉ុន្តែត្រូវតែមានការរក្សាការសម្ងាត់នោះ?

**ឆ៖** បាទ ធម្មតាអាហ្នឹងបាទ។ គឺយើងមានតួនាទី ហើយយើងមានក្របខ័ណ្ឌ ដូច្នេះបើយើង

មានតួនាទីកម្រិតណា ហើយយើងនិយាយហួសក្របខ័ណ្ឌ យើងចេះតែគិតដែរ ព្រោះក្នុងឋានៈដែលយើងមិនអាចរំលោភពីលាក់ការណ៍ហ្នឹងបាន។ បាទៗ ឆ្លើយប៉ុណ្ណឹងបាទ។

**ស៖** តើភារកិច្ចរក្សាការសម្ងាត់នេះ គឺថាវាចារឹកទុកក្នុងទស្សនវិជ្ជារបស់ខ្មែរក្រហម ដែលថាសូម្បីតែនៅសព្វថ្ងៃនេះ លោកមានការលំបាកណាស់ ក្នុងការថាមិនរក្សានោះ។ តើសព្វថ្ងៃ-- មានន័យថា តើសព្វថ្ងៃនេះ លោកនៅតែមានអារម្មណ៍ថា ត្រូវតែរក្សាការសម្ងាត់នេះ ឬក៏យ៉ាងណា?

[១៥:៥០:០៣]

**ឆ៖** សូមជម្រាបជូនបាទ មកដល់ថ្ងៃនេះ ខ្ញុំអត់មានគំនាបគាបអីទៀតទេ ពីព្រោះខ្ញុំស្ថិតក្នុងសភាពដែលចូលរួមជាមួយរាជរដ្ឋាភិបាលហើយ។ ហើយខ្ញុំក៏ចូលជាសមាជិកបក្ស-- ចូលជា ចូលការរួមការងារជាមួយគណៈបក្សប្រជាជន ដូច្នោះអត់មានអារម្មណ៍ហ្នឹងទៀតទេបាទ។ ខ្ញុំអាចនិយាយបានថា ខ្ញុំស្ថិតនៅក្នុងសភាពធំទូលាយហើយបាទ។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយអំពីបញ្ហាពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ ដែលលោកបានចូលរួមនៅភូមិភាគបស្ចិម គឺដំបូងនៅ-- កិច្ចប្រជុំនៅថ្នាក់មូលដ្ឋាន គឺនៅតំបន់១៥ និងតំបន់៣២។ តើមន្ទីរដែលលោកធ្វើការនោះជាមន្ទីរអី? សាខារបស់លោកឈ្មោះអ្វីដែរ? ហើយវាមានទីតាំងនៅឯណាដែរ?

**ឆ៖** មន្ទីរដែលខ្ញុំចូលរួមម្តងម្កាលជាមួយនឹងការប្រជុំបើកទូលាយហ្នឹង ដូចខ្ញុំបានជម្រាបហើយ គឺគេហៅ "ចម្ការដូង"។ ហើយមន្ទីរដែលខ្ញុំប្រជុំចូលរួមជាមួយសាខាហ្នឹង ខ្ញុំនៅម្តុំអន្លង់វស្សហ្នឹង។ បាទ មាត់ទន្លេហ្នឹង ប៉ុណ្ណឹងបាទ។

[១៥:៥២:២២]

**ស៖** ហើយសាខារបស់លោកនោះនៅ-- មានទីតាំងជាក់លាក់មួយ មានឈ្មោះច្បាស់លាស់មួយ ឬក៏គ្រាន់តែមានឈ្មោះថាជាសាខាឃោសនាអប់រំទេ?

**ឆ៖** សូមបញ្ជាក់ជូន សាខាដែលខ្ញុំធ្វើការហ្នឹង វាមិនទាន់មានអីជាមូលដ្ឋានច្បាស់លាស់ទេ ពីព្រោះចេញពីសង្គ្រាមភ្លាមៗ ហ្នឹង។ បើអង្គាល់នៅក្នុងសង្គ្រាម វាគ្រាន់តែបោះទីតាំងដូចជាដំបូលកៅស៊ូ ឬក៏ខ្ទមអី ពីស្បូវ ហើយសំចតហើយធ្វើទៅ។ ហើយដល់ក្រោយសង្គ្រាមចប់ភ្លាមៗ ក៏គ្មានអីជាមូលដ្ឋានច្បាស់លាស់ដែរបាទ។ មានតែកំណត់ថា ត្រង់នេះ ហើយធ្វើដំបូលស័ង្កសីអីទៅ ហើយក៏ធ្វើការទៅ។ តែប៉ុណ្ណឹងទេ អត់មានអីទ្រង់ទ្រាយជារូបភាពអី មានស្លាក មានប៉ាយអី អត់មានទេបាទ ច្បាស់លាស់អីទេ ។

**ស៖** បាទ សូមអរគុណ។ តើលោកបានចូលរួមនៅកិច្ចប្រជុំទិតៀន និងស្វ័យទិតៀន ឬក៏ប្រជុំជីវទស្សន៍ដែរឬទេ? តើលោកចូល-- តើលោកប្រជុំ ចូលរួមកិច្ចប្រជុំហ្នឹងនៅថ្នាក់សាខា ឬក៏កម្រិតខ្ពស់ជាងសាខាហ្នឹងទៀត?

[១៥:៥៤:២៤]

**ឆ៖** ការប្រជុំគេហៅថា ទិតៀន និងស្វ័យទិតៀននោះ គេប្រជុំតាមសាខា។ ហើយហៅថាប្រជុំទិតៀន ស្វ័យទិតៀនហ្នឹង គឺខ្លួនយើងស្វ័យមើលខ្លួនយើង ថាយើងត្រូវអី? យើងខុសអី? មូលហេតុមកពីអី? ហើយយើងកែប្រែយ៉ាងម៉េចតទៅទៀត? រួចហើយ គេដែលនៅស្តាប់យើងនោះ គេជួយមកយើងទៅ ហើយយើងយកមតិគេហ្នឹងទៅ ទៅកែលម្អខ្លួនយើងទៅ។ ឯកែបានតិចបានច្រើន អាហ្នឹងនៅលើបុគ្គលទៀត តែគេធ្វើអ៊ីចឹងបាទ។

**ស៖** តើកិច្ចប្រជុំទាំងអស់នេះ មានធ្វើរបាយការណ៍ដែរឬទេ? ហើយរបាយការណ៍ទាំងអស់នេះបានបញ្ជូនទៅថ្នាក់លើដែរឬទេ?

**ឆ៖** បាទ អាហ្នឹងគេធ្វើបាទ ប្រធានហ្នឹងគេសរុប ហើយគេយកទៅរាយការណ៍តាមថ្នាក់ ថាបានធ្វើចប់ហើយ ម្នាក់ៗបានត្រួតពិនិត្យខ្លួនហើយ បានប្តេជ្ញាកែលម្អអ៊ីចេះហើយ តែប៉ុណ្ណឹង។

[១៥:៥៦:២២]

**ស៖** តើលោកអាចនិយាយម្តងទៀត ផ្នែកទីមួយ នៃចម្លើយរបស់លោកអម្បាញ់មិញទេ ព្រោះខ្ញុំអត់បានទទួលការបកប្រែទេ។ អ្វីដែលខ្ញុំឮនោះគឺថា ប្រធានកិច្ចអង្គប្រជុំនោះធ្វើរបាយការណ៍លើអ្វីដែលអ្នកចូលរួមប្រជុំបានលើកឡើង។ តើលោកបាននិយាយអ្វីក្រៅពីហ្នឹងទៀតទេ? ព្រោះប្រហែលជាស្តាប់មិនឮផ្នែកណាមួយហើយ។

**ឆ៖** ជាមូលដ្ឋានដូចខ្ញុំជម្រាប ហើយក៏ដូចលោកស្តាប់បានអម្បាញ់មិញដែរ គឺថាគេធ្វើរាយការណ៍ហ្នឹងគេបូកសរុប អំពីលទ្ធផលនៃការប្រជុំ ថាការប្រជុំនេះពិនិត្យឃើញចំណុចល្អអ៊ីចេះ ចំណុចមិនល្អអ៊ីចេះ ហើយមូលហេតុមកពីអ៊ីចេះ ទិសដោះស្រាយតទៅមុខទៀត គឺអ៊ីចេះ ហើយគេសរសេរជាខ្លឹមសារហ្នឹងទៅ គេជូនទៅតាមថ្នាក់ទៅលើទៅបាទ។ ហ្នឹងមានប៉ុណ្ណឹងដែលខ្ញុំជម្រាបជូនអំមិញបាទ។

**ស៖** តើគឺជាកិច្ចប្រជុំទិតៀន និងស្វ័យទិតៀន ទាំងអស់នេះគឺជា កិច្ចប្រជុំដែលអ្នកចូលរួមភ័យខ្លាច ពីព្រោះថា ត្រូវតែឲ្យអ្នកផ្សេងហ្នឹង ទិតៀនមកខ្លួន តើអ៊ីចឹងមែនទេ? ជាកិច្ចប្រជុំដែលគេទាំងអស់គ្នាភ័យខ្លាចមែនទេ?

[១៥:៥៨:០៧]

**ឆ៖** អាហ្នឹងជាវិន័យ បើយើងស្មោះស្ម័គ្រថាយើងស្នេហាជាតិហើយ ហើយយើងស្មោះស្ម័គ្រថាយើងខំធ្វើខ្លួនឲ្យទៅជា អ្នកបម្រើប្រជាជនបានល្អ អាហ្នឹងវាត្រូវតែធ្វើអ៊ីចឹង។ ឯការភ័យខ្លាចដែលលោកសួរ ធម្មតាទេ មនុស្សម្នាក់ៗតែកាលណាមានចំណុចខ្សោយ វាព្រួយដែរ គេលើកចំណុចខ្សោយមក តែងតែព្រួយដែរ។ មិនមែនជាការភ័យខ្លាចទេ ព្រួយថាយើងបានធ្វើខុស ខុសពីការដែលយើងចង់បានល្អនុ៎ង។ ហ្នឹងវាមានមែនបាទ។

**ស៖** តើលោកធ្លាប់ព្រួយបារម្ភ នៅពេលដែលលោកធ្វើការនៅក្នុងភូមិភាគបូព៌ា ភ័យខ្លាចអំពីការរិះគន់ទិតៀនមកលើលោកដែរឬទេ? តើមានពេលណាជាក់លាក់មួយ ដែលលោកមានការភ័យខ្លាចពាក់ព័ន្ធនឹងបញ្ហារិះគន់មកលើលោកនេះទេ?

**ឆ៖** សូមបញ្ជាក់ជូន ខ្ញុំមិនដែលបាននៅភូមិភាគបូព៌ាទេ ខ្ញុំនៅតែតំបន់១៥។ ហើយគេរិះគន់--

**អ្នកបកប្រែ៖**

អ្នកបកប្រែសូមកែប្រែ អំមិញតាមពិតជាភូមិភាគបស្ចិម បាទ សូមទោស។

**ឆ៖** បាទ ព្រួយបារម្ភៗត្រង់ថា ផែនការដាក់មកហើយ យើងសម្រេចបាន ឬមិនបាន។ ឧបមាថាត្រូវអប់រំរយៈពេលប៉ុណ្ណេះឲ្យចប់ ហើយកែលម្អការជំរុញការបង្កបង្កើនផល ឲ្យវាបានហូបគ្រប់ ហ្នឹងព្រួយបារម្ភដែរ បាទ។

**ស៖** សាក្សីតើលោកធ្លាប់ទៅចូលប្រជុំធ្វើជីវប្រវត្តិនៅក្នុងសាខា ឬក៏នៅក្នុងតំបន់៣២ដែរឬទេ?

**ឆ៖** ចង់សួរថាម៉េច? សូមបញ្ជាក់ម្តងទៀតបាទ។

[១៦:០១:១០]

**ស៖** តើលោកធ្លាប់ចូលរួមក្នុងការប្រជុំក្នុងសាខា ឬក៏តំបន់៣០ ឬ១៥ ដែលចូលប្រជុំដែលគេសូមឲ្យលោកធ្វើជីវប្រវត្តិ ឲ្យអ្នកចូលរួមទាំងអស់ធ្វើជីវប្រវត្តិរបស់ខ្លួន?

**ឆ៖** បាទ ធ្លាប់ដែរ។ ខ្លួនខ្ញុំជាសំខាន់ ត្រូវរាយការណ៍ជូនសាខាទាំងអស់ ថាខ្លួនធ្វើអីៗពីមុន។ អាហ្នឹងធ្វើបាទ។ រួចហើយខ្ញុំធ្វើ អ្នកដទៃទៀតក៏ធ្វើដែរ រាយការណ៍ពីប្រវត្តិដើមរបស់ខ្លួននៅឯណាអីឯណា ហើយបានរៀនសូត្រ អីម៉េចៗ ដូចអំមិញអ៊ីចឹងដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។

ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកទី២៩ ខែឧសភា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី នី កន ដែលនឹងបន្តតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។

[១៦:០២:៣៩]

លោក នី កន ដោយការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ ហើយត្រូវបន្តធ្វើនៅថ្ងៃស្អែក និងថ្ងៃបន្តបន្ទាប់ទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោក មកផ្តល់សក្ខីកម្មនៅថ្ងៃស្អែក។

ដូចគ្នានេះដែរ អង្គជំនុំជម្រះសូមអញ្ជើញប្រឹក្សាសាក្សី-- មេធាវីប្រឹក្សាសាក្សីមកចូលរួមដើម្បីបន្តប្រឹក្សាសាក្សីនៅថ្ងៃស្អែក និងថ្ងៃបន្តបន្ទាប់នៃការស្តាប់សក្ខីកម្មរូបនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី ប្រសិនបើគាត់បង្ហាញជំហរច្បាស់លាស់ ក្នុងការលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ តាមរយៈពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ជាលាយលក្ខណ៍អក្សរបានមុនពេលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការសវនាការ នៅវេលាម៉ោងប្រាំបួនព្រឹកនោះ អង្គជំនុំជម្រះឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនគាត់មកត្រឹមតែបន្ទប់ឃុំខ្លួនមួយ ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*